**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
UNIVERSITÉ ROYALE DE DROIT ET DES SCIENCES ECONOMIQUES
ROYAL UNIVERSITY OF LAW AND ECONOMICS

# សារណាបញ្ចប់ការសិក្សា

# តួនាទីសារការីនៅក្នុងសន្តិកម្ម

*ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១*

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ទួន សុខគីមម៉ីសួគ៌**
**ហុង ណាតា**

សាស្ត្រាចារ្យណែនាំ
លោកស្រី **ចាំង ស៊ីណាត**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ
ជំនាន់ទី២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# អំណះអំណាង

យើងខ្ញុំ **ទួន សុខគីមម៉ីសួគ៌** និង **ហុង ណារ៉ា** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២១ ជំនាញនីតិសាស្ត្រ ឆ្នាំសិក្សា ២០១៧-២០២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ពិតជាបានជ្រើសរើស ប្រធានបទសិក្សាស្រាវជ្រាវស្តីពី «*តួនាទីសារការីក្នុងសន្តតិកម្ម*» ប្រាកដមែន។

យើងខ្ញុំសូមធានាអះអាងថា ស្នាដៃនេះ ពិតជាត្រូវបានរៀបចំចងក្រង និងបានសិក្សាស្រាវជ្រាវដោយយើងខ្ញុំផ្ទាល់ ដោយបានទទួលនូវពុទ្ធិនានា តាមរយៈការសិក្សា ថ្នាក់បរិញ្ញាបត្រ ជំនាញនីតិសាស្ត្រ នៅឯសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច រួមទាំងអនុសាសន៍ និងមតិយោបល់ណែនាំតម្រង់ទិសរបស់ លោក លោកស្រី សាស្ត្រាចារ្យកន្លងមក។

បន្ថែមពីលើនេះ យើងខ្ញុំ សូមអះអាងផងដែរថា ស្នាដៃសិក្សាស្រាវជ្រាវនេះ មិនមានការចម្លង និងមិនមានការដកស្រង់ចេញពីអត្ថបទរបស់អ្នកស្រាវជ្រាវដទៃ ដោយមិនបានកំណត់ច្បាស់លាស់ ឬមិនបានយោងនូវប្រភពឯកសារនោះទេ។ រាល់ការដកស្រង់ចេញពីប្រភពឯកសារនានាទាំងឡាយ គឺត្រូវបានចង្អុលបង្ហាញក្នុងអត្ថបទត្រង់ចំណុចនីមួយៗយ៉ាងពិតប្រាកដ រួមទាំងមានការបង្ហាញបន្ថែមក្នុង បញ្ជីឯកសារយោង និង/ឬ គន្ថនិទ្ទេស ថែមទៀតផងដែរ៕

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែសីហា ឆ្នាំ២០២១

ហត្ថលេខា

**ទួន សុខគីមម៉ីសួគ៌** **ហុង ណារ៉ា**

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ **ទួន សុខគីមមុីស្វត៍** និង **ហុង ណាតា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញនីតិសាស្ត្រ ជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សូមគោរពប្រតិបត្តិ និងសូមសម្តែងនូវកតាញ្ញូតាធម៌យ៉ាងជ្រាវជ្រៅជូនចំពោះ៖

លោកឪពុកអ្នកម្តាយ ព្រមទាំង លោកតានិងលោកយាយ ជាទីគោរពដ៏ខ្ពង់ខ្ពស់ ដែល បានផ្តល់កំណើតដល់ កូនចៅ និងបានខិតខំលះបង់អស់នូវកម្លាំងកាយកម្លាំងចិត្ត ដោយពុំខ្លាចនឿយហត់ក្នុងការចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅ កូនចៅ ឱ្យខិតខំប្រឹងប្រែងសិក្សារៀនសូត្រ ក្រេបជញ្ជក់នូវពុទ្ធិចំណេះដឹងសព្វសារពើ តាំងពីកម្រិតមូលដ្ឋាន រហូតមកដល់ពេលបច្ចុប្បន្ននេះ។

ឯកឧត្តមបណ្ឌិត លុយ ចណ្ណា សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលលោកបានផ្តល់ឱកាសជូនដល់រូបខ្ញុំបាទ ក្នុងការពង្រីកនូវចំណេះដឹងផ្នែកនីតិសាស្ត្រ និងបន្តលើកស្ទួយថ្នាលបណ្តុះបណ្តាលនូវជំនាញនីតិសាស្ត្រជូនដល់និស្សិតគ្រប់រូបផងដែរ។

ជាពិសេស លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការប្រឹងប្រែងត្រួតពិនិត្យ ដោយមិនខ្លាចនឿយហត់សម្រាប់ការចង្អុលបង្ហាញផ្លូវ ណែនាំ និងកែប្រែរាល់កំហុសឆ្គងរបស់យើងខ្ញុំ ដើម្បីធានាបានសមិទ្ធផលនៃស្នាដៃមួយដែលប្រកបដោយគុណភាពនេះ។

លោក និងលោកស្រី សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានបង្ហាត់បង្រៀនដល់រូបយើងខ្ញុំតាំងពីឆ្នាំសិក្សាមូលដ្ឋានរហូតដល់ពេលបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។

សិស្សច្បង មិត្តនិស្សិត និងរៀមច្បងរួមការងារ ដែលបានជួយណែនាំ និងផ្តល់នូវប្រភពឯកសារដល់យើងខ្ញុំ ព្រមទាំងកែសម្រួលនូវកំហុសឆ្គងទាំងឡាយ រួមទាំងផ្តល់នូវកម្លាំងចិត្តជម្រុញឱ្យយើងខ្ញុំខិតខំបន្តការសិក្សាស្រាវជ្រាវនេះរហូតដល់បានជោគជ័យ។

ជាចុងក្រោយ យើងខ្ញុំ សូមគោរពជូនពរ និងសូមលើកហត្ថាទាំងទ្វេរបួងសួងដល់ទេវតា សូមជួយថែរក្សាលោកអ្នកមានគុណគ្រប់រូប ឯកឧត្តម លោក លោកស្រីសាស្ត្រាចារ្យ និងអ្នកបានជួយទំនុកបម្រុងក្នុងកិច្ចការសារណានេះ សូមឱ្យទទួលបានជោគជ័យគ្រប់ភារកិច្ច និងសូមឱ្យជួបប្រទះតែពុទ្ធពរ ទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ៕

# អារម្ភកថា

យើងខ្ញុំឈ្មោះ **ទួន សុខគីមម៉ីសួគ៌** និង **ហុខ ណាតា** ជានិស្សិតនៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី ២១ បានឆ្លងកាត់ការសិក្សា និងការបណ្ដុះបណ្ដាលក្នុងថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រអស់រយៈពេល ៤ឆ្នាំមកហើយ។ តាមរយៈការសិក្សារយៈពេល ៤ឆ្នាំនេះ ឃើញថាការសិក្សាបរិញ្ញាបត្រនីតិសាស្ត្រ ផ្នែកនីតិសាស្ត្រនេះ ពិតជាផ្ដល់នូវសារៈសំខាន់យ៉ាងខ្លាំងសម្រាប់យើងខ្ញុំក្នុងនាមជាយុវជនជំនាន់ក្រោយ។ ជាក់ស្ដែង យើងខ្ញុំបានទទួលបាននូវចំណេះដឹង និងបទពិសោធន៍ជាច្រើនពីការសិក្សាកន្លងមកនេះ។ ទោះបីជាកាលៈទេសៈខ្លះ យើងខ្ញុំបានជួបប្រទះនូវឧបសគ្គ និងការលំបាកយ៉ាងណាក៏ដោយ ក៏យើងខ្ញុំនៅតែព្យាយាមតស៊ូក្រេបយកចំណេះវិជ្ជា ដោយមិនព្រមបោះបង់នូវការសិក្សាដ៏គាប់ប្រសើរនេះឡើយ ក្នុងគោលបំណងមួយដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រនេះឲ្យបានជោគជ័យជាស្ថាពរ។ ទន្ទឹមនឹងការបញ្ចប់បរិញ្ញាបត្រឲ្យបានជោគជ័យផងដែរ យើងខ្ញុំក៏មានគោលបំណងក្នុងការបញ្ចប់ការសិក្សាដោយការសរសេរសារណាមួយដ៏សមប្រកប ដែលជាលទ្ធផល និងជាស្នាដៃដ៏សំខាន់មួយសម្រាប់យើងខ្ញុំបន្ទាប់ពីបានសិក្សាក្រេបយកចំណេះដឹងអស់រយៈពេល ៤ឆ្នាំកន្លងមកនេះ។

ដោយឡែក ដោយសារតែមានការឆ្លងកាត់ការសិក្សាកន្លងមកនូវមុខវិជ្ជាសំខាន់ៗជាច្រើនក្នុងបរិញ្ញាបត្រនីតិសាស្ត្រ ផ្នែកនីតិសាស្ត្រនេះ យើងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើមុខវិជ្ជានីតិរដ្ឋប្បវេណី ព្រោះថាមុខវិជ្ជានេះ គឺជាមុខវិជ្ជា ដែលសិក្សាទាក់ទងនឹងបុគ្គលឯកជនដែលរួមមានសញ្ញាណនៃសន្តតិកម្មក្នុងនោះផងដែរ។ ជាងនេះទៅទៀត ក៏ជាផ្នែកមួយដ៏សំខាន់ក្នុងចំណោមផ្នែកផ្សេងៗទៀតសម្រាប់គ្រប់គ្រងសង្គម។ ពិសេសនោះ គឺយើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវបន្ថែមទាក់ទងនឹងវិជ្ជាជីវៈសារការីបន្ថែមទៀត ដែលជាស្ពានក្នុងការបង្កើននូវចំណេះដឹងឲ្យកាន់តែស៊ីជម្រៅ។ អាស្រ័យហេតុនេះហើយ ទើបយើងខ្ញុំសម្រេចចិត្តជ្រើសរើសយក ប្រធានបទមួយគឺ **“តួនាទីរបស់សារការីនៅក្នុងសន្តតិកម្ម”** មកធ្វើការសិក្សាស្រាវជ្រាវ។

មូលហេតុ ដែលយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយនេះមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងឡើងនោះគឺ ដោយសារយើងខ្ញុំមានបំណងក្នុងការទទួលបាននូវបទពិសោធន៍ និងចំណេះដឹងកាន់តែស៊ីជម្រៅអំពីផ្នែកច្បាប់សារការី។ មួយវិញទៀត ប្រធានបទមួយនេះមានភាពថ្មីស្រឡាងដែលមានបំណងក្នុងការចងក្រងឡើង ទុកជាគន្លឹះឲ្យប្អូនៗជំនាន់ក្រោយទទួលបានការស្វែងយល់ពីផ្នែកនេះឲ្យកាន់តែច្រើនបន្ថែមដែរ។ ទោះបីជាយ៉ាងណាក៏ដោយ យើងខ្ញុំសង្ឃឹមថាការស្រាវជ្រាវថ្មីនេះនឹងមានអ្វីដែលពិសេស និងលម្អិតបន្ថែមពីការស្រាវជ្រាវមុនៗ។

ដោយហេតុថា ប្រធានបទ "**តួនាទីរបស់សារការីនៅក្នុងសន្តតិកម្ម**" មានភាពធំទូលាយ ដូច្នេះយើងខ្ញុំសូមអភ័យទោសជាមុនប្រសិនបើមានភាពខ្វះខាតត្រង់ចំណុចណាមួយ ជាពិសេសរាល់ចំណុចដែលមានទាក់ទងនឹងការអនុវត្តជាក់ស្តែង ដោយហេតុថា យើងខ្ញុំជានិស្សិត ដែលពុំទាន់ឆ្លងកាត់ការអនុវត្តជាក់ស្តែងនៅឡើយ ដែលនាំឲ្យការស្រាវជ្រាវរបស់យើងខ្ញុំនៅមានកម្រិត។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ក៏យើងខ្ញុំនៅតែសង្ឃឹមថាការស្រាវជ្រាវមួយនេះនឹងអាចផ្តល់នូវចំណេះដឹងបន្ថែមបន្តិចបន្តួចដល់អ្នកសិក្សា។

យើងខ្ញុំសូមទទួលការរិះគន់ដោយស្ថាបនាពីសំណាក់ លោក លោកស្រីសាស្ត្រាចារ្យ បងៗ ប្អូនៗ មិត្តនិស្សិត ទាំងអស់ដែលបានអានស្នាដៃមួយនេះ និងរីករាយទទួលនូវរាល់កំហុសដែលកើតមានដោយអចេតនារបស់យើងខ្ញុំ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ............ ១

**ជំពូកទី១**

**វិជ្ជាជីវៈសារការីនៅក្នុងបទបញ្ញត្តិសន្តតិកម្ម និងសញ្ញាណទូទៅនៃសន្តតិកម្ម**

**ផ្នែកទី ១៖ វត្តមានវិជ្ជាជីវៈសារការី និងមុខងារទូទៅនៅក្នុងបទបញ្ញត្តិសន្តតិកម្ម** ............ ៤

**១.១. ការវិវត្តនៃច្បាប់សន្តតិកម្ម** ............ ៤

១.១.១. ក្រមរដ្ឋប្បវេណីសង្គមចាស់ ............ ៥

១.១.២. ច្បាប់ភូមិបាល ឆ្នាំ ១៩៩២ ............ ៥

១.១.៣. ច្បាប់ភូមិបាល ឆ្នាំ ២០០១ ............ ៦

**១.២. វត្តមាននៃវិជ្ជាជីវៈសារការីនៅក្នុងច្បាប់វិជ្ជមាន** ............ ៧

១.២.១. វិជ្ជាជីវៈសារការីតាមរយៈព្រះរាជក្រមលេខ ៩១០ ន.ស ............ ៧

១.២.២. វិជ្ជាជីវៈសារការីនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ............ ៧

១.២.៣. វិជ្ជាជីវៈសារការីក្នុងច្បាប់ស្តីពីបរធនបាលកិច្ច ............ ៨

**១.៣. វិជ្ជាជីវៈនៃសារការី** ............ ៩

១.៣.១. សារការីជាមន្ត្រីសាធារណៈ ............ ៩

១.៣.២. សារការីជាអាជ្ញាធរនៃលិខិតយថាភូត ............ ១០

១.៣.៣. សារការីជាអ្នកវិជ្ជាជីវៈច្បាប់ ............ ១០

**ផ្នែកទី ២៖ របបសន្តតិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា** ............ ១០

**២.១. សញ្ញាណទូទៅនៃសន្តតិកម្ម** ............ ១១

២.១.១. ការចាប់ផ្តើមសន្តតិកម្ម ............ ១១

២.១.២. អានុភាពនៃសន្តតិកម្ម ............ ១១

**២.២. លំដាប់សន្តតិកម្មតាមច្បាប់** ............ ១២

២.២.១. សន្តតិជនជានិច្ច និងសន្តតិជនលំដាប់ទី១ ............ ១២

២.២.២. សន្តតិជនលំដាប់ទី២ ............ ១៣

២.២.៣. សន្តតិជនលំដាប់ទី៣ ............ ១៣

២.២.៤. សន្តតិជនជំនួស ............ ១៤

២.២.៥. សន្តតិជនជាជនជាតិបរទេស ............ ១៤

**២.៣. សន្តតិកម្មតាមមតកសាសន៍** ............ ១៥

២.៣.១. សមត្ថភាពក្នុងការធ្វើមតកសាសន៍ ............ ១៥

២.៣.២. អានុភាពនៃមតកសាសន៍ ............ ១៦

២.៣.៣. ការលុបចោលនូវមតកសាសន៍ ............ ១៧

២.៣.៣.១. ការលុបចោលនូវមតកសាសន៍ ដោយមតកសាសន៍ ............ ១៧

២.៣.៣.២. ការលុបចោលមតកសាសន៍តាមច្បាប់កំណត់ ............ ១៨

**ជំពូកទី២**

**តួនាទីរបស់សារការីពាក់ព័ន្ធនឹងមតកសាសន៍**

**ផ្នែកទី១៖ តួនាទីសារការីក្នុងការតាក់តែងមតកសាសន៍** ............ ១៩

**១.១. មុខងារតួនាទីសារការីក្នុងសន្តតិកម្ម** ............ ១៩

១.១.១. ការតាក់តែងលិខិតយថាភូត និង ការធ្វើការបញ្ជាក់ ............ ១៩

១.១.២. ការធានានូវភាពត្រឹមត្រូវនៃឆន្ទៈ ............ ២០

១.១.៣. ការការពារ និងសុវត្ថិភាពនៃមតកសាសន៍ ............ ២១

១.១.៤. ភាពឆាប់រហ័សក្នុងការប្រតិបត្តិនៃការបែងចែកមត៌ក ............ ២១

១.១.៥. ការបង្ការវិវាទ ............ ២២

**១.២. ប្រភេទនៃមតកសាសន៍** ............ ២២

១.២.១. មតកសាសន៍ដោយលិខិតយថាភូត ............ ២២

១.២.១.១. ការចូលរួម និងវត្តមានបុគ្គលពាក់ព័ន្ធ ............ ២៣

១.២.១.២. ការតាក់តែងមតកសាសន៍ ............ ២៣

១.២.១.៣. ការបញ្ជាក់ភាពត្រឹមត្រូវនៃលិខិត ............ ២៤

១.២.២. មតកសាសន៍ដោយលិខិតឯកជន ........ ២៤
១.២.៣. មតកសាសន៍ដោយលិខិតសម្ងាត់ ........ ២៥
១.២.៣.១. ការចូលរួម និងវត្តមានបុគ្គលពាក់ព័ន្ធ ........ ២៥
១.២.៣.២. ការតាក់តែងមតកសាសន៍ និង ការដាក់លិខិតចូលស្រោមសំបុត្របិទជិត ........ ២៦
១.២.៤. មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ ........ ២៦
១.២.៥. ការធ្វើមតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន ........ ២៨
**១.៣. ចំណុចសំខាន់នៃមតកសាសន៍** ........ ២៩
១.៣.១. សមត្ថភាពក្នុងការធ្វើមតកសាសន៍ ........ ២៩
១.៣.២. លក្ខណៈសម្បត្តិជាសន្តតិជន ........ ២៩
១.៣.៣. ការចុះហត្ថលេខា និងផ្តិតស្នាមមេដៃ ........ ២៩
១.៣.៤. បុគ្គលដែលមិនអាចក្លាយជាសាក្សី ........ ៣១
១.៣.៤.១. អនីតិជន ឬជនក្រោមអាណាព្យាបាល ........ ៣១
១.៣.៤.២. ជនដែលត្រូវបានសន្មតជាសន្តតិជន ឬ អច្ច័យលាភី ជាអាទិ៍ ........ ៣១
១.៣.៤.៣. សហព័ទ្ធ ញាតិលោហិតខ្សែផ្ទាល់ ក្រឡាបញ្ជី ឬ និយោជិតរបស់សារការីពាក់ព័ន្ធ ........ ៣៣
១.៣.៥. ការកំណត់ចំណែក និង វិធីបែងចែកមត៌ក ........ ៣៣
១.៣.៦. ការកំណត់អច្ច័យទាន ........ ៣៦
១.៣.៧. ការកំណត់អំពីសន្តតិជនជំនួស និងអច្ច័យលាភីជំនួស ........ ៣៦
១.៣.៨. សិទ្ធិលើភាគបម្រុង ........ ៣៦
**ផ្នែកទី ២៖ តួនាទីសារការីក្នុងការថែរក្សា និងប្រតិបត្តិមតកសាសន៍** ........ ៣៨
**២.១. ការតម្កល់មតកសាសន៍របស់សារការី** ........ ៣៨
២.១.១. គោលបំណង ........ ៣៨
២.១.១.១. ការបំពេញនូវឆន្ទៈរបស់ម្ចាស់បណ្តាំឲ្យទទួលបានប្រសិទ្ធិភាព ........ ៣៨
២.១.១.២. ការធានាឲ្យបាននូវការទទួលស្គាល់ និងសុក្រឹត្យភាពនៃមតកសាសន៍ ........ ៣៨
២.១.២. វិធីសាស្ត្រនៃការតម្កល់មតកសាសន៍ ........ ៣៨

២.១.៣. ការចេញនូវឯកសារចម្លងយថាភូតនៃមតកសាសន៍ដោយលិខិតយថាភូត ........................... ៤០
**២.២. ការប្រតិបត្តិមតកសាសន៍ក្នុងសន្តតិកម្ម** ........................................................ ៤០
២.២.១. អ្នកប្រតិបត្តិមតកសាសន៍ ........................................................ ៤១
២.២.១.១. ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ ........................................ ៤១
២.២.១.២. វិសាលភាពនៃការប្រតិបត្តិមតកសាសន៍ ........................................ ៤២
២.២.១.៣.កម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍ និងសោហ៊ុយនៃការប្រតិបត្តិមតកសាសន៍ ............... ៤២
២.២.១.៤.សោហ៊ុយក្នុងការប្រតិបត្តិមតកសាសន៍ ........................................ ៤៣
២.២.២. ការប្រតិបត្តិមតកសាសន៍ដោយសារការី ........................................ ៤៣
២.២.២.១. ការទទួលមុខងារជាអ្នកប្រតិបត្តិមតកសាសន៍ ........................................ ៤៣
២.២.២.២. ការគ្រប់គ្រងមត៌ក និងការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ ........................ ៤៣
២.២.២.៣. ការដាក់ពាក្យសុំផ្តាច់មត៌កជាអាទិ៍ពីសន្តតិជន ........................................ ៤៥
២.២.២.៤. ការបែងចែកមត៌កដោយអ្នកប្រតិបត្តិមតកសាសន៍ ........................................ ៤៥
**២.៣. ការបែងចែកមត៌កដោយទម្រង់លិខិតយថាភូត** ........................................ ៤៦
២.៣.១. ទម្រង់នៃការពិភាក្សាបែងចែកមត៌កតាមការព្រមព្រៀង ........................................ ៤៦
២.៣.១.១. កម្មសិទ្ធិអចលនវត្ថុ ........................................ ៤៦
២.៣.១.២. ការបែងចែកសិទ្ធិលើបំណុល ........................................ ៤៦
២.៣.១.៣. ការបែងចែកសិទ្ធិប្រត្យក្សផ្សេងទៀត ........................................ ៤៧
២.៣.២. វិធីសាស្រ្តក្នុងការបែងចែក ........................................ ៤៧
២.៣.២.១.សិទ្ធិអាទិភាពរបស់សហព័ទ្ធ ........................................ ៤៧
២.៣.២.២.ការបង់ប្រាក់សម្រួល ........................................ ៤៧
២.៣.២.៣. ការពិចារណាស្ថានភាពជុំវិញ ........................................ ៤៨
២.៣.២.៤.ការផ្លាស់ប្តូរភាគបន្ទុកកាតព្វកិច្ច ........................................ ៤៨
**២.៤. បញ្ហាប្រឈមរបស់វិជ្ជាជីវៈសារការីក្នុងសន្តតិកម្ម** ........................................ ៤៨
២.៤.១. កង្វះធនធានសារការី ........................................ ៤៨

២.៤.២. កង្វះខាតក្របខ័ណ្ឌគតិយុត្ត .........................................................................................៤៩
**សេចក្តីសន្និដ្ឋាន**........................................................................................................ ៥០
**អនុសាសន៍**................................................................................................................ ៥២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

សារការីគឺជា វិជ្ជាជីវៈសេរីមួយដែលបានចាប់កំណើតឡើងនៅប្រទេសកម្ពុជាតាំងពីឆ្នាំ ១៩៥៥ មក ម្ល៉េះ។ ដោយយោងតាមព្រះរាជក្រមលេខ ៩១០ ន.ស ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៥។ ក៏ប៉ុន្តែ វិជ្ជាជីវៈសារការីនេះត្រូវផ្អាកការអនុវត្តនៅពេលដែលប្រទេសកម្ពុជាបានជួបប្រទះ ជាមួយនឹងរបបប្រល័យពូជសាសន៍ខ្មែរក្រហម ដែលបានបំផ្លិចបំផ្លាញនូវរចនាសម្ព័ន្ធប្រទេសកម្ពុជាទាំងស្រុង ដែលជាហេតុបណ្តាលឲ្យមានការបង្អាក់នូវការអភិវឌ្ឍន៍ប្រទេសកម្ពុជាអស់រយៈពេល ៣ឆ្នាំ ៨ខែ ២០ថ្ងៃ។

ដោយយើងទាំងពីរនាក់បានយល់ឃើញថា ប្រទេសកម្ពុជាគឺជា ប្រទេសកំពុងអភិវឌ្ឍន៍មួយនៅតំបន់អាស៊ីអាគ្នេយ៍ ហើយក៏ជាប្រទេសមួយដែលកំពុងស្វះស្វែងគេចខ្លួនចេញពីភាពក្រីក្រផងដែរនោះ បានជួបប្រទះជាមួយនឹងបញ្ហាជាច្រើនដូចជា បញ្ហាផ្នែកអប់រំ សេដ្ឋកិច្ច និងអភិវឌ្ឍន៍ ជាពិសេសបណ្តុះបណ្តាលវិជ្ជាជីវៈផ្នែកច្បាប់។ យោងតាមព្រះរាជក្រមលេខ ៩១០ ន.ស ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៥ ដែលជាឧបករណ៍ ឬបញ្ញត្តិដែលបង្កើតឡើងដើម្បីប្រកាសអំពីការកកើតឡើងនូវវិជ្ជាជីវៈសារការីនៅប្រទេសកម្ពុជា។ ដោយយោងតាមប្រវត្តិសាស្ត្រកម្ពុជា កម្ពុជាត្រូវបានស្ថិតនៅក្រោមការត្រួតត្រារបស់ប្រទេសបារាំងអស់រយៈពេល ៩០ឆ្នាំ ដែលជាហេតុនាំឲ្យគ្រប់វិស័យទាំងអស់ត្រូវបានគ្រប់គ្រងតាមការសម្រេចចិត្តរបស់រាជរដ្ឋាភិបាលបារាំង។ ជាងនេះទៅទៀត រដ្ឋាភិបាលបារាំងបានលូកដៃក្នុងរឿងរ៉ាវជាច្រើនដែលធ្វើឲ្យ រដ្ឋាភិបាលកម្ពុជាបាត់បង់សមត្ថកិច្ចនៃការសម្រេចសេចក្តីផងដែរ។ ជាការពិតណាស់វិជ្ជាជីវៈសារការីត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលបារាំង ពោលគឺបារាំងបានជួយប្រទេសកម្ពុជាសរសេរក្រមរដ្ឋប្បវេណីសង្គមចាស់ ឆ្នាំ១៩៦៧។ ហេតុនេះ អាចនិយាយបានថាសមត្ថកិច្ចក្នុងកិច្ចការផ្នែកច្បាប់របស់សារការីនៅក្នុងប្រទេសកម្ពុជា និងសមត្ថកិច្ចក្នុងកិច្ចការផ្នែកច្បាប់របស់សារការីនៅប្រទេសបារាំង ភាគច្រើនមានលក្ខណៈស្រដៀងគ្នា។ បន្ថែមពីនេះទៀត បើក្រឡេកមើលលើវិជ្ជាជីវៈសារការីនេះឲ្យកាន់តែស៊ីជម្រៅ គឺសារការីមិនត្រឹមតែអនុវត្តក្នុងការបង្កើតកិច្ចសន្យានានាដែលច្បាប់ទទួលស្គាល់នោះទេ ដែលក្នុងនោះផងដែរ លិខិតយថាភូតមានវិសាលភាពខ្លាំងជាងគេ។

## ២. ចំណោទបញ្ហា

ដោយហេតុថាមានបញ្ញត្តិជាច្រើនរួមមាន ច្បាប់ភូមិបាល ឆ្នាំ១៩៩២ និងឆ្នាំ២០០១ ក្រមរដ្ឋប្បវេណីសង្គមចាស់ ឆ្នាំ១៩៦៧ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១ និងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ ដែលបានចែងពីការអនុវត្តការងារក្នុងសន្តិកម្មរបស់សារការី ក្នុងនោះដែរក៏បានបង្ហាញពីមុខងារសិទ្ធិអំណាចរបស់សារការី។ យោងតាមច្បាប់ទាំងអស់នេះ គឺជាការវិវត្តនៃវិជ្ជាជីវៈសារការី។ ហេតុផលដែលធ្វើឲ្យការអនុវត្តនៃវិជ្ជាជីវៈសារការីនៅមាន

កម្រិត នោះក៏ដោយសារតែកង្វះខាតផ្នែកច្បាប់ដែលបញ្ញត្តិទាក់ទងទៅនឹង លក្ខន្តិកៈ និងនីតិវិធីក្នុងការអនុវត្ត មុខងារវិជ្ជាជីវៈសារការី។ ទោះបីជាបច្ចុប្បន្នភាព វិជ្ជាជីវៈសារការីចាប់ផ្ដើមមានការពេញនិយមក៏ដោយ ក៏ប៉ុន្តែ ចំពោះប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជាយើងគឺពុំទាន់មានការយល់ដឹង និងស្គាល់នូវវិជ្ជាជីវៈសារការីជាទូលំទូលាយនៅឡើយ។

ដូច្នេះ សារណានេះនឹងផ្ដោតសំខាន់ទៅលើការតួនាទីរបស់សារការីនៅក្នុងសន្តតិកម្មប៉ុណ្ណោះ។ ហេតុនេះ ចំណោទបញ្ហានៅក្នុងសារណានេះរួមមាន៖

- ដូចម្ដេចដែលហៅថាសន្តតិកម្ម?
- តើសារការីជានរណា? ហើយសារការីមានតួនាទីដូចម្ដេចខ្លះនៅក្នុងសន្តតិកម្ម?

## ៣. គោលបំណង៖

ចំពោះការសិក្សាស្រាវជ្រាវមួយនេះគឺ មានគោលបំណងក្នុងការ។ គោលបំណងចម្បងៗក្នុងការសិក្សាស្រាវជ្រាវនេះគឺ ផ្ដោតទៅលើរួមមាន៖

- ធ្វើការសិក្សាទៅលើជីវប្រវត្តិរបស់សារការី
- ធ្វើការសិក្សាទៅលើសញ្ញាណនៃសន្តតិកម្ម
- ធ្វើការសិក្សាទៅលើវត្តមានរបស់សារការីនៅក្នុងសន្តតិកម្ម
- ធ្វើការសិក្សាទៅលើការតាក់តែងរបស់សារការីក្នុងមតកសាសន៍
- ធ្វើការសិក្សាទៅលើការប្រតិបត្តិមតកសាសន៍
- ធ្វើការសិក្សាទៅលើបញ្ហាប្រឈមខ្លះៗដែលកើតមានក្នុងវិជ្ជាជីវៈសារការីក្នុងសន្តតិកម្ម។

គោលបំណងដែលបានរៀបរាប់ខាងលើនេះ នឹងធ្វើការពន្យល់បកស្រាយយ៉ាងក្បោះក្បាយនៅក្នុងសារណាមួយនេះ។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ៖

យ៉ាងណាមិញ ទោះបីជាតួនាទីរបស់សារការីមានច្រើនក៏ដោយ ប៉ុន្តែ ក្នុងបរិបទ ក៏ដូចជាដែនកំណត់នៃកិច្ចការស្រាវជ្រាវនេះ គឺនឹងធ្វើការស្រាវជ្រាវត្រឹមតែតួនាទីសារការីក្នុងសន្តតិកម្មតែប៉ុណ្ណោះ។ មានន័យថា ការស្រាវជ្រាវធ្វើឡើងចាប់ផ្ដើមពីជីវប្រវត្តិសារការី សញ្ញាណនៃសន្តតិកម្ម ការតាក់តែង និងប្រតិបត្តិក្នុងមតកសាសន៍។ សូមបញ្ជាក់ផងដែរថា កិច្ចការស្រាវជ្រាវមួយនេះ គឺធ្វើការសិក្សានៅក្នុងដែនប្រទេសកម្ពុជាតែប៉ុណ្ណោះ។

## ៥. សារសំខាន់នៃការស្រាវជ្រាវ៖

ការយល់ដឹងអំពីតួនាទីសារការីនៅក្នុងសន្តតិកម្ម គឺជាផ្នែកមួយដែលសំខាន់ និងចាំបាច់នៅក្នុងពេលបច្ចុប្បន្ននេះ។ តាមរយៈប្រធានបទនៃសារណា ស្ដីអំពី «**តួនាទីសារការីនៅក្នុងសន្តតិកម្ម**» នេះ នឹងអាចផ្ដល់

សារប្រយោជន៍យ៉ាងច្រើនទាក់ទងនឹងការយល់ដឹងកាន់តែច្បាស់អំពីសន្តតិកម្មនៅក្នុងប្រទេសកម្ពុជា និងសមត្ថកិច្ចសារការីក្នុងការតាក់តែង និងប្រតិបត្តិមតកសាសន៍។ លើសពីនេះទៅទៀត នៅក្នុងចំណុចបញ្ចប់នៃការស្រាវជ្រាវនេះ នឹងទទួលបានការយល់ដឹងអំពីបញ្ហាប្រឈមដែលកំពុងជួបប្រទះនៃវិជ្ជាជីវៈសារការី។

**៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ៖**

ទាក់ទងទៅនឹងប្រធានបទ **"តួនាទីសារការីនៅក្នុងសន្តតិកម្ម"** នៅក្នុងចំណុចបន្ទាប់ នឹងធ្វើការបកស្រាយនូវចំណុចសំខាន់ទាក់ទងនឹង៖

(ជំពូកទី១) វិជ្ជាជីវៈសារការីនៅក្នុងបទបញ្ញត្តិសន្តតិកម្ម និងសញ្ញាណទូទៅនៃសន្តតិកម្ម

(ជំពូកទី២) តួនាទីរបស់សារការីពាក់ព័ន្ធនឹងមតកសាសន៍។

# ជំពូកទី១

## វិជ្ជាជីវៈសារការីនៅក្នុងបទបញ្ញត្តិសន្តតិកម្ម និង សញ្ញាណទូទៅនៃសន្តតិកម្ម

# ជំពូកទី១

# វិជ្ជាជីវៈសារការីនៅក្នុងបទបញ្ញត្តិសន្តតិកម្ម និងសញ្ញាណទូទៅនៃសន្តតិកម្ម

ចាប់តាំងពីថ្ងៃដែលរូបវន្តបុគ្គលមានកំណើត រូបវន្តបុគ្គលនីមួយៗគឺត្រូវទទួលបាននូវសិទ្ធិ និងកាតព្វកិច្ចរៀងៗខ្លួន ហើយសិទ្ធិ និងកាតព្វកិច្ចនោះត្រូវបានរលត់នៅថ្ងៃដែលបុគ្គលទទួលមរណភាព។ យ៉ាងណាមិញ សិទ្ធិ និងកាតព្វកិច្ចអាចធ្វើការផ្លាស់ប្តូរ ឬធ្វើការផ្ទេរពីបុគ្គលភាពទៅកាន់អ្នកទទួលបន្តតាមរយៈសន្តតិកម្ម ឬ អច្ច័យទានក្រោយពេលដែលបុគ្គលភាពគតិយុត្តត្រូវបានបញ្ចប់។ ការធ្វើសន្តតិកម្មអាចកើតមានឡើងតាមរយៈច្រើនរូបភាព និងទម្រង់ ដោយមានគោលបំណងកំណត់អំពីបុគ្គលដែលត្រូវទទួលបានសិទ្ធិ និងកាតព្វកិច្ច ព្រមទាំងចំណែកមត៌កនៅពេលដែលមតកជនទទួលមរណភាព។

នៅក្នុងជំពូកនេះមានកម្មវត្ថុសិក្សាលើ វត្តមានវិជ្ជាជីវៈសារការី និងមុខងារទូទៅនៅក្នុងបទបញ្ញត្តិសន្តតិកម្ម (**ផ្នែកទី ១**) និងរបបសន្តតិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា (**ផ្នែកទី ២**)។

## ផ្នែកទី ១៖ វត្តមានវិជ្ជាជីវៈសារការី និងមុខងារទូទៅនៅក្នុងបទបញ្ញត្តិសន្តតិកម្ម

ចាប់តាំងពីថ្ងៃដែលរូបវន្តបុគ្គលមានកំណើត រូបវន្តបុគ្គលនីមួយៗគឺត្រូវទទួលបាននូវសិទ្ធិ និងកាតព្វកិច្ចរៀងៗខ្លួន ហើយសិទ្ធិ និងកាតព្វកិច្ចត្រូវបានរលត់នៅថ្ងៃដែលបុគ្គលនោះទទួលមរណភាព។ យ៉ាងណាមិញ សិទ្ធិ និងកាតព្វកិច្ចអាចធ្វើការផ្លាស់ប្តូរ ឬមានការផ្ទេរពីបុគ្គលភាពទៅកាន់អ្នកទទួលបន្តតាមរយៈសន្តតិកម្ម ឬធ្វើតាមរយៈអច្ច័យទានក្រោយពេលដែលបុគ្គលភាពគតិយុត្តត្រូវបានបញ្ចប់។ សន្តតិកម្មអាចកើតមានឡើងតាមរយៈច្រើនរូបភាព និងទម្រង់ ដោយមានគោលបំណងកំណត់អំពីបុគ្គលដែលត្រូវទទួលបានសិទ្ធិ និងកាតព្វកិច្ច ព្រមទាំងចំណែកមត៌កនៅពេលដែលមតកជនទទួលមរណភាព។

យោងតាមក្រមរដ្ឋប្បវេណី និង ច្បាប់ផ្សេងទៀតដែលបានកំណត់អំពីការផ្ទេរនូវសិទ្ធិ និងកាតព្វកិច្ច គឺបានផ្តល់នូវនីតិសម្បទាដល់សារការីក្នុងការធ្វើអន្តរាគមន៍ចំពោះការធ្វើសកម្មភាព ដែលមានចែងក្នុងច្បាប់ក្នុងការអនុវត្តការផ្ទេរនូវសិទ្ធិ និងកាតព្វកិច្ចពីមតកជន ទៅកាន់បុគ្គលដែលត្រូវបានទទួល ឬ សន្តតិជន។ នៅក្នុងផ្នែកនេះ យើងនឹងធ្វើការសិក្សាអំពីការវិវត្តនៃច្បាប់សន្តតិកម្ម (**ចំណុច ១.១**) វត្តមាននៃវិជ្ជាជីវៈសារការីក្នុងច្បាប់វិជ្ជមាន (**ចំណុច ១.២**) វិជ្ជាជីវៈនៃសារការី (**ចំណុច ១.៣**) និង មុខងារសារការីក្នុងសន្តតិកម្ម (**ចំណុច ១.៤**)។

### ១.១. ការវិវត្តនៃច្បាប់សន្តតិកម្ម

សន្តតិកម្ម សំដៅដល់ការផ្តល់ ផ្ទេរ ឬ អច្ច័យទាននៃសិទ្ធិ និងកាតព្វកិច្ចដល់បុគ្គលដែលជាសន្តតិជន ឬ ជាអច្ច័យលាភី។ នៅក្នុងបទបញ្ញត្តិចែងអំពីសន្តតិកម្ម សន្តតិកម្មត្រូវចាប់ផ្តើមដោយមរណភាពរបស់មតកជន

ហើយត្រូវផ្អែកតាមបញ្ញត្តិច្បាប់ ឬតាមឆន្ទៈរបស់មតកជន។[1] វត្តមាននៃច្បាប់សន្តតិកម្មនៅកម្ពុជា គឺមានកំណើតចាប់តាំងពីសម័យសង្គមបុរាណដែលកើតមានមុននៃការវិវត្តនៃនីតិរដ្ឋប្បវេណីឆ្នាំ ២០០៧ មកម្លេះ។ ការបង្កើតអោយមានច្បាប់សន្តតិកម្មគឺផ្តល់នូវវិធាន និងដំណោះស្រាយក្នុងការបែងចែងទ្រព្យសម្បត្តិទៅតាមសម័យកាលនីមួយៗ។ យ៉ាងណាមិញ ការចាប់ផ្តើម និង វិវត្តនៃច្បាប់សន្តតិកម្មទៅតាមបរិបទរបស់សង្គម គឺពុំមានការពាក់ព័ន្ធជាមួយវិជ្ជាជីវៈសារការីនោះទេ។ ដោយសារតែមានការវិវត្តជាច្រើនដំណាក់កាលទៅតាមបរិបទសង្គមកម្ពុជា ក៏ដូចជាការទទួលរងឥទ្ធិពលពីច្បាប់បរទេសផង ដូច្នេះយើងនឹងធ្វើការសិក្សាលើការវិវត្តជាដំណាក់កាលនៃច្បាប់សន្តតិកម្ម។

### ១.១.១. ក្រមរដ្ឋប្បវេណីសង្គមចាស់

ក្រោយពីប្រទេសបារាំងបានដាក់អាណានិគម ក្រមរដ្ឋប្បវេណីប៉ុទ្បុងជាភាសាជប៉ុនក៏ត្រូវបាននាំយកមក និងប្រកាសអោយប្រើជាច្បាប់នៃប្រទេសកម្ពុជា។ បន្ទាប់ពីការរំដោះចេញពីអាណានិគមបារាំងដែលបានកើតឡើងអស់រយៈពេល៩០ឆ្នាំ កម្ពុជាក៏ទទួលបាននូវឥទ្ធិពល ព្រមទាំងបទពិសោធន៍ពីបារាំងដែលបង្កអោយមានការចងក្រងក្រមរដ្ឋប្បវេណីឡើងវិញនៅឆ្នាំ ១៩៦៧ ដោយយកលំនាំតាមនីតិកម្មនៃសាធារណរដ្ឋបារាំង។ ក្រមរដ្ឋប្បវេណីឆ្នាំ ១៩៦៧ បានចែងពីបទប្បញ្ញត្តិស្តីពីសន្តតិកម្ម ដែលទទួលស្គាល់នូវភាពទូលំទូលាយនៃសិទ្ធិស្វ័យភាព តាមរយៈការផ្តល់សិទ្ធិក្នុងការបែងចែកកំណត់អំពីចំណែកមត៌ករបស់សន្តតិជន និងអច្ច័យលាភី។

ក្នុងក្រមនេះដដែល និយមន័យនៃសន្តតិកម្មបានកំណត់ ជាការផ្ទេរនូវបេតិកភណ្ឌនៃបុគ្គលម្នាក់ដែលបានស្លាប់ឱ្យទៅជនម្នាក់ ឬ ច្រើននាក់ដែលហៅថាទាយាទ ឬ សន្តតិជន ដោយការផ្ទេរនោះគឺត្រូវផ្ទេរតាមច្បាប់ ឬតាមឆន្ទៈរបស់ខ្មោច។ សន្តតិកម្មដែលត្រូវបានផ្ទេរតាមឆន្ទៈរបស់ខ្មោចគឺជាសន្តតិកម្មមានបណ្តាំ ចំណែកការផ្ទេរតាមច្បាប់គឺជាសន្តតិកម្មឥតបណ្តាំ។[2] ក្រោមក្រមរដ្ឋប្បវេណីឆ្នាំ១៩៦៧ ក៏បានបញ្ជាក់បង្ហាញនូវ សមត្ថភាពនៃជនដែលមានសិទ្ធិក្នុងការធ្វើបណ្តាំ សិទ្ធិទទួលបណ្តាំ ក៏ដូចជាការចែងអំពីប្រភេទនៃសំបុត្របណ្តាំ ឬ មតកសាសន៍ដែលអាចធ្វើឡើងដោយលិខិតបញ្ជាក់ ឬជាសំបុត្រឯកជន។

### ១.១.២. ច្បាប់ភូមិបាល ឆ្នាំ ១៩៩២

ចាប់តាំងពីឆ្នាំ ១៩៨៩ តាមរយៈកំណែទម្រង់សេដ្ឋកិច្ចប្រទេសកម្ពុជាបាននាំឱ្យកម្មសិទ្ធិឯកជនត្រូវបានចាប់កំណើតឡើងវិញ។ កម្មសិទ្ធិលើដីធ្លីរបស់បុគ្គលឯកជនត្រូវបានទទួលស្គាល់ដោយរដ្ឋតាមរយៈច្បាប់ភូមិបាលឆ្នាំ ១៩៩២ លើសពីនេះ ក្នុងច្បាប់ភូមិបាលដដែលក៏បានចែងពី បញ្ញត្តិស្តីអំពីសិទ្ធិសេរីភាពរបស់កម្មសិទ្ធិករក្នុងការចាត់ចែងទ្រព្យតាមរយៈពីរវិធី គឺ តាមកិច្ចសន្យា និងសន្តតិកម្ម។ យ៉ាងណាមិញ វិសាលភាពនៃបញ្ញត្តិ

[1] មាត្រា ១១៤៥ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ "*ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧*"។

[2] មាត្រា ៤៨៦ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៦៧។

កិច្ចសន្យា និងសន្តតិកម្មគឺត្រូវបានកម្រិតទៅលើកម្មវត្ថុនៃមត៌កជាសិទ្ធិភោគៈ និង កម្មសិទ្ធិព្រមទាំងសិទ្ធិប្រត្យក្ស លើអចលនវត្ថុតែប៉ុណ្ណោះ ហើយមានចែងអំពីសិទ្ធិ និងទ្រព្យសម្បត្តិផ្សេងៗ ដូចជា កម្មសិទ្ធិលើអចលនវត្ថុ និង សិទ្ធិលើបំណុលឡើយ។

យោងតាមច្បាប់ភូមិបាលឆ្នាំ ១៩៩២ បានកំណត់ "ភោគីអាចនឹងផ្ទេរនូវសិទ្ធិរបស់ខ្លួនខ្លះ ឬ ទាំងអស់ ទៅអ្នកដទៃតាមសន្តតិកម្ម មានបណ្តាំបាន ឬ តាមកិច្ចសន្យាក៏បាន។ លិខិតផ្ទេរនូវភោគៈនោះ ត្រូវធ្វើតាមរូបមន្ត យថាភូត"[3] ផ្អែកទៅតាមមាត្រាដែលបានចែងឡើង បញ្ជាក់ឱ្យឃើញនូវពីសារៈសំខាន់នៃ លិខិតយថាភូត ក្នុង ការផ្ទេរសិទ្ធិ ឬ ការធ្វើសន្តតិកម្ម។ ទោះសញ្ញាណនៃវិជ្ជាជីវៈសារការីពុំត្រូវបានកំណត់ក្តី ប៉ុន្តែការទាមទារតម្រូវឱ្យ មានវត្តមាននៃមន្ត្រីសាធារណៈអន្តរាគមន៍ជាដាច់ខាតក្នុងការធ្វើសន្តតិកម្មដែលតម្រូវឱ្យត្រូវធ្វើតាមលិខិត យថាភូត និងធានាឆន្ទៈពិតប្រាកដរបស់ភាគី ព្រមទាំងភាពស្របច្បាប់។

### ១.១.៣. ច្បាប់ភូមិបាល ឆ្នាំ ២០០១

ច្បាប់ភូមិបាល ឆ្នាំ ២០០១ ត្រូវបានបង្កើតឡើងក្នុងការកំណែទម្រង់ថ្មីទៅលើវិស័យភូមិបាលនៅ ប្រទេសកម្ពុជា ដោយច្បាប់នេះមានគោលដៅកំណត់អំពីរបបកម្មសិទ្ធិលើអចលនវត្ថុទាំងឡាយនៅប្រទេស កម្ពុជា[4]។ ច្បាប់នេះក៏បានចែងនូវ បទបញ្ញត្តិស្តីពីសន្តតិកម្មចំពោះទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិអចលនវត្ថុ ភោគៈ និងអវៈយវៈភេទនៃកម្មសិទ្ធិ ព្រមទាំងសិទ្ធិភណ្ឌិកអចលនវត្ថុផងដែរ។[5] នៅក្រោមច្បាប់ភូមិបាលថ្មី បទបញ្ញត្តិ អំពីសន្តតិកម្មគឺត្រូវបានចែងមានតែ ៩ មាត្រាប៉ុណ្ណោះ ចំណែកឯសម្រាប់វិជ្ជាជីវៈសារការីក៏ពុំទាន់ត្រូវបានមាន វត្តមាននៅឡើយ។

យ៉ាងណាមិញ យើងសង្កេតឃើញថា លិខិតយថាភូតត្រូវបានចែងក្នុងបទបញ្ញត្តិមួយចំនួននៃច្បាប់នេះ ជាអាទិ៍ នៅក្នុងជំពូកទី ៦ ផ្នែកទី ១ នៃច្បាប់ភូមិបាល ឆ្នាំ ២០០១ ស្តីអំពីលទ្ធកម្មដោយការទិញលក់អចលនវត្ថុ បានចែងក្នុងមាត្រា ៦៥ ដោយកំណត់ថា "ការផ្ទេរកម្មសិទ្ធិមិនអាចជំទាស់ពីតតិយជន លុះត្រាតែកិច្ចសន្យាលក់ អចលនវត្ថុបានធ្វើជាលាយលក្ខណ៍អក្សរតាមទម្រង់លិខិតយថាភូតធ្វើដោយអាជ្ញាធរមានសមត្ថកិច្ច ហើយត្រូវ បានចុះបញ្ជីនៅអង្គភាពសុរិយោដី[6] ដូចគ្នាជាមួយនឹងច្បាប់ភូមិបាល ឆ្នាំ ១៩៩២ ពាក្យ លិខិតយថាភូត គឺ សំដៅទៅលើលិខិតដែលបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច។

[3] មាត្រា ៧៣ នៃច្បាប់ភូមិបាលឆ្នាំ ១៩៩២។

[4] មាត្រា ១ នៃច្បាប់ភូមិបាលឆ្នាំ ២០០១។

[5] មាត្រា ៧១ នៃច្បាប់ភូមិបាលឆ្នាំ ២០០១។

[6] មាត្រា ៦៥ នៃច្បាប់ភូមិបាលឆ្នាំ ២០០១។

## ១.២. វត្តមាននៃវិជ្ជាជីវៈសារការីនៅក្នុងច្បាប់វិជ្ជមាន

ដោយមានការសង្កេតឃើញថា កន្លងមកការចូលរួមនៃអាជ្ញាធរមានសមត្ថកិច្ចក្នុងការចូលរួមធានាធន្ទៈ ក៏ដូចជាការទប់ស្កាត់ និង បង្ការនូវវិវាទដែលអាចបង្ករឡើងដោយការចោទប្រកាន់ ឬភាពមិនច្បាស់ការនៃធន្ទៈ មានសារៈសំខាន់ នោះក៏នាំឱ្យមានការកកើតលេចឡើងនៃវិជ្ជាជីវៈសារការីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីមកបំពេញភារៈកិច្ចក្នុងការធានាធន្ទៈ ទប់ស្កាត់និងបង្ការនូវវិវាទ ព្រមទាំងធានាភាពឆាប់រហ័សនៃកិច្ចការជំនួញ និងការធ្វើកិច្ចសន្យាផ្សេងៗ។ ហេតុនេះ យើងនឹងសិក្សាលើការលេចឡើងនៃវិជ្ជាជីវៈសារការីនៅក្នុងច្បាប់នៃប្រទេសកម្ពុជា។

### ១.២.១. វិជ្ជាជីវៈសារការីតាមរយៈព្រះរាជក្រមលេខ ៩១០ ន.ស

វិជ្ជាជីវៈសារការីត្រូវបានបង្ហាញវត្តមានដំបូងបំផុតក្នុងនីតិខ្មែរ តាមរយៈព្រះរាជក្រមលេខ ៩១០ ន.ស ឆ្នាំចុះថ្ងៃទី ០៤ វិច្ឆិកា ឆ្នាំ១៩៥៤ ស្ដីបទបញ្ញត្តិវិជ្ជាជីវៈសារការីជាមន្ត្រីសាធារណៈ[7]។ គោលបំណងនៃច្បាប់នេះឡើង គឺដើម្បីជាក្របខ័ណ្ឌគ្រប់គ្រងវិជ្ជាជីវៈសារការី ដោយរួមមានការបង្កើតមន្ទីរសារការី ការតែងតាំង ព្រមទាំងការបែងចែកសិទ្ធិ និងកាតព្វកិច្ចរបស់សារការី ក៏ដូចជាមុខងារ និងតួនាទីរបស់សារការីផងដែរ។ បន្ថែមពីនេះ អត្តសញ្ញាណនៃសារការីត្រូវបានរំលេច តាមនិយមន័យដែលបានកំណត់ក្នុងបទបញ្ញត្តិទូទៅនៃច្បាប់នេះ។

ក្នុងល័ក្ខខ័ណ្ឌបំពេញងារជាសារការី ច្បាប់នេះបានកំណត់ថា ការតែងតាំងសារការីគឺត្រូវបានធ្វើឡើងតាមសេចក្ដីស្នើសុំនៃរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ហើយត្រូវមានការកំរិតប្រាក់ធានាដែលសាមីខ្លួនត្រូវបង់មុន និងទទួលសម្បថសច្ចា។[8] យ៉ាងណាមិញ បទបញ្ញត្តិដែលបានចែងឡើង មានលក្ខណៈធំទូលាយខ្លាំង ដែលពុំមានការគ្របដណ្ដប់ទៅលើចំណុចលម្អិតពាក់ព័ន្ធទៅនឹងបទបញ្ញត្តិសន្តតិកម្មឡើយ។

### ១.២.២. វិជ្ជាជីវៈសារការីនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ក្រោមការដឹកនាំនៃក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា និងប្រទេសជប៉ុន តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិប្រទេសជប៉ុន ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ត្រូវបានបង្កើតឡើងជាជំនួយក្នុងការលើកស្ទួយអភិវឌ្ឍន៍វិស័យច្បាប់ និងយុត្តិធម៌។ នៅក្នុងច្បាប់នេះ បានរំលេចអោយឃើញនូវការលេចឡើងនៃវត្តមានរបស់សារការីនៅក្នុងក្របខណ្ឌសន្តតិកម្ម ដោយក្នុងបទបញ្ញត្តិសន្តតិកម្ម សារការីត្រូវបានផ្ដល់តួនាទីតាមរយៈការតាក់តែងមតកសាសន៍[9] ការប្រតិបត្តិ និងការផ្ដល់យថាភូតភាពចំពោះការពិភាក្សាក្នុងការបែងចែកមត៌ក[10]។

---

[7] សូមមើល ឧបសម្ព័ន្ធ ១។

[8] មាត្រា ៩ នៃព្រះរាជក្រមលេខ ៩១០ ន.ស។

[9] មាត្រា ១១៧៣ និង ១១៧៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[10] មាត្រា ១២៦៦ ថ្មី នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

យើងអាចសង្កេតឃើញថា ការចូលរួមអន្តរាគមន៍របស់សារការីក្នុងបទបញ្ញត្តិសន្តតិកម្ម ឬ ការតាក់តែងមតកសាសន៍ ត្រូវបានបកស្រាយ និងចងក្រងដោយមានភាពលម្អិតប្រសើរ ប៉ុន្តែទោះបីជាការចែងកំណត់មានភាពលម្អិតក្តី ការប្រតិបត្តិអនុវត្តនូវបទបញ្ញត្តិសន្តតិកម្ម គឺមានកម្រិតនៅឡើយ។ ជាមូលហេតុនៃការដែលមានកម្រិតក្នុងការប្រតិបត្តិអនុវត្ត គឺដោយសារតែការខ្វះខាតនូវធនធានក្នុងវិជ្ជាជីវៈសារការី ជាក់ស្តែង គិតត្រឹមថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១១ មន្ទីរសារការីដែលកំពុងប្រតិបត្តិផ្តល់សេវាកម្មនៅក្នុងប្រទេសកម្ពុជាមានចំនួន ២ តែប៉ុណ្ណោះ។ ដើម្បីជាដំណោះស្រាយ នៅក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី បានចែងថា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មានសិទ្ធិក្នុងការកំណត់តែងតាំងមន្ត្រីទទួលបន្ទុកការងារសារការីជាបណ្តោះអាសន្នតាមតម្រូវការចាំបាច់ នៅក្នុងអំឡុងពេលរហូតដល់មានការកំណត់ផ្សេង មិនឱ្យលើសពី២នាក់ នៅក្នុងដែនសមត្ថកិច្ចនៃសាលាដំបូង បន្ថែមពីនេះ ក្នុងករណីចៅក្រមត្រូវបានកំណត់ជាមន្ត្រីទទួលបន្ទុកកិច្ចការសារការី នឹងត្រូវដកហូតសមត្ថកិច្ចពីសមត្ថកិច្ចជំនុំជំរះចំពោះរឿងក្តីដែលខ្លួនបានចាត់ចែងកិច្ចការសារការី។[11]

### ១.២.៣. វិជ្ជាជីវៈសារការីក្នុងច្បាប់ស្តីពីបរធនបាលកិច្ច

បរធនបាលកិច្ច គឺសំដៅដល់កិច្ចការគ្រប់គ្រង និងចាត់ចែងបរធនដែលផ្តល់ដោយបរធនបាលទាយក[12] សម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ ដោយអនុលោមតាមលិខិតបរធនបាលកិច្ច ឬ បទប្បញ្ញត្តិជាធរមាន។[13] នៅក្នុងច្បាប់បរធនបាលកិច្ចនេះ យើងសង្កេតឃើញមានចំណុចពាក់ព័ន្ធនឹងការកំណត់តួនាទីសារការីនៅក្នុងបទបញ្ញត្តិសន្តតិកម្ម បន្ថែមពីនេះ បរធនបាលកិច្ចត្រូវបានចែងជា៤ប្រភេទ ដូចជា៖ បរធនបាលកិច្ចសាធារណៈ បរធនបាលកិច្ចពាណិជ្ជកម្ម បរធនបាលកិច្ចសង្គម និង បរធនបាលកិច្ចបុគ្គល។ ដោយក្នុងចំណោមបរធនបាលកិច្ចទាំងបួនប្រភេទ គឺមានតែបរធនបាលកិច្ចពីរប្រភេទប៉ុណ្ណោះ រួមមាន បរធនបាលកិច្ចពាណិជ្ជកម្ម[14] និង បរធនបាលកិច្ចបុគ្គល[15] ដែលពាក់ព័ន្ធនឹងការចូលរួមពីសារការីក្នុងការបង្កើតលិខិតបរធនបាលកិច្ច។

នៅក្នុងការកំណត់អំពីបរធនបាលកិច្ចបុគ្គល បានបង្ហាញថា ក្នុងករណីបរធនបាលទាយកធ្វើមតកសាសន៍ នៅពេលដែលបរធនបាលទាយកនោះទទួលមរណភាពតាមមតកសាសន៍ បង្កើតបានជាបរធនបាល

---

[11] មាត្រា ១០ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។

[12] ឧបសម្ព័ន្ធនៃច្បាប់ស្តីពីបរធនបាលកិច្ច (សន្ទានុក្រម) ចំនុចទី ៨ និយមន័យនៃបរធនបាលទាយក
“បរធនបាលទាយក គឺបុគ្គលដែលបង្កើត និងកំណត់ល័ក្ខខ័ណ្ឌនៃបរធនបាលកិច្ច និងផ្តល់ទ្រព្យសម្បត្តិ ឬ មូលនិធិដំបូងក្នុងបរធនបាលកិច្ច។”

[13] សូមមើលឧបសម្ព័ន្ធ ២។

[14] មាត្រា ១០ នៃច្បាប់ស្តីពីបរធនបាលកិច្ច។

[15] មាត្រា ១៣ នៃច្បាប់ស្តីពីបរធនបាលកិច្ច។

កិច្ចដែលស្របតាមបទបញ្ញត្តិនៃក្រមរដ្ឋប្បវេណី។[16] ជាក់ស្តែង ក្នុងច្បាប់ស្តីពីបរធនបាលកិច្ច ពុំបានកំណត់ច្បាស់នូវវិធានដែលពាក់ព័ន្ធនឹងបរធនបាលកិច្ចតាមមតកសាសន៍នៅឡើយទេ ដោយច្បាប់នេះគ្រាន់តែមានការបង្ហាញឱ្យឃើញថា ការកំណត់នៃច្បាប់នេះ គឺស្របតាមបទបញ្ញត្តិនៃក្រមរដ្ឋប្បវេណី។

បរធនបាលកិច្ចតាមមតកសាសន៍ គឺជាបរធនបាលកិច្ចដែលបង្កើតឡើងក្នុងគោលបំណង ផ្តល់ប្រយោជន៍អោយសន្តតិជន ឬ បុគ្គលដែលត្រូវទទួលផលពីកិច្ចការបរធនបាលកិច្ច ជាអាទិ៍ នៅក្នុងករណីសន្តតិជនជាអនីតិជន ឬ ជនបរទេសដែលពុំមានសិទ្ធិកាន់កាប់អចលនវត្ថុជាដើម។ បរធនបាលកិច្ចនេះ គឺជាបរធនបាលកិច្ចបុគ្គល ដែលកំណត់ភាពជាក់លាក់នៃការចាប់ផ្តើមសន្តតិកម្ម ដោយមត៌កត្រូវផ្ទេរទៅកាន់បរធនបាល ដែលជាអ្នកគ្រប់គ្រង និងចាត់ចែង ក្នុងនាម ឬ ជាប្រយោជន៍ដល់ជនជាសន្តតិជន ឬ បុគ្គលដែលបានកំណត់។

### ១.៣. វិជ្ជាជីវៈនៃសារការី

តួនាទីសារការីគឺជាតួនាទីចាំបាច់នៅក្នុងការអន្តរាគមន៍ ក៏ដូចជាធ្វើការប្រតិបត្តិនូវសន្តតិកម្ម ដោយមូលហេតុតែ វិជ្ជាជីវៈនេះត្រូវបានគេទទួលស្គាល់ ព្រមទាំងទទួលបានសិទ្ធិអំណាចក្នុងការអន្តរាគមន៍កិច្ចការមួយចំនួនផ្សេងទៀត។ ដោយសារតែភាពស្រដៀងគ្នារវាងវិជ្ជាជីវៈសារការី និងវិជ្ជាជីវៈមេធាវី ទើបច្បាប់បានផ្តល់នូវប្រតិភូតកម្មអំណាចពិសេសដល់សារការី ហេតុនេះទើប លិខិតយថាភូត ឬ កិច្ចសន្យាដែលធ្វើឡើងដោយសារការីត្រូវបានចាត់ទុកជាលិខិតយថាភូត និងមានតម្លៃជាងលិខិតដែលធ្វើឡើងដោយអ្នកវិជ្ជាជីវៈដទៃ។

#### ១.៣.១. សារការីជាមន្ត្រីសាធារណៈ

សារការី ត្រូវបានកំណត់ជាមន្ត្រីសាធារណៈដែលតែងតាំងឡើងដោយព្រះរាជក្រឹត្យនៃរដ្ឋាភិបាល ដើម្បីបំពេញភារកិច្ចក្នុងការផ្តល់យថាភូតភាពលើលិខិត និងកិច្ចសន្យាទាំងឡាយជាអាទិ៍ ទទួលនិងធ្វើតាមតម្រូវការនៃកិច្ចសន្យា ឬ លិខិតយថាភូតដែលត្រូវធ្វើឱ្យមានចរិកពេញលក្ខណៈតាមផ្លូវច្បាប់ ចេញការបញ្ជាក់កាលបរិច្ឆេទនៃលិខិត ទទួលរក្សាលិខិត និង ចេញសេចក្តីដើមឬសេចក្តីចម្លងនៃលិខិតនោះ។[17] ទោះសារការីត្រូវបានរាប់បញ្ចូលជាមន្ត្រីសាធារណៈ ប៉ុន្តែសារការីមិនមែនជាមន្ត្រីរាជការស៊ីវិល ដែលស្ថិតក្រោមច្បាប់សហលក្ខន្តិកៈនៃជាមន្ត្រីរាជការស៊ីវិលឡើយ។ សារការី គឺស្ថិតនៅក្រោមការត្រួតពិនិត្យ និងការដាក់ពិន័យពីរដ្ឋ តែពុំទទួលបានប្រាក់ខែ ឬប្រាក់ឧបត្ថម្ភជំនួយពីរដ្ឋឡើយ។ សារការីបំពេញការងារឯករាជ្យ និងទទួលប្រាក់កម្រៃពីការងារផ្តល់សេវា តាមរយៈការពិគ្រោះ ការបង្កើតលិខិតយថាភូត និងពិនិត្យលិខិតស្នាមនៅមន្ទីសារការីរបស់ខ្លួន។

---

[16] មាត្រា ១៣ ចំណុចទី២ ខ នៃច្បាប់ស្តីពីបរធនបាលកិច្ច។

[17] មាត្រា ១ នៃព្រះរាជក្រមលេខ ៩១០ ន.ស។

យោងតាមព្រះរាជក្រមលេខ ៩១០ ន.ស ដដែល សារការីអាចធ្វើការសម្របសម្រួលការងារដល់មន្ត្រីសារធារណៈដូចជា ចៅហ្វាយស្រុក មេឃុំ មេភូមិ ចៅសង្កាត់។ យ៉ាងណាមិញ យើងក្រឡេកទៅមើលក្រមរដ្ឋប្បវេណីនៃព្រះរាជណាចក្រកម្ពុជាឆ្នាំ ២០០៧ សារការីគឺត្រូវបានកំណត់ក្នុងនិយមន័យប្រហាក់ប្រហែលទៅនឹងច្បាប់ស្តីពីលក្ខន្តិកៈសារការីចាស់ ឆ្នាំ ១៩៥៤ ដោយសារការីជាមន្ត្រីសាធារណៈមានមុខងារជាអ្នកធ្វើ និងបញ្ជាក់លិខិតយថាភូតដែលកំណត់ និងកែតម្រូវឱ្យមានចរិកពេញលក្ខណៈតាមផ្លូវច្បាប់ ដោយធានារ៉ាប់រងអំពីភាពត្រឹមត្រូវនៃលិខិត ក៏ដូចជា តម្កល់និងរក្សាទុកនូវលិខិតយថាភូតនោះ។

### ១.៣.២. សារការីជាអាជ្ញាធរនៃលិខិតយថាភូត

វិជ្ជាជីវៈសារការីគឺត្រូវបានកំណត់ឱ្យសារការីក្លាយជាមន្ត្រីសាធារណៈ ប៉ុន្តែសារការីមានសិទ្ធិច្រើនជាងមន្ត្រីសាធារណៈផ្សេងៗដែលតួនាទីនោះគឺត្រូវផ្តល់ឱ្យដោយរាជរដ្ឋាភិបាល។ សិទ្ធិដែលត្រូវបានប្រគល់ឱ្យសារការីក្នុងនាមជាមន្ត្រីសាធារណៈ គឺសិទ្ធិក្នុងការបញ្ជាក់ទម្រង់ការមុខក្រសួងខ្លួន នូវលិខិតគ្រប់ប្រភេទដែលបានកម្រិតទៅតាមចំនួនទឹកប្រាក់ដែលបានកំណត់។[18] ក្នុងការបង្កើតឱ្យមានវិជ្ជាជីវៈនេះឡើង គឺដើម្បីធ្វើការធានានូវគោលដៅរួមមាន យថាភូតភាព តុល្យភាព ប្រសិទ្ធិភាព និងសុវត្ថិភាពគតិយុត្តនៃលិខិត និងដំណើរការនៃការធ្វើលិខិតជូនចំពោះគូភាគីនៃកិច្ចសន្យា។

លិខិតយថាភូតដែលកកើតដោយសារការីគឺមានលក្ខណៈសម្បត្តិបីយ៉ាង កាលបរិច្ឆេទស្ថាពរ អំណាចជាលិខិតអនុវត្ត និងអំណាចបន្ទាល់ ដោយលិខិតនេះត្រូវបានទទួលស្គាល់ និងផ្តល់សិទ្ធិអំណាចតាមច្បាប់ ក៏ព្រមទាំងមានការចូលរួមអនុវត្តដោយភាពតឹងរឹងផងដែរ។

### ១.៣.៣. សារការីជាអ្នកវិជ្ជាជីវៈច្បាប់

ដូចនឹងវិជ្ជាជីវៈដទៃទៀតដែរ សារការីគឺជាអ្នកច្បាប់ ដែលធានាសុវត្ថិភាពគតិយុត្តនៃលិខិត ឬកិច្ចសន្យា សារការីមានកាតព្វកិច្ចសាធារណៈជាករណីមួយ។ ប៉ុន្តែសារការីត្រូវបានចាត់ទុកជាមន្ត្រីសាធារណៈដែលបានតែងតាំងដោយព្រះរាជក្រឹត្យ[19] ហេតុនេះការណ៍ដែលសារការីជាអ្នកជំនាញច្បាប់ដែរ នេះគឺជាផលចម្បងមួយនៃកាតព្វកិច្ច និងទំនួលខុសត្រូវរបស់សារការីក្នុងការត្រួតពិនិត្យឯកសារ និងផ្តល់ប្រឹក្សាលើបញ្ហាផ្សេងៗដែលច្បាប់បានចែងតម្រូវ។

## ផ្នែកទី ២៖ របបសន្តតិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ជាទូទៅ នៅពេលបុគ្គលម្នាក់បានទទួលអនិច្ចកម្មទៅដែលនាំឲ្យមានបន្សល់នូវទ្រព្យសម្បត្តិរបស់បុគ្គលនោះ ក៏ដូចជាសិទ្ធិ និងករណីយកិច្ចដែលបុគ្គលនោះមានបន្សល់ទៅឲ្យបុគ្គលម្នាក់ទៀត។ ដូចនេះហើយ នៅក្នុង

---

[18] មាត្រា ៣ នៃព្រះរាជក្រមលេខ ៩១០ ន.ស។

[19] មាត្រា ១ កថាខណ្ឌទី ១ នៃព្រះរាជក្រមលេខ ៩១០ ន.ស។

ផ្នែកនេះនឹងធ្វើការបកស្រាយពីសញ្ញាណទូទៅដែលទាក់ទងនឹងសន្តតិកម្មដែលមាន បីចំណុចធំៗ រួមមាន សញ្ញាណទូទៅនៃសន្តតិកម្ម (**ចំណុច ២.១**) សន្តតិកម្មតាមច្បាប់ (**ចំណុច ២.២**) និងសន្តតិកម្មតាមមតកសាសន៍ (**ចំណុច ២.៣**)។

### ២.១. សញ្ញាណទូទៅនៃសន្តតិកម្ម

យោងតាមក្រមរដ្ឋប្បវេណី សន្តតិកម្មគឺជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឲ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈឬតាមច្បាប់។[20] រីឯសន្តតិជន គឺជាជនដែលទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនតាមរយៈសន្តតិកម្ម។[21] បុគ្គលដែលមានលក្ខណៈសម្បត្តិក្នុងការក្លាយជាសន្តតិជន មានតែជនដែលមានជីវិតរស់នៅ នាពេលចាប់ផ្តើមសន្តតិកម្មហើយមិនមែនជាអភ័ព្វបុគ្គល ឬបុគ្គលដែលបានកាត់ផ្តាច់មត៌កពីមតកជន ទើបអាចទទួលសន្តតិកម្មបាន។[22] ហើយរាប់បញ្ចូលនូវទារកនៅក្នុងគភ៌នាពេលចាប់ផ្តើមសន្តតិកម្ម ហើយទារកនោះមានកំណើតនៅពេលក្រោយ ក៏អាចទទួលមត៌កដោយសន្តតិកម្មនោះបាន។[23]

#### ២.១.១. ការចាប់ផ្តើមសន្តតិកម្ម

ការចាប់ផ្តើមធ្វើសន្តតិកម្ម ឬការចាប់ផ្តើមបើកឲ្យមាននូវសន្តតិកម្មមួយកើតឡើងបានលុះត្រាតែមតកជននោះបានទទួលមរណភាព។[24] ប្រសិនបើមតកជនមិនទាន់ទទួលមរណភាពទេ សន្តតិកម្មនៅតែមិនទាន់អាចកើតឡើងបានដែរ។ មួយវិញទៀត ទីកន្លែងដែលចាប់ផ្តើមបើកសន្តតិជនគឺស្ថិតនៅលំនៅឋានរបស់មតកជននាពេលទទួលមរណភាព។[25] ក្នុងសន្តតិកម្ម ត្រូវធ្វើឡើងដោយគោរពទៅតាមបញ្ញត្តិនៃច្បាប់ ឬដោយផ្អែកតាមឆន្ទៈរបស់មតកជន។ សន្តតិកម្មដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ហៅថា សន្តតិកម្មតាមច្បាប់។ រីឯសន្តតិកម្មដោយផ្អែកតាមឆន្ទៈរបស់មតកជនហៅថា សន្តតិកម្មមានបណ្តាំ។[26]

#### ២.១.២. អានុភាពនៃសន្តតិកម្ម

ចំពោះសន្តតិកម្មមានអានុភាពគិតចាប់ពីពេលមតកជនបានទទួលមរណភាព និងត្រូវធ្វើឡើងតាមគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ។ មួយវិញទៀត ទាក់ទងនឹងសិទ្ធិ និងករណីយកិច្ចទាំងអស់ដែលស្ថិត

[20] សន្ធានុក្រមផ្នែករដ្ឋប្បវេណីនៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[21] សន្ធានុក្រមផ្នែករដ្ឋប្បវេណីនៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[22] មាត្រា ១១៤៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[23] មាត្រា ៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[24] មាត្រា ១១៤៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[25] មាត្រា ១១៤៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[26] មាត្រា ១១៤៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

នៅក្រោមទ្រព្យសម្បត្តិរបស់មតកជន គឺត្រូវឲ្យសន្តតិជនជាអ្នកទទួលបន្តដែលគិតចាប់ពីពេលដែលចាប់ផ្តើមបើកសន្តតិកម្ម។[27] ប៉ុន្តែចំពោះសិទ្ធិ និងករណីយកិច្ចផ្តាច់មុខទាំងស្រុងរបស់មតកជនដូចជា អាហារកាតព្វកិច្ច ដែលមតកជនមាន ឬមុខជំនាញការងាររបស់មតកជន ឬសិទ្ធិ និងករណីយកិច្ចទាំងឡាយណាដែលមិនអាចផ្ទេរបាននោះគឺមិនត្រូវយកមកអនុវត្តឡើយ។ ទាក់ទងទៅនឹងការទទួលបន្តសិទ្ធិលើទ្រព្យសម្បត្តិ ក្នុងករណីដែលមានសន្តតិជនច្រើននាក់នោះ គឺត្រូវទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចតាមសមាមាត្រនៃចំណែកមត៌ក។ ប៉ុន្តែប្រសិនបើសិទ្ធិ និងករណីយកិច្ចដែលមិនអាចបែងចែកបានតាមលក្ខណៈនៃសិទ្ធិ ឬករណីយកិច្ចនោះត្រូវទទួលបន្តដោយអវិភាគីយ៍[28]។[29]

### ២.២. លំដាប់សន្តតិកម្មតាមច្បាប់

នៅក្នុងរឿងសន្តតិកម្ម មិនមែនមនុស្សគ្រប់រូបសុទ្ធតែអាចក្លាយជាសន្តតិជនក្នុងការទទួលបានមត៌កគ្រប់ទីកន្លែងបាននោះទេ។ ហើយក្នុងរឿងសន្តតិកម្មនេះទៀតសោត ភាគច្រើនតែងតែមានទំនាស់បញ្ហារវាងសន្តតិជន និងសន្តតិជនដែលអាចនិយាយសាមញ្ញបានថាជម្លោះកេរ្តិ៍មត៌ក។ ហេតុដូចច្នេះហើយ បានជាច្បាប់ធ្វើការតាក់តែងផ្នែកនេះឡើង ដើម្បីបញ្ចៀសពីបញ្ហាដែលកើតមានឡើង ក៏ដូចជាកំណត់បែងចែកឲ្យបានច្បាស់លាស់ថានរណាខ្លះដែលត្រូវក្លាយជាសន្តតិជន និងស្ថិតក្នុងលំដាប់ណាដើម្បីឲ្យសន្តតិជនបានដឹងថាខ្លួនមានសិទ្ធិក្នុងការក្លាយជាសន្តតិជនទទួលយកមត៌កនោះដោយពេញលេញស្របច្បាប់។ នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់អំពីលំដាប់នៃសន្តតិកម្មតាមច្បាប់។

#### ២.២.១. សន្តតិជនជានិច្ច និងសន្តតិជនលំដាប់ទី១

សហព័ទ្ធរបស់មតកជន ត្រូវតែជាសន្តតិជនជានិច្ច។[30] ដោយក្នុងនោះ សហព័ទ្ធគឺមានឋានៈស្មើគ្នាទៅនឹងសន្តតិជនផ្សេងទៀត ដែលស្ថិតក្នុងលំដាប់សន្តតិជនទី១ ក្នុងការទទួលយកសន្តតិកម្ម។ ជាក់ស្តែង កូនជាសន្តតិជនលំដាប់ទី១ ដែលនាំឲ្យសហព័ទ្ធនោះក៏ជាសន្តតិជនលំដាប់ទី១ដូចគ្នា។ មួយវិញទៀត ចំពោះកូនរបស់មតកជនដែលត្រូវក្លាយជាសន្តតិជន គឺសំដៅទៅកូនដែលមានបុគ្គលភាពទទួលស្គាល់តាមផ្លូវច្បាប់ ឬកូនដែលទទួលបាននូវខាន់ស្លាដែលឪពុកម្តាយរបស់កូននោះបានចុះនូវ សំបុត្រអាពាហ៍ពិពាហ៍ សមស្របតាមផ្លូវច្បាប់។ ក្នុងករណី កូនដែលឥតខាន់ស្លា មានន័យថា ឪពុកម្តាយរបស់កូននោះមិនបានចុះនូវសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់ទេ ទោះបីជាឪពុកម្តាយ និងកូនមានទំនាក់ទំនងជាសាច់លោហិតបង្កើត

---

[27] មាត្រា ១១៤៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[28] សន្ទានុក្រមផ្នែករដ្ឋប្បវេណីនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[29] មាត្រា ១១៤៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[30] មាត្រា ១១៦១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

នឹងគ្នាក៏ដោយ ក៏កូននោះមិនអាចក្លាយទៅជាសន្តតិជនបានឡើយ ព្រោះតែកូននោះគឺមិនបានទទួលស្គាល់តាមផ្លូវច្បាប់។

ម្យ៉ាងទៀត ចំពោះកូនស្មុំនៅក្នុងសន្តតិកម្មទាំងកូនស្មុំពេញលេញ និងកូនស្មុំធម្មតាគឺសុទ្ធតែអាចទទួលបាននូវសន្តតិកម្មបានដូចគ្នា។ កូនស្មុំធម្មតា គឺអាចទទួលសន្តតិកម្ម ឬក្លាយជាសន្តតិជនរបស់ឪពុកម្ដាយបង្កើតផង និងឪពុកម្ដាយចិញ្ចឹមផងដោយយោងតាមមាត្រា ១០២៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា។[31] ប៉ុន្តែសម្រាប់កូនស្មុំពេញលេញ អាចទទួលសន្តតិកម្ម ឬក្លាយជាសន្តតិជនបានតែចំពោះឪពុកម្ដាយចិញ្ចឹមប៉ុណ្ណោះ។ នេះបញ្ជាក់ថា កូនស្មុំពេញលេញបានបញ្ចប់នូវញាតិភាពជាមួយនឹងឪពុកម្ដាយបង្កើតហើយ យោងតាមមាត្រា ១០១៤នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា។[32] ដូចនេះ កូនស្មុំពេញលេញមិនអាចក្លាយជាសន្តតិជនរបស់ឪពុកម្ដាយបង្កើតបានទេ គឺអាចក្លាយជាសន្តិជនរបស់ឪពុកម្ដាយចិញ្ចឹមតែប៉ុណ្ណោះ។

### ២.២.២. សន្តតិជនលំដាប់ទី២

សន្តតិជនដែលមានលំដាប់ទីពីរ គឺជាបុព្វញាតិផ្ទាល់របស់មតកជនដែលនៅជិតជាង ដែលសំដៅលើឪពុកម្ដាយរបស់មតកជនជាអ្នកទទួលសន្តតិកម្ម[33] ប៉ុន្តែក្នុងករណីដែល ឪពុកម្ដាយរបស់មតកជនបានទទួលមរណភាពដែរ នោះសន្តតិកម្មត្រូវធ្លាក់ទៅជីដូនជីតាជាអ្នកទទួលបន្តវិញ។ យោងតាមមាត្រា ១១៥៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា បានចែងថា ប្រសិនបើបុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនមានចំនួនច្រើននាក់ បុព្វញាតិផ្ទាល់នីមួយៗត្រូវទទួលចំណែកមត៌កស្មើៗគ្នា។[34]

### ២.២.៣. សន្តតិជនលំដាប់ទី៣

ករណីដែលមតកជនមិនមានទាំងបច្ឆាញាតិផ្ទាល់ និងបុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ នោះបងប្អូនបង្កើតរបស់មតកជនត្រូវក្លាយជាសន្តតិជនវិញ។[35] ក្នុងករណីនេះ បើបងប្អូនបង្កើតមានចំនួនច្រើននាក់ នោះម្នាក់ៗទទួលបានចំណែកមត៌កស្មើៗគ្នា ប៉ុន្តែចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុក ឬម្ដាយ

[31] មាត្រា ១០២៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[32] មាត្រា ១០១៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[33] មាត្រា ១១៥៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[34] មាត្រា ១១៥៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[35] មាត្រា ១១៦០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

តែម្ខាងដូចគ្នា គឺត្រូវទទួលបានចំណែកមត៌ក ១ភាគ២ (មួយភាគពីរ) នៃចំណែកមត៌ករបស់បងប្អូនដែលមានឪពុកម្តាយទាំងសងខាងដូចគ្នា។[36]

### ២.២.៤. សន្តតិជនជំនួស

នៅក្នុងចំណុចនេះផងដែរនឹងធ្វើការបកស្រាយអំពីក្នុងករណីដែលកូនរបស់មតកជនបានទទួលមរណភាព ដែលជាហេតុធ្វើឲ្យកូនរបស់មតកជននោះមិនអាចទទួលនូវមត៌កបាន ឬមិនអាចក្លាយជាសន្តតិជនបាន តើអ្នកណាជាអ្នកត្រូវក្លាយជាសន្តតិជនជំនួស? បើកូនរបស់មតកជនដែលនឹងត្រូវក្លាយជាសន្តតិជន តែបានទទួលមរណភាពនៅមុនពេលចាប់ផ្តើមសន្តតិកម្ម។ ដូចនេះកូនរបស់បុគ្គលនោះត្រូវក្លាយជាសន្តតិជនជំនួសបន្តវិញ ពោលគឺសំដៅទៅលើចៅដែលត្រូវក្លាយជាសន្តតិជនជំនួស។ ដូចគ្នាជាមួយនឹងករណី ដែលកូនរបស់មតកជនបានបាត់បង់នូវសិទ្ធិសន្តតិកម្ម ដោយបានបំពេញតាមលក្ខខ័ណ្ឌកំណត់ក្នុងបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) ឬដោយការផ្តាច់មត៌កនេះដែរ។[37] លើសពីនេះទៅទៀត សន្តតិកម្មជំនួសត្រូវយកអនុវត្តជាបន្តបន្ទាប់ ចំពោះករណីដែលមានមូលហេតុដូចខាងលើនេះ[38] ក៏ប៉ុន្តែ សន្តតិកម្មជំនួសនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះបុគ្គលដែលមិនមែនជាបច្ឆាញាតិផ្ទាល់របស់មតកជន។[39] ឧទាហរណ៍ ក្នុងករណីដែលកូនរបស់មតកជនបានទទួលមរណភាពមុនពេលចាប់ផ្តើមសន្តតិកម្ម ចៅរបស់មតកជនជាអ្នកទទួលសន្តតិកម្មជំនួស ហើយបើចៅនោះបានទទួលមរណភាពទៀត នោះចៅទួតនឹងត្រូវទទួលសន្តតិកម្មជំនួសបន្តដែលមានន័យសំដៅលើអាចអនុវត្តបានចំពោះតែសន្តតិជនដែលជាកូនរបស់មតកជនប៉ុណ្ណោះ។

### ២.២.៥. សន្តតិជនជាជនជាតិបរទេស

ជនបរទេសត្រូវបានហាមឃាត់ ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលជាច្បាប់កំពូល ថាមិនអាចក្លាយជាម្ចាស់សិទ្ធិករលើដីធ្លីនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានឡើយ។[40] ដូចច្នេះ ជនបរទេសក៏ត្រូវបានកម្រិតនូវសិទ្ធិសន្តតិកម្មលើរឿងដីធ្លីដូចគ្នាដែរ។ យោងតាមមាត្រា ១១៥៥ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា បានចែងបញ្ជាក់អំពី ការហាមឃាត់ជនបរទេសក្នុងការទទួលយកជាម្ចាស់កម្មសិទ្ធិលើដីធ្លីតាមសន្តតិកម្ម ឬអច្ច័យទាន។[41]

---

[36] មាត្រា ១១៦០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[37] មាត្រា ១១៥៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[38] មាត្រា ១១៥៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[39] មាត្រា ១១៥៧ កថាខណ្ឌទី១ វាក្យខ័ណ្ឌទី២ នៃឆ្នាំ ២០០៧។

[40] មាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា។

[41] មាត្រា ១១៥៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

ទោះបីជាយ៉ាងណាក្តី ក្នុងករណីដែលសន្តតិជនមានច្រើននាក់ ឬសហសន្តតិជនទាំងអស់ពុំមានសញ្ជាតិជាខ្មែរទេនោះ ក៏នៅតែអាចទទួលមត៌ក និងធ្វើការបែងចែកនោះបានដដែរ ក៏ប៉ុន្តែត្រូវប្តូរពីដីធ្លីទៅជាប្រាក់វិញ ដោយហេតុថា សន្តតិជនមិនអាចមានកម្មសិទ្ធិលើដីធ្លី នាំឲ្យសន្តតិជនក៏មិនអាចចាត់ចែងបានដូចគ្នា។ ហេតុនេះ ត្រូវចាត់ទុកដីធ្លីដែលជាមត៌កនោះត្រូវស្ថិតក្រោមជាកម្មសិទ្ធិនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរវិញ។

យ៉ាងណាមិញ ទោះបីជាស្ថិតនៅក្រោមនីតិបុគ្គលក៏ដោយ ក៏មានល័ក្ខខ័ណ្ឌបន្ថែមពីលើនេះដើម្បីកម្រិតផងដែរ ព្រោះថាការដែលស្ថិតក្រោមកម្មសិទ្ធិនីតិបុគ្គលដែលមិនមានពេលកំណត់ ក៏មិនមែនជាការត្រឹមត្រូវឡើយ។ ដោយក្នុងអំឡុងពេល ៣ (បី)ខែ គិតចាប់ពីពេលដែលសន្តតិជន ឬសហសន្តតិជនទាំងអស់បានយល់ព្រម ឬបានយល់ព្រមដោយមានកម្រិតនោះ បានចាត់ចែងលើដីធ្លី។ ដូចនេះថ្លៃលក់ដីដែលលក់បាន ត្រូវក្លាយជាមត៌ក ហើយកម្មសិទ្ធិនីតិបុគ្គលនោះក៏ត្រូវបានរលត់ដែរ។ ក្នុងករណីលើសពី ៣(បី) ខែ មិនមានការចាត់ចែងទេ កម្មសិទ្ធិលើដីធ្លីនោះនឹងត្រូវបានធ្វើសន្តតិកម្មដោយសន្តតិជនដែលមានលំដាប់ក្រោយបន្ទាប់ទៀតដែលមានសញ្ជាតិជាខ្មែរ។

### ២.៣. សន្តតិកម្មតាមមតកសាសន៍

មតកសាសន៍ មានន័យថាជាលិខិតបណ្តាំដែលបុគ្គលម្នាក់បានធ្វើឡើងតាមទម្រង់ដែលកំណត់ដោយច្បាប់ ដើម្បីសំដែងឆន្ទៈចុងក្រោយអំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍ បន្ទាប់ពីមរណភាព។[42] ដូចនេះសន្តតិកម្មតាមមតកសាសន៍សំដៅទៅលើការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឲ្យសន្តតិជនតាមរយៈលិខិតបណ្តាំដោយធ្វើតាមទម្រង់នៃច្បាប់បានកំណត់ ដែលនេះមិនមែនបានន័យថាច្បាប់ជាអ្នកកំណត់នូវឆន្ទៈនោះទេ ពោលគឺសន្តតិកម្មនោះធ្វើឡើងតាមឆន្ទៈពិតប្រាកដរបស់មតកជនដោយមិនមានការបង្ខិតបង្ខំ និងគោរពទៅតាមទម្រង់នៃមតកសាសន៍។

#### ២.៣.១. សមត្ថភាពក្នុងការធ្វើមតកសាសន៍

ការធ្វើមតកសាសន៍ មិនមែនបុគ្គលគ្រប់រូបសុទ្ធតែអាចធ្វើមតកសាសន៍បាននោះទេ។ ការធ្វើមតកសាសន៍ ឬបណ្តាំគឺអាចធ្វើឡើងលុះត្រាតែបុគ្គលនោះជាបុគ្គលម្នាក់ដែលច្បាប់ទទួលស្គាល់។ ដោយផ្អែកលើមាត្រា ១១៦៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា បានចែងថា បុគ្គលដែលជានីតិជន និងអនីតិជនដែលទទួលបានអត្តាធីនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬអំណាចមេបា អាចធ្វើ

[42] សន្ធានុក្រមផ្នែករដ្ឋប្បវេណីនៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

មតកសាសន៍បាន។ ពាក្យនីតិជន មានន័យថាជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ។[43] រីឯពាក្យអនីតិជន ដែលទទួលបាននូវអត្តាធីនភាព សំដៅទៅលើជនដែលមិនទាន់គ្រប់អាយុតាមច្បាប់កំណត់ ឬជនដែលមានអាយុក្រោម១៨ឆ្នាំ ប៉ុន្តែស្ថិតក្នុងស្ថានភាពមួយដែលផ្តល់ឲ្យអនីតិជនបានរួចផុត ពីអាណាព្យាបាលសម្រាប់អនីតិជន ឬរួចផុតពីអំណាចមេបាហើយមានសមត្ថភាពដូចនីតិជនដែរ។[44] លក្ខណៈបុគ្គលទាំងពីរនេះ សុទ្ធតែច្បាប់បានទទួលស្គាល់ពេញលេញ ហេតុនេះហើយទើបមានសមត្ថភាពក្នុងការធ្វើមតកសាសន៍បាន។

ផ្ទុយទៅវិញ ប្រសិនបើបុគ្គលនោះជានីតិជនហើយ ប៉ុន្តែស្មារតីផ្នែកការយល់ដឹងរបស់គាត់បែរជាអសមត្ថភាព បុគ្គលនោះមិនអាចធ្វើមតកសាសន៍បានទេ។ ផ្អែកតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ការអសមត្ថភាពខាងផ្នែកឆន្ទៈបែងចែកចេញជាពីររួមមាន ជននៅក្រោមហិតូបត្ថម្ភ និងជននៅក្រោមអាណាព្យាបាលទូទៅ។ ជននៅក្រោមអាណាព្យាបាលទូទៅ គឺជាជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យ ដោយសារតែមានវិបត្តិផ្នែកបញ្ញាស្មារតី។[45] រីឯ ជននៅក្រោមហិតូបត្ថម្ភ គឺជាជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី។[46]

### ២.៣.២. អានុភាពនៃមតកសាសន៍

មតកសាសន៍ មានអានុភាពចាប់ពីពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព។[47] ប៉ុន្តែក្នុងករណីដែលម្ចាស់បណ្តាំមានដាក់នូវល័ក្ខខ័ណ្ឌណាមួយនៅក្នុងលិខិតបណ្តាំ ហេតុនេះមតកសាសន៍នឹងមានអានុភាពនៅក្រោយពេលដែលសន្តតិជនបានបំពេញនូវល័ក្ខខ័ណ្ឌរបស់មតកជនបានរួចរាល់។ ដោយយោងតាមមាត្រា ១១៩៤ កថាខណ្ឌទី២នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាបានចែងថា នៅក្នុងករណីដែលមតកសាសន៍ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ បើល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញនៅក្រោយពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព មតកសាសន៍នោះត្រូវមានអានុភាព ចាប់ពីពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ។

ជាមួយគ្នានេះដែរ ប្រសិនបើមតកជនបានធ្វើការបែងចែកចំណែកមត៌កទុកជាមុន តាំងពីពេលគាត់នៅរស់ដោយធ្វើការផ្ទេរកម្មសិទ្ធិនូវទ្រព្យសម្បត្តិមួយ ឬច្រើនទៅឲ្យសន្តតិជនតែម្នាក់ឬច្រើននាក់ នៅពេលម្ចាស់

[43] សន្ធានុក្រមផ្នែករដ្ឋប្បវេណីនៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[44] មាត្រា ២១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[45] មាត្រា ២៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[46] មាត្រា ២៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[47] មាត្រា ១១៩៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

បណ្តាំបានទទួលមរណភាព នោះទ្រព្យសម្បត្តិជាក់លាក់នោះនឹងត្រូវធ្លាក់ទៅលើសន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះដោយស្វ័យប្រវត្តិ។[48]

លើសពីនេះទៅទៀត ក្នុងករណីដែលម្ចាស់បណ្តាំបានធ្វើការកំណត់បែងចែកនូវចំណែកមត៌កទៅកាន់សន្តតិជនណាមួយដែលមាននៅក្នុងលិខិតបណ្តាំ ហើយជនដែលជាសន្តតិជននោះបានទទួលមរណភាព នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬជនដែលជាសន្តតិជនត្រូវបានក្លាយជាអភ័ព្វបុគ្គល ដែលការកំណត់បែងចែកមត៌កនឹងត្រូវធ្លាក់ទៅលើអ្នកទទួលសន្តតិកម្មជំនួសវិញ។[49] ប៉ុន្តែបើសិនជាគ្មានអ្នកទទួលសន្តតិកម្មជំនួសពីជនដែលត្រូវបានសន្មតថាជាសន្តតិជននោះទេ ការកំណត់ចំពោះជនដែលត្រូវបានសន្មតជាសន្តតិជននោះពុំត្រូវបង្កើតអានុភាពឡើយ រួមទាំងករណីដែលសន្តតិជនបានបោះបង់សន្តតិកម្ម។[50]

### ២.៣.៣. ការលុបចោលនូវមតកសាសន៍

ម្ចាស់បណ្តាំមិនអាចបោះបង់សិទ្ធិលុបចោលមតកសាសន៍បានឡើយ។[51] ប៉ុន្តែម្ចាស់បណ្តាំអាចលុបចោលនូវមតកសាសន៍មួយភាគ ឬទាំងមូលនៅពេលណាក៏បាន[52]ពោលគឺ ក្រោយពីម្ចាស់បណ្តាំបានធ្វើមតកសាសន៍រហូតដល់ពេលបានទទួលមរណភាព គឺមតកជនអាចលុបចោលនូវមតកសាសន៍របស់ខ្លួនពេលណាក៏បានដែរ។ នៅក្នុងចំណុចនេះ នឹងធ្វើការបែងចែកចេញជាពីរចំណុចបន្ថែមរួមមាន ការលុបចោលនូវមតកសាសន៍ ដោយមតកសាសន៍ (**ចំណុច ២.៣.៣.១**) និង ការលុបចោលមតកសាសន៍តាមច្បាប់កំណត់(**ចំណុច ២.៣.៣.២**)។

#### ២.៣.៣.១. ការលុបចោលនូវមតកសាសន៍ ដោយមតកសាសន៍

មតកជនអាចលុបចោលនូវមតកសាសន៍មួយភាគ ឬទាំងមូលបាន ទៅតាមទម្រង់នៃមតកសាសន៍។[53] មួយវិញទៀត ទម្រង់នៃមតកសាសន៍មានច្រើនប្រភេទរួមមាន មតកសាសន៍ដោយលិខិតយថាភូត មតកសាសន៍ដោយលិខិតឯកជន មតកសាសន៍ដោយលិខិតសម្ងាត់ មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង និងការធ្វើមតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន ដែលតាមទម្រង់ទាំងអស់នេះ គឺម្ចាស់

---

[48] មាត្រា ១១៩៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[49] មាត្រា ១១៩៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[50] មាត្រា ១១៩៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[51] មាត្រា ១១៩២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[52] មាត្រា ១១៨៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[53] មាត្រា ១១៨៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

បណ្តាំអាចធ្វើការលុបចោលនូវមតកសាសន៍របស់ខ្លួនដោយមួយភាគ ឬទាំងអស់បានទៅតាមទម្រង់ទាំងអស់នោះដែលខ្លួនបានធ្វើឡើង។

លើសពីនេះទៅទៀត យោងតាមមាត្រា ១១៨៩ កថាខណ្ឌទី២នៃព្រះរាជាណាចក្រកម្ពុជាចែងថា បើមតកសាសន៍ដែលបានធ្វើក្រោយនេះ មានភាពផ្ទុយនឹងមតកសាសន៍ដែលបានធ្វើមុន ត្រូវចាត់ទុកថា មតកសាសន៍ដែលបានធ្វើក្រោយនោះបានលុបចោលមតកសាសន៍ដែលបានធ្វើមុនចំពោះផ្នែកដែលផ្ទុយគ្នានោះ មានន័យថាក្នុងករណីដែលមតកសាសន៍ធ្វើក្រោយមានអត្ថន័យខ្លឹមសារផ្ទុយពីមតកសាសន៍ដែលធ្វើមុន នោះមតកសាសន៍ដែលធ្វើក្រោយនឹងធ្វើការលុបចោលនូវមតកសាសន៍ដែលបានធ្វើមុនចេញ លើកលែងតែផ្នែកដែលមានខ្លឹមសារអត្ថន័យដូចគ្នាប៉ុណ្ណោះ។

### ២.៣.៣.២. ការលុបចោលមតកសាសន៍តាមច្បាប់កំណត់

ម្យ៉ាងវិញទៀត ក្នុងករណីម្ចាស់បណ្តាំធ្វើការលុបចោលមតកសាសន៍ក្នុងកំឡុងពេលនៅរស់ យោងតាមមាត្រា ១១៩០ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា បើម្ចាស់បណ្តាំបានធ្វើអនុប្បទាន ឬបានធ្វើសកម្មភាពផ្សេងទៀត ចំពោះវត្ថុដែលជាកម្មវត្ថុនៃមតកសាសន៍នាពេលនៅរស់ ត្រូវចាត់ទុកថា ម្ចាស់បណ្តាំបានលុបចោលមតកសាសន៍ចំពោះផ្នែកដែលផ្ទុយនឹងអនុប្បទាន ឬសកម្មភាពផ្សេងនោះ។ ឧទាហរណ៍ នៅក្នុងមតកសាសន៍ម្ចាស់បណ្តាំបានធ្វើអច្ច័យទាននូវឡានមួយគ្រឿងជូនទៅលោក ក ប៉ុន្តែប្រសិនបើម្ចាស់បណ្តាំបានធ្វើប្រទានកម្មនូវឡាននោះទៅឲ្យលោក គ វិញនៅពេលដែលខ្លួននៅរស់ត្រូវចាត់ទុកថា សាមីខ្លួនដែលជាម្ចាស់បណ្តាំបានលុបចោលនូវផ្នែកនេះនៃមតកសាសន៍។ ចំពោះការលុបចោលមតកសាសន៍តាមរយៈការបដិសេដលិខិតមតកសាសន៍គឺ សំដៅទៅលើការបំផ្លាញមតកសាសន៍ ឬការបំផ្លាញវត្ថុដែលជាកម្មវត្ថុនៃមតកសាសន៍ដោយម្ចាស់បណ្តាំ។ តាមមាត្រា ១១៩១ វាក្យខ័ណ្ឌទីមួយនៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា បើម្ចាស់បណ្តាំបានបំផ្លាញច្បាប់ដើមនៃមតកសាសន៍ដោយចេតនា ត្រូវចាត់ទុកថា បានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលត្រូវបានបំផ្លាញនោះ។ ដូចច្នេះ ប្រសិនបើម្ចាស់បណ្តាំបានបំផ្លាញលិខិតបណ្តាំដោយចេតនានោះនឹងត្រូវចាត់ទុកថា សាមីខ្លួនបានលុបចោលមតកសាសន៍ត្រង់ផ្នែកដែលខ្លួនបានបំផ្លាញ។ ម៉្យាងទៀត ក្នុងករណីដែលម្ចាស់បណ្តាំបានបំផ្លាញកម្មវត្ថុនៃមតកសាសន៍ដោយចេតនា[54] គឺត្រូវចាត់ទុកថាសាមីខ្លួនបានលុបចោលនូវមតកសាសន៍របស់ខ្លួនដូចនឹងការលុបចោលមតកសាសន៍ ដោយការចាត់ចែងនាពេលនៅរស់ដែរ។ ប៉ុន្តែបើសិនលិខិតមតកសាសន៍ត្រូវបានបំផ្លាញដោយតតិយជន ឬប្រធានសក្តិនោះនឹងមិនមានអានុភាពនៃការលុបចោលទេ។

[54] មាត្រា ១១៩១ វាក្យខ័ណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

# ជំពូកទី២

## តួនាទីរបស់សារការីពាក់ព័ន្ធនឹងមតកសាសន៍

# ជំពូកទី២
# តួនាទីរបស់សារការីពាក់ព័ន្ធនឹងមតកសាសន៍

សារការីដើរតួយ៉ាងសំខាន់ក្នុងការប្រតិបត្តិសរសេរ ក៏ដូចជាការអន្តរាគមន៍ និងថែរក្សាមតកសាសន៍។ ការបង្កើតមតកសាសន៍អាចបង្ករ ជាភាពច្របូលច្របល់ដោយសារការកម្រិតទាមទារក្នុងការអនុវត្តនូវល័ក្ខខ័ណ្ឌដែលបានកំណត់។ ហេតុនេះ សារការីមានតួនាទីក្នុងការផ្តល់ជំនួស ឬជាការពិគ្រោះទៅដល់មតកជនសម្រាប់បញ្ហាគតិយុត្តផ្សេងៗដែលអាចបង្កឡើងនៅពេលសន្តតិកម្មចាប់ផ្តើម ប្រសិនជាមានការរំលោភសិទ្ធិ ឬក្នុងករណីដែល ម្ចាស់បណ្តាំមានបំណងកាត់ចំណែកមត៌កពីជនដែលសន្មតថាជាសន្តតិជនណាមួយ។

នៅក្នុងជំពូកនេះមានកម្មវត្ថុសិក្សាលើ តួនាទីសារការីក្នុងការតាក់តែងមតកសាសន៍ (**ផ្នែកទី ១**) និង តួនាទីសារការីក្នុងការថែរក្សា និងប្រតិបត្តិមតកសាសន៍(**ផ្នែកទី ២**)។

## ផ្នែកទី១៖ តួនាទីសារការីក្នុងការតាក់តែងមតកសាសន៍

យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជណាចក្រកម្ពុជា សន្តតិកម្មអាចធ្វើឡើងតាមច្បាប់ និង តាមលិខិតមតកសាសន៍។ ដើម្បីជាការធានានូវប្រសិទ្ធិភាព ក៏ជាការពារនូវឆន្ទៈរបស់ម្ចាស់បណ្តាំ សារការីត្រូវបានផ្តល់នូវទំនុកចិត្ត តាមរយៈការកំណត់តួនាទីក្នុងការតាក់តែង និងអន្តរាគមន៍ចំពោះរឿងពាក់ព័ន្ធនឹងសន្តតិកម្ម។ ជាក់ស្តែង ដូចបានរៀបរាប់ក្នុងចំណុច ១.១.៣ ក្នុងផ្នែកទី១ នៃជំពូកទី១ខាងលើ ទម្រង់មតកសាសន៍គឺមានលក្ខណៈតឹងរឹង ដែលតម្រូវទាមទារឱ្យមានការប្រុងប្រយ័ត្នក្នុងពេលតាក់តែង។ នៅក្នុងផ្នែកនេះ យើងនឹងធ្វើការសិក្សាលើមុខងារតួនាទីសារការីក្នុងសន្តតិកម្ម (**ចំណុច ១.១**) ប្រភេទនៃមតកសាសន៍ (**ចំណុច ១.២**) និងចំណុចនៃសន្តតិកម្មតាមច្បាប់ (**ចំណុច ១.៣**)។

### ១.១. មុខងារតួនាទីសារការីក្នុងសន្តតិកម្ម

ក្នុងការធ្វើសន្តតិកម្ម វត្តមានរបស់សារការីមានភាពចាំបាច់ណាស់ ដោយសារតែសារការីដើរតួជាអ្នកតាក់តែង ក៏ដូចជាបញ្ជាក់នូវភាពត្រឹមត្រូវរបស់មតកសាសន៍។ នៅក្រោមបណ្តាប្រទេសដែលប្រកាន់យកប្រព័ន្ធច្បាប់ស៊ីវិល បានកំណត់នូវបទបញ្ញត្តិសន្តតិកម្មស្តីអំពីការផ្តល់អាទិភាពដល់សារការីក្នុងការបំពេញនូវសន្តតិកម្ម ក៏ដូចជាផ្តល់នូវអំណាចដល់ ក្នុងការអន្តរាគមន៍ចំពោះកិច្ចមួយចំនួន ជាអាទិ៍ បទបញ្ញត្តិហ៊ីប៉ូតែក។

#### ១.១.១. ការតាក់តែងលិខិតយថាភូត និង ការធ្វើការបញ្ជាក់

តួនាទីដ៏សំខាន់របស់សារការីគឺការតាក់តែងនូវលិខិតយថាភូត ដោយករណីយកិច្ចសារការីគឺ មានការតម្រូវឱ្យមានការបំភ្លឺឱ្យដំណឹង និងផ្តល់ការពិភាក្សាពាក់ព័ន្ធនឹងលិខិតដែលម្ចាស់បណ្តាំបានធ្វើ ឬមានបំណងក្នុងការបង្កើត។ យោងតាមក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ សមត្ថកិច្ចរបស់សារការីក្នុងការបង្កើតលិខិតយថាភូត

ត្រូវបានឱ្យឃើញថា ជាអំណាចផ្តាច់មុខក្នុងការបង្កើតកិច្ចសន្យាផ្សេងៗជាអាទិ៍ កិច្ចសន្យាទិញលក់[55] កិច្ចសន្យាអនុប្បទានកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់អចលនវត្ថុ[56] ការដូរ[57] កិច្ចសន្យាបង្កើត និងប្រទានកម្ម ហ៊ីប៉ូតែក[58] និង ការបង្កើតមតកសាសន៍ដោយលិខិតយថាភូត[59]។ នៅក្នុងនីតិវិធីក្នុងការបង្កើតលិខិតយថាភូតឡើង សារការីដើរតួជាសាក្សីស្របច្បាប់ ក៏ដូចជាអ្នកដែលផ្ទៀងផ្ទាត់នូវរាល់ឯកសារពាក់ព័ន្ធ ផ្តល់ការពិគ្រោះប្រឹក្សាដោយមិនមានភាពលំអៀង តម្កល់រក្សាច្បាប់ដើមនៃលិខិតនោះផងដែរ។

សារការីគឺពុំមានសមត្ថកិច្ចទទួលលិខិតរបស់ខ្លួន បងប្អូន ញាតិពន្ធ ឬសាខាញាតិរបស់ខ្លួនឡើយ។[60] ក្នុងករណីដែលម្ចាស់បណ្តាំ ឬអតិថិជនមានបំណងចង់ឱ្យសារការីពិនិត្យ កែតម្រូវ ឬ ធ្វើការបញ្ជាក់ទៅលើកិច្ចសន្យានោះ សារការីមានសមត្ថភាពទទួលធ្វើបានដោយស្របច្បាប់។ ក្នុងការបញ្ជាក់លិខិតនានា សារការីមានសិទ្ធិក្នុង៖

- ការបញ្ជាក់នូវស្នាមមេដៃ ឬ ហត្ថលេខានៃម្ចាស់បណ្តាំ និងសាក្សី[61]
- ការបញ្ជាក់ការបកប្រែភាសាផ្លូវការ ក្នុងករណីមានលិខិតដែរ[62]
- ការបញ្ជាក់ទៅតាមផ្លូវច្បាប់ និងតាមការទាមទាររបស់ភាគី ចំពោះលិខិតគ្រប់ប្រភេទ[63]។

### ១.១.២. ការធានានូវភាពត្រឹមត្រូវនៃឆន្ទៈ

នៅក្រោមបទបញ្ញត្តិស្តីពីសន្តតិកម្ម ការបង្កើតលិខិតយថាភូតត្រូវធ្វើទៅតាមល័ក្ខខ័ណ្ឌដែលបានកំណត់ ហើយការកំណត់នោះត្រូវអនុវត្តយ៉ាងតឹងរឹង ដោយគេកំណត់អំពីល័ក្ខខ័ណ្ឌនៃលិខិត ទម្រង់នៃលិខិត លក្ខណៈសម្បត្តិសាក្សី តម្រូវការបន្ថែម ឬ ល័ក្ខខ័ណ្ឌបន្ថែមសម្រាប់អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិតូបត្ថម្ភ ឬ ជនពិការ។ ការការពារនូវភាពត្រឹមត្រូវនៃឆន្ទៈពិតមានសារៈសំខាន់ក្នុងសន្តតិកម្ម ដោយមានភាពខុសគ្នារវាងកិច្ចសន្យាដទៃដែលគូភាគីអាចមានឱកាសក្នុងការបដិសេធ ឬ ធ្វើការការពារនូវឆន្ទៈ

[55] មាត្រា ៥១៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[56] មាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[57] មាត្រា ៥៦៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[58] មាត្រា ៨៤៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[59] មាត្រា ១១៧៣ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[60] មាត្រា ១០ នៃព្រះរាជក្រមលេខ ៩១០ ន.ស។

[61] មាត្រា ១១ នៃព្រះរាជក្រមលេខ ៩១០ ន.ស។

[62] មាត្រា ១២ នៃព្រះរាជក្រមលេខ ៩១០ ន.ស។

[63] មាត្រា ១៥ នៃព្រះរាជក្រមលេខ ៩១០ ន.ស។

ខ្លួន ចំណែកឯក្នុងបញ្ញត្តិសន្តតិកម្ម ម្ចាស់បណ្តាំពុំអាចមកធ្វើការការពារ ឬ បដិសេធឡើយនៅពេលដែលសន្តតិកម្មចាប់ផ្តើម។

មតកសាសន៍ដែលតាក់តែងឡើងក្រោមទម្រង់លិខិតយថាភូត គឺត្រូវបានគេផ្តល់ការជឿទំនុកចិត្តខ្ពស់លើឆន្ទៈដែលបានបង្ហាញតាមការចែងកំណត់ក្នុងលិខិតនោះ។ ប្រសិនបើយើងធ្វើការសង្កេតមើលលើក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១២១៣ ចែងថា ចំពោះមតកសាសន៍ដែលធ្វើដោយលិខិតយថាភូត គឺពុំបាច់ធ្វើការបញ្ជូនមតកសាសន៍ទៅតុលាការ ក្រោយពេលដែលសន្តតិកម្មត្រូវបានចាប់ផ្តើម[64] ដោយនេះបានបង្ហាញឱ្យឃើញនូវអានុភាព និងចរិកពេញលក្ខណៈតាមផ្លូវច្បាប់ដែលត្រូវបានទទួលស្គាល់។ យោងតាមបទបញ្ញត្តិស្តីពី ទម្រង់នៃមតកសាសន៍ បានចែងថា ម្ចាស់បណ្តាំត្រូវធ្វើមតកសាសន៍ដោយលិខិតយថាភូត នៅចំពោះមុខសារការីតាមទម្រង់កំណត់[65] ឬ ម្ចាស់បណ្តាំអាចធ្វើឡើងដោយលិខិតសម្ងាត់[66] ដើម្បីជាការធានាដល់ម្ចាស់បណ្តាំ មិនឱ្យមានការបង្ខិតបង្ខំ ឬ លេចធ្លោយមុននីតិវិធីបញ្ជាក់តុលាការ។

### ១.១.៣. ការការពារ និងសុវត្ថិភាពនៃមតកសាសន៍

ក្រៅពីការធានានូវឆន្ទៈរបស់ម្ចាស់បណ្តាំនៃមតកសាសន៍ សារការីក៏ធានាបាននូវសុវត្ថិភាពនៃលិខិតមតកសាសន៍ តាមរយៈការអន្តរាគមន៍ក្នុងការតម្កល់ទុកនូវលិខិតនៅមន្ទីរសារការី ដោយស្របតាមអនុក្រឹត្យស្តីពីការបង្កើតមន្ទីរសារការី របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា[67] និង លិខិតបទដ្ឋានពាក់ព័ន្ធផ្សេងៗ។ យោងតាមមាត្រា ៤ នៃអនុក្រឹត្យនោះ បានកំណត់ឱ្យមន្ទីរសារការីមានភារៈកិច្ច និងតួនាទីតម្រូវតាមច្បាប់ក្នុងការទទួលតម្កល់ និងរក្សាទុកច្បាប់ដើមនៃកិច្ចសន្យា លិខិតឯកតោភាគីផ្សេងៗ មតកសាសន៍ និង លិខិតស្នាមគ្រប់ប្រភេទ។ ការទទួលរក្សាទុក និងតម្កល់នេះគឺកំណត់ឡើង ដើម្បីធានាបានចំពោះការក្លែងបន្លំ ការបាត់បង់ ការកែប្រែ ឬ បំផ្លាញចោល។

### ១.១.៤. ភាពឆាប់រហ័សក្នុងការប្រតិបត្តិនៃការបែងចែកមត៌ក

ការបែងចែកទ្រព្យសម្បត្តិដែលធ្វើឡើងដោយលិខិតមតកសាសន៍ គឺបានជួយកាត់បន្ថយពេលវេលាដែលសន្តតិជន និងអច្ច័យលាភីត្រូវចំណាយតាមផ្លូវនីតិវិធីតុលាការ ជាក់ស្តែង នៅក្នុងការធ្វើសន្តតិកម្មទៅតាមមតកសាសន៍ពុំមានតម្រូវការក្នុងការរងចាំ ដោយត្រូវមានការឆ្លងកាត់ការដាក់ពាក្យ ការពិនិត្យ ការកោះហៅ ឬ

[64] មាត្រា ១២១៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[65] មាត្រា ១១៧៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[66] មាត្រា ១១៧៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[67] ការដាក់តម្កល់មតកសាសន៍ ពុំទាន់មានការកំណត់នៅក្នុងក្រមរដ្ឋប្បវេណីនៅឡើយ ប៉ុន្តែបានឱ្យឃើញថា មានការកំណត់អោយមន្ទីរសារការីនីមួយៗ មានតួនាទីភារៈកិច្ចក្នុងការតម្កល់ យោងតាមមាត្រា ៤ នៃអនុក្រឹត្យស្តីពីការបង្កើតមន្ទីរសារការី។

ការទាញហេតុផលផ្ទាល់មាត់ ក៏ដូចជាការរងចាំដីការសម្រេចបញ្ជាក់ចូលជាស្ថាពរឡើយ។ ដោយសារ តម្លៃ និង ការផ្តល់នូវទំនុកចិត្តខ្ពស់ក្នុងការថែរក្សាសុវត្ថិភាព និងការការពារនូវឆន្ទៈ ក្រោមការអន្តរាគមន៍នៃសារការីក្នុងការ បង្កើតឡើងនូវលិខិតមតកសាសន៍នីមួយៗ ទើបនោះបង្ករជាភាពងាយស្រួលក្នុងការប្រតិបត្តិនៃការបែងចែក មត៌ក មានភាពឆាប់រហ័ស និង រលូន។

**១.១.៥. ការបង្ការវិវាទ**

ក្នុងចំណោមផលវិបាកនៃការចែកមត៌កដែលមិនមានតាមមតកសាសន៍ គឺវិវាទដែលបង្ករឡើងដោយ ការចង់បាន ឬ ផលប្រយោជន៍បុគ្គលផ្សេងៗ ហើយនោះក៏ជាមូលហេតុដែលបង្កឱ្យមានការបង្កើតឡើងនូវតួនាទី សារការីក្នុងបញ្ញត្តិសន្តតិកម្មផងដែរ។ ជាភាពទំនុកបំរុង ជៀសវាងពីវិវាទដែលអាចកើតមាន សារការីគឺមាន តួនាទីក្នុងការផ្តល់ប្រឹក្សាយោបល់ ចំពោះការបែងចែកមត៌ក ការប្រតិបត្តិមតកសាសន៍ ការតាក់តែងទៅតាមឆន្ទៈ ដោយមានភាពច្បាស់លាស់ និងត្រឹមត្រូវ ការបង្ការមិនឱ្យមានភាពបំពានភាគបម្រុង និងតួនាទីសំខាន់ៗផ្សេង ទៀតក្នុងការពិភាក្សាបែងចែករវាងចំណោមសន្តតិជន។

**១.២. ប្រភេទនៃមតកសាសន៍**

ទម្រង់មតកសាសន៍មានច្រើនទម្រង់ ដែលមតកជនអាចធ្វើការជ្រើសយកដើម្បីធ្វើការបង្កើតជាបណ្តាំ របស់ខ្លួន។ យ៉ាងណាមិញ មតកសាសន៍ពុំអាចបង្កើតបានឡើយ ប្រសិនជាគ្មានការផ្អែកតាមទម្រង់ដែល កំណត់ដោយច្បាប់ ហេតុនេះទើប ការបំពេញនូវល័ក្ខខ័ណ្ឌទម្រង់ គឺមានភាពចាំបាច់បំផុត។[68] ហេតុដូចនេះ យើងអាចកំណត់ប្រភេទនៃទម្រង់មតកសាសន៍ដូចជា មតកសាសន៍ដោយលិខិតយថាភូត (**ចំណុច ១.២.១**) មតកសាសន៍ដោយលិខិតឯកជន (**ចំណុច ១.២.២**) មតកសាសន៍ដោយលិខិតសម្ងាត់ (**ចំណុច ១.២.៣**) មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ (**ចំណុច ១.២.៤**) ការធ្វើមតកសាសន៍នៃបុគ្គលដែលមិន អាចនិយាយបាន (**ចំណុច ១.២.៥**)។

**១.២.១. មតកសាសន៍ដោយលិខិតយថាភូត**

ការធ្វើមតកសាសន៍តាមលិខិតយថាភូត ចាំបាច់ត្រូវមានការធ្វើឡើងដោយម្ចាស់បណ្តាំ និងមានការ ទាមទារនូវវត្តមានរបស់សារការី។[69] ការតាក់តែងមតកសាសន៍តាមលិខិតយថាភូត គឺគប្បីធ្វើឡើងនៅមន្ទីរ សារការី ឬ ការិយាល័យមន្រ្តីទទួលបន្ទុកកិច្ចការសារការី ដោយយោងទៅតាម ក្រមសីលធម៌ និងវិធានរៀបចំ សម្រាប់សារការី នៃសហភាពសារការីឡាតាំងអន្តរជាតិ និង ច្បាប់ស្តីអំពីក្រមសីលធម៌សារការី នៃក្រុមប្រឹក្សានៃ សហភាពអឺរ៉ុប បានចែងថា សារការីពុំអនុញ្ញាតឱ្យបំពេញការងារ ក្រៅមន្ទីរសារការីឡើយ ការបំពេញការងារ

[68] មាត្រា ១១៧០ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[69] មាត្រា ១១៧៣ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

របស់សារការី ត្រូវអនុវត្តនៅមន្ទីរសារការី សារការីត្រូវបានអនុញ្ញាតឱ្យបំពេញការងារក្រៅមន្ទីរ ក្នុងករណីដែលលើកលែងដោយច្បាប់។[70]

### ១.២.១.១. ការចូលរួម និងវត្តមានបុគ្គលពាក់ព័ន្ធ

នៅក្នុងមាត្រា ១១៧៣ កថាខណ្ឌទី ២ បានចែងអំពីបទបញ្ញត្តិនីតិវិធីជាក់ស្តែងក្នុងការបង្កើតមតកសាសន៍តាមលិខិតយថាភូត ដោយទាមទារឱ្យមានការចូលរួមជាដាច់ខាតពី (១) ម្ចាស់បណ្តាំ និង (២) សាក្សីយ៉ាងតិច ពីរនាក់។[71] បុគ្គលពាក់ព័ន្ធគឺ ត្រូវមានវត្តមាននៅមន្ទីរសារការី តាមកាលបរិច្ឆេទនៃការចូលរួម ដែលត្រូវបានកំណត់ដោយសារការី។ ល័ក្ខខ័ណ្ឌនៃវត្តមាននេះ គឺអនុញ្ញាតអោយមានការចូលរួមពីបុគ្គលដែលពាក់ព័ន្ធ ឬ បុគ្គលដែលត្រូវបានស្នើសុំដោយម្ចាស់បណ្តាំអោយមានវត្តមានក្នុងការចូលរួមក្នុងកាលបរិច្ឆេទផងដែរ។ យ៉ាងណាមិញ បុគ្គលដែលជាសាក្សី គឺត្រូវមានលក្ខណៈសម្បត្តិត្រឹមត្រូវតាមច្បាប់ដែលបានកំណត់ ហើយក្នុងករណីមានការសង្ស័យអំពីលក្ខណៈសម្បត្តិរបស់សាក្សី សារការីមានសិទ្ធិស្នើរសុំឱ្យសាក្សីបង្ហាញ ឬ ផ្តល់ឯកសារ ឬ ភស្តុតាងបញ្ជាក់អំពីលក្ខណៈសម្បត្តិ ដូចជា សំបុត្រកំណើត ឬ សៀវភៅគ្រួសាររបស់ខ្លួន។

### ១.២.១.២. ការតាក់តែងមតកសាសន៍

ក្នុងការតាក់តែងមតកសាសន៍ ម្ចាស់បណ្តាំត្រូវប្រាប់ខ្លឹមសារនៃមតកសាសន៍ ចំពោះសារការី ក៏ដូចជាសាក្សីដែលមានវត្តមាននៅក្នុងកាលបរិច្ឆេទ។ ជាទូទៅ ការប្រាប់នូវខ្លឹមសារនៃបណ្តាំ គឺម្ចាស់បណ្តាំអាចសរសេរព្រាងជា ភាសាសាមញ្ញ រួចសារការីនឹងធ្វើការសរសេរបញ្ចូលក្នុងលិខិតយថាភូតនោះជាភាសាដែលមានន័យតាមផ្លូវច្បាប់ ម្យ៉ាងដោយហេតុជាទូទៅ ម្ចាស់បណ្តាំពុំបានយល់ច្បាស់នូវខ្លឹមសារនៃបទបញ្ញត្តិ និងច្បាប់សន្តតិកម្ម នោះសារការីមានតួនាទីក្នុងការស្វែងយល់បន្ថែមអំពីឆន្ទៈ និងសាកសួរអំពីឆន្ទៈពិតប្រាកដនៃម្ចាស់បណ្តាំ។ ការសរសេរនូវអត្ថន័យនៃមតកសាសន៍ ទាមទារឱ្យសារការីសរសេរឡើងជាលាយលក្ខណ៍អក្សរ ហើយសារការីត្រូវសូត្រអោយម្ចាស់បណ្តាំ និងសាក្សីស្តាប់។[72]

---

[70] ក្រមសីលធម៌ និង វិធានរៀបចំសម្រាប់សារការី របស់សហភាពសារការីឡាតាំងអន្តរជាតិ, មាត្រា ២៨។ កថាខណ្ឌទី ៣ មានចែងជាភាសាអង់គ្លេសដូចតទៅ៖

> [...] The activity of notaries shall be exercised at a notarial office (or Practice)
> Excluding those cases when the need for a public service makes it necessary, owing to distance and in accordance with notarial competence, secondary offices shall not be authorized. [...]

សូមមើលបន្ថែម ក្រមសីលធម៌សារការី របស់សហភាពអឺរ៉ុប, មាត្រា ២៣។ កថាខណ្ឌទី ៦ មានចែងជាភាសាអង់គ្លេសដូចតទៅ៖

> [...] A notary is not allowed to perform his/her activity and receive clients outside the notary office, except in cases prescribed by law. [...]

[71] មាត្រា ១១៧៣ កថាខណ្ឌទី ២ ចំណុច ខ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[72] មាត្រា ១១៧៣ កថាខណ្ឌទី ២ ចំណុច គ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧។

បន្ទាប់ពីស្តាប់នូវអត្ថន័យបណ្តាំរួច ម្ចាស់បណ្តាំ និង សាក្សីមានសិទ្ធិក្នុងការពិនិត្យមើលនូវខ្លឹមសារនៃកំណត់ត្រាជាលាយលក្ខណ៍អក្សរនោះ ប៉ុន្តែក្នុងករណីដែលម្ចាស់បណ្តាំ ឬ សាក្សីជាមនុស្សមិនអាចនិយាយបាន ឬ ស្តាប់មិនឮ នោះសារការីត្រូវទាមទារអោយមានទម្រង់បន្ថែម ដូចបានចែងក្នុងមាត្រា ១១៧៩ ដែលនឹងត្រូវបកស្រាយក្នុងចំណុច ១.១.២.៣ នៃផ្នែកនេះ។

### ១.២.១.៣. ការបញ្ជាក់ភាពត្រឹមត្រូវនៃលិខិត

ក្រោយពិនិត្យអត្ថន័យនៃបណ្តាំរួច ម្ចាស់បណ្តាំ និង សាក្សីត្រូវទទួលស្គាល់ថាលិខិតយថាភូតនោះគឺត្រឹមត្រូវ ម្ចាស់បណ្តាំ និង សាក្សីត្រូវធ្វើអោយមានភាពច្បាស់លាស់នៅលើឯកសារ អំពីឈ្មោះ អាយុ លំនៅឋាន ហើយចុះហត្ថលេខារៀងៗខ្លួន និងជាចុងក្រោយ សារការីត្រូវសរសេរថ្ងៃខែឆ្នាំ និងចុះហត្ថលេខា។[73] គោលបំណងនៃការធ្វើអោយមានភាពច្បាស់នេះ គឺដើម្បីធ្វើការបញ្ជាក់ ក៏ដូចជាការរក្សាទុកជាឯកសារដែល ម្ចាស់បណ្តាំ និង សាក្សីបានត្រួតពិនិត្យ និង ទទួលស្គាល់ថា ការតាក់តែងមតកសាសន៍របស់សារការីគឺមានភាពត្រឹមត្រូវទៅតាមឆន្ទៈរបស់ម្ចាស់បណ្តាំ។ ប្រសិនជាក្នុងករណីដែល ម្ចាស់បណ្តាំ មិនអាចសរសេរ ឬ ចុះហត្ថលេខាបាន សារការីអាចធ្វើការសរសេរជំនួស និង ហត្ថលេខាជំនួសបាន ដោយត្រូវសរសេរបន្ថែមនូវហេតុផលនៃការសរសេរជំនួសផងដែរ។

### ១.២.២. មតកសាសន៍ដោយលិខិតឯកជន

ការធ្វើមតកសាសន៍ដោយលិខិតឯកជន គឺពុំមានការទាមទារជាលម្អិតដូចជា មតកសាសន៍ដោយលិខិតយថាភូត ឬ លិខិតផ្សេងៗឡើយ។ មតកសាសន៍តាមទម្រង់នេះ ទាមទារតែវត្តមាននៃម្ចាស់បណ្តាំប៉ុណ្ណោះ តែម្ចាស់បណ្តាំត្រូវសរសេរមតកសាសន៍ទាំងមូល ដែលបង្ហាញអំពីឆន្ទៈនៃការបែងចែក ឬ ចំណែកមត៌ក ព្រមទាំងចុះថ្ងៃខែឆ្នាំ និងហត្ថលេខាដោយផ្ទាល់[74] ដើម្បីជៀសពីភាពក្លែងបន្លំ ក៏ដូចជាបញ្ហាអំពីសុក្រឹត្យភាពនៃមតកសាសន៍។ រាល់មតកសាសន៍ដោយលិខិតឯកជនដែលត្រូវបានសរសេរជំនួសដោយអ្នកដទៃ ឬ ធ្វើការសរសេរដោយម៉ាស៊ីនដូចជា អង្គុលីលេខ ជាអាទិ៍ នឹងត្រូវបានចាត់ទុកជាមោឃៈ។[75] ល័ក្ខខ័ណ្ឌកំណត់តម្រូវអោយមានការធ្វើឡើងតាមរយៈការសរសេរដោយផ្ទាល់ដៃ គឺដើម្បីផ្តល់ភាពងាយស្រួលក្នុងការផ្ទៀងផ្ទាត់បញ្ជាក់ និងកំណត់មើលអក្សរ ប្រៀបទៅនឹងអក្សរដែលម្ចាស់បណ្តាំបានសរសេរក្នុងលិខិតផ្សេងៗ ដើម្បីបង្ហាញភាពពិតត្រឹមត្រូវនៃមតកសាសន៍របស់ម្ចាស់បណ្តាំ។

---

[73] មាត្រា ១១៧៣ កថាខណ្ឌទី ២ ចំណុច ឃ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧។

[74] មាត្រា ១១៧៤ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[75] មាត្រា ១១៧៤ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

យោងតាមមាត្រា ១១៧៤ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី បានចែងថា ការបន្ថែម ការលុប ឬការកែប្រែនៅក្នុងមតកសាសន៍ដោយលិខិតឯកជន ត្រូវមានការសរសេរបន្ថែមនូវមូលហេតុនៃការកែប្រែនោះ និងចុះហត្ថលេខាបញ្ជាក់ ប្រសិនជាគ្មានការបង្ហាញនូវកន្លែងកែប្រែ មូលហេតុ និងការចុះហត្ថលេខានោះទេ ការកែប្រែគឺមិនមានអានុភាពឡើយ។ ល័ក្ខខ័ណ្ឌនេះ គឺបង្កើតឡើងដើម្បីការពារមតកសាសន៍ ក្នុងករណីដែលតតិយជនផ្លាស់ប្តូរ ឬ កែប្រែអត្ថន័យនៃបណ្តាំ[76] ហេតុនេះទើបយើងឃើញថា ភាពចាំបាច់ក្នុងការកែប្រែនៃមតកសាសន៍តាមរយៈទម្រង់នេះ គឺម្ចាស់បណ្តាំត្រូវសរសេរបញ្ជាក់នូវការផ្លាស់ប្តូរ និងចាំបាច់ចុះហត្ថលេខា ដើម្បីបញ្ជាក់ប្រៀបធៀបនឹងលិខិតផ្សេងថា ការកែប្រែនោះគឺពិតប្រាកដ ឬ ធ្វើដោយម្ចាស់បណ្តាំមែនឬទេ។

### ១.២.៣. មតកសាសន៍ដោយលិខិតសម្ងាត់

ការតាក់តែងមតកសាសន៍ គឺមតកជនមានជម្រើសក្នុងការជ្រើសយកនូវទម្រង់ដែលខ្លួនពេញចិត្ត ក្នុងនោះផងដែរ ម្ចាស់បណ្តាំអាចជ្រើសយកមតកសាសន៍ដែលមានភាពសម្ងាត់ តាមរយៈទម្រង់មតកសាសន៍ដោយលិខិតសម្ងាត់។ មតកសាសន៍តាមរយៈលិខិតសម្ងាត់ គឺជាវិធីមតកសាសន៍មួយដែលអនុញ្ញាតឱ្យម្ចាស់បណ្តាំរក្សាឆន្ទៈ និងខ្លឹមសារនៃបណ្តាំទាំងស្រុង ក៏ដូចជាការពារកុំឱ្យមានការលុបចោល ឬ ការកែប្រែដោយតតិយជន។ កម្រិតនៃការការពារមតកសាសន៍ដោយលិខិតសម្ងាត់ គឺមានកម្រិតខ្ពស់ជាងការការពារមតកសាសន៍ដោយលិខិតឯកជន ដោយមានការចូលរួមពីសារការីជាអ្នកថែរក្សាទុក រហូតដល់ការចាប់ផ្តើមនៃសន្តតិកម្ម។

#### ១.២.៣.១. ការចូលរួម និងវត្តមានបុគ្គលពាក់ព័ន្ធ

មតកសាសន៍ដោយលិខិតសម្ងាត់ ទាមទារវត្តមានរបស់សារការីជាចំបាច់ ដូចទៅនឹងមតកសាសន៍ដោយលិខិតយថាភូតដែរ ប៉ុន្តែភាពខុសគ្នានៃលិខិតនេះ គឺការសរសេរលិខិតបណ្តាំពុំចាំបាច់មានជំនួយពីសារការីឡើយ។ វត្តមាននៃសារការីក្នុងទម្រង់មតកសាសន៍នេះ គឺគ្រាន់តែជាអ្នកធានាការថែរក្សា និងការពារមិនឱ្យមានការបើកមតកសាសន៍តែប៉ុណ្ណោះ។

នៅក្នុងនីតិវិធីនៃការធ្វើមតកសាសន៍តាមទម្រង់នេះ តម្រូវឱ្យមានវត្តមានរបស់ម្ចាស់បណ្តាំ សារការីម្នាក់ និង សាក្សីយ៉ាងតិចចំនួនពីរនាក់ ដូចទៅនឹងមតកសាសន៍ដោយលិខិតយថាភូតដែរ[77]។ ដោយចំណុចសំខាន់នៃការធ្វើបណ្តាំតាមទម្រង់នេះ គឺធ្វើឡើងក្នុងគោលបំណងជាសម្ងាត់ ហេតុនេះ សាក្សីដែលចូលរួម ត្រូវទទួលបានការអនុញ្ញាតពីម្ចាស់បណ្តាំ ហើយសារការី និងសាក្សីពុំអាចដឹងអំពីអត្ថន័យនៃបណ្តាំបានឡើយ។

[76] មាត្រា ១១៧៤ កថាខណ្ឌទី ២ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមក្រមរដ្ឋប្បវេណី។

[77] មាត្រា ១១៧៥ ចំណុច គ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។ សូមមើលបន្ថែមនៅ **ចំណុច ១.២.១** ដែលបកស្រាយអំពីមតកសាសន៍ដោយលិខិតយថាភូតនៃផ្នែកនេះ។

#### ១.២.៣.២. ការតាក់តែងមតកសាសន៍ និង ការដាក់លិខិតចូលស្រោមសំបុត្របិទជិត

យោងតាមមាត្រា ១១៧៥ នៃក្រមរដ្ឋប្បវេណី មតកសាសន៍ដោយលិខិតសម្ងាត់ ត្រូវធ្វើឡើងដោយម្ចាស់បណ្ដាំធ្វើការចុះហត្ថលេខាលើលិខិត រួចដាក់លិខិតនៅក្នុងស្រោមបិទជិត ហើយធ្វើការចុះហត្ថលេខា ឬសរសេរសម្គាល់ ឬ តាមមធ្យោបាយផ្សេងនៅលើមាត់ស្រោមលិខិត ដែលអាចឱ្យវិនិច្ឆ័យបានអំពីការបានបើក ឬ មិនបានបើកនៃស្រោមលិខិត។[78] នៅក្នុងទម្រង់មតកសាសន៍នេះ យើងអាចឃើញថា ពុំមានច្បាប់កំណត់តម្រូវឱ្យម្ចាស់បណ្ដាំសរសេរដោយផ្ទាល់ដៃដូចជាមតកសាសន៍ដោយលិខិតឯកជនឡើយ នេះបង្ហាញថា ម្ចាស់បណ្ដាំមានសិទ្ធិក្នុងការសរសេរបណ្ដាំតាមរយៈឧបករណ៍ជំនួយ ជាអាទិ៍ កុំព្យូទ័របាន។

ក្រោយពីការលិខិតចូលស្រោមបិទជិតរួច ម្ចាស់បណ្ដាំត្រូវដាក់លិខិតបិទជិតនោះ នៅចំពោះសារការី និង សាក្សីដែលមានវត្តមាន ហើយធ្វើសេចក្ដីថ្លែងការណ៍ថា លិខិតនោះជាលិខិតមតកសាសន៍របស់ខ្លួន នៅក្នុងករណីដែលមានអ្នកសរសេរជំនួស ម្ចាស់បណ្ដាំត្រូវធ្វើសេចក្ដីថ្លែងការណ៍អំពីឈ្មោះ និងលំនៅដ្ឋាននៃជនដែលសរសេរនោះ។[79] សារការីត្រូវសរសេរកាលបរិច្ឆេទដែលម្ចាស់បណ្ដាំបានដាក់លិខិត និងសរសេរសេចក្ដីថ្លែងការណ៍នៃម្ចាស់បណ្ដាំនៅលើស្រោមបិទជិតនោះ អមនឹងហត្ថលេខារបស់សាក្សី និងម្ចាស់បណ្ដាំផងដែរ។[80]

### ១.២.៤. មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ

ជននៅក្រោមអាណាព្យាបាល គឺជាជនដែលស្ថិតក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយមានវិបត្តិផ្នែកបញ្ញាស្មារតី ហើយតុលាការបានប្រកាសចាប់ផ្ដើម។[81] ក្រោមមាត្រា ១១៦៩ នៃក្រមរដ្ឋប្បវេណីបានកំណត់ថា ការធ្វើមតកសាសន៍តម្រូវឱ្យម្ចាស់បណ្ដាំត្រូវមានសមត្ថភាព នៅពេលធ្វើមតកសាសន៍ ក៏ប៉ុន្តែក្នុងល័ក្ខខ័ណ្ឌបុគ្គលដែលមានភស្តុតាងអាចជាការអះអាងអំពីការខ្វះសមត្ថភាពរបស់ម្ចាស់បណ្ដាំ នោះមតកសាសន៍អាចកំណត់បានជាមតកសាសន៍សុពលភាពបាន។

ជាក់ស្ដែង បុគ្គលដែលខ្វះសមត្ថភាពខាងឆន្ទៈអាចជាសះស្បើយមួយរយៈ ដោយក្នុងអំឡុងពេលនោះ បុគ្គលនោះមានសមត្ថភាពអាចយល់ដឹង និងអាចធ្វើការវិនិច្ឆ័យបាន។ តាមការបកស្រាយនៃអ្នកវិទ្យាសាស្ត្របានឱ្យដឹងថា ស្ថានភាពដែលអាចជាសះស្បើយមួយរយៈ គឺកើតឡើងចំពោះជនដែលបាត់បង់ស្មារតីផ្នែកឆន្ទៈ

[78] មាត្រា ១១៧៥ ចំណុច ខ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[79] មាត្រា ១១៧៥ ចំណុច គ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[80] មាត្រា ១១៧៥ ចំណុច ឃ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[81] មាត្រា ២៤ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

ហើយមានសមត្ថភាពក្នុងការទទួលស្គាល់ឆន្ទៈរបស់ខ្លួននៅក្នុងអំឡុងពេលជាសះស្បើយមួយរយៈ[82] ឬ អាចនិយាយបានថាជាចិរវេលាដែលបុគ្គលបាត់បង់ស្មារតីផ្នែកឆន្ទៈទទួលបានសិទ្ធិ និង សមត្ថភាពស្របច្បាប់ក្នុងការចុះកិច្ចសន្យា និងធ្វើសកម្មភាពក្នុងនាមបុគ្គលនោះ[83]។ ដើម្បីធ្វើការបញ្ជាក់ និង ផ្តល់ជាទីបន្ទាល់នៃការជាសះស្បើយមួយរយៈនៃជនស្ថិតក្រោមអាណាព្យាបាលទូទៅ ចាំបាច់ត្រូវមានការបញ្ជាក់ផ្នែកវេជ្ជសាស្ត្រដែលមានឯកទេស។

យោងតាមក្រមរដ្ឋប្បវេណី កាលដែលជននៅក្រោមអាណាព្យាបាលទូទៅ មានបំណងក្នុងការតាក់តែងមតកសាសន៍ក្រោមទម្រង់ណាមួយដែលបានចែងក្នុងច្បាប់ ត្រូវមានវត្តមានវេជ្ជបណ្ឌិតយ៉ាងតិច ២ នាក់[84] ដោយវេជ្ជបណ្ឌិតត្រូវបញ្ជាក់ថា ម្ចាស់បណ្តាំពិតជាមានការជាសះស្បើយមួយរយៈពិតមែន និងមានសមត្ថភាពក្នុងការធ្វើមតកសាសន៍។ វេជ្ជបណ្ឌិតដែលមានវត្តមានត្រូវសរសេរបញ្ជាក់បន្ថែមលើលិខិតមតកសាសន៍អំពី ការជាសះស្បើយមួយរយៈពេលរបស់ម្ចាស់បណ្តាំ និងបញ្ជាក់ទៅតាមការវិនិច្ឆ័យថា ជននោះមានសមត្ថភាពក្នុងការយល់ដឹង ក៏ដូចជាអាចធ្វើការវិនិច្ឆ័យអំពីលទ្ធផលនៃសកម្មភាពខ្លួនទៅតាមផ្លូវច្បាប់ រួចចុះហត្ថលេខា ដោយបញ្ជាក់ថា ខ្លួនជាវេជ្ជបណ្ឌិតផងដែរ[85]។

ការដែលតម្រូវឱ្យមានវត្តមាននៃវេជ្ជបណ្ឌិត និងការសរសេរបញ្ជាក់អំពីស្ថានភាពរបស់ម្ចាស់បណ្តាំ ក៏ដូចជាការផ្តល់ស្នាមមេដៃ គឺកំណត់ឡើងដើម្បីបញ្ជាក់ឱ្យច្បាស់លាស់អំពីការអនុវត្តតាមនីតិវិធី។ យ៉ាងណាមិញ ក្នុងល័ក្ខខ័ណ្ឌដែលតម្រូវឱ្យមាននូវវត្តមានសាក្សីផ្សេង ជាអាទិ៍ ការធ្វើមតកសាសន៍តាមលិខិតយថាភូត ឬ ការធ្វើមតកសាសន៍តាមលិខិតសម្ងាត់ វត្តមានវេជ្ជបណ្ឌិតពុំអាចដើរតួជំនួស វត្តមានសាក្សីឡើយ។ សម្រាប់ករណីដែលជនក្រោមអាណាព្យាបាលមានបំណងធ្វើមតកសាសន៍តាមលិខិតសម្ងាត់ ឬ តាមលិខិតឯកជន នោះចាំបាច់ត្រូវមានវត្តមានរបស់វេជ្ជបណ្ឌិត ប៉ុន្តែយោងតាមមាត្រា ៩៧៣ កថាខណ្ឌទី២ នៃ ក្រមរដ្ឋប្បវេណីជប៉ុនបានកំណត់ថា វេជ្ជបណ្ឌិតដែលមានវត្តមាននៅពេលដែលធ្វើមតកសាសន៍ ត្រូវសរសេរនៅលើលិខិតមតក

---

[82] របាយការណ៍អំពីប្រវត្តិនៃការប៉ះទង្គិចក្បាល រួមមានការជាសះស្បើយមួយរយៈពេល (History of an abusive head trauma including a Lucid Interval) ដោយលោកវេជ្ជបណ្ឌិត De Leeuw M, Beuls EA, Jorens PG, Parizel PM, Jacobs W. ដោយបានលើកឡើងជាភាសាអង់គ្លេសថា៖

> A lucid interval (LI) is the period of time between regaining consciousness after a short period of unconsciousness, resulting from a head injury and deteriorating after the onset of neurologic signs and symptoms caused by that injury. [...]

[83] អត្ថបទស្រាវជ្រាវរបស់ Hammond W. A. (2003). Do lucid intervals exist? 1883, The Journal of Nervous and Mental Disease: March 2003, Vol 191, លេខ៣, ទំព័រ ១៩០។

[84] មាត្រា ១១៧៦ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[85] មាត្រា ១១៧៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

សាសន៍អំពីការដែលម្ចាស់បណ្តាំមិនស្ថិតក្រោម ស្ថានភាពអសមត្ថភាពក្នុងការវិនិច្ឆ័យនៅពេលធ្វើមតកសាសន៍ ហើយ ធ្វើការចុះហត្ថលេខា និងប្រថាប់ត្រា ចំណែកនៅក្នុងករណីការធ្វើមតកសាសន៍ដោយលិខិតសម្ងាត់ វេជ្ជបណ្ឌិតត្រូវសរសេរនៅលើស្រោមបិទជិត និងធ្វើការចុះហត្ថលេខា និងប្រថាប់ត្រា[86]។

### ១.២.៥. ការធ្វើមតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន

នៅក្នុងចំណោមទម្រង់នៃការធ្វើមតកសាសន៍ យើងបានដឹងថា ការធ្វើមតកសាសន៍តាមលិខិតយថាភូត មតកសាសន៍តាមលិខិតសម្ងាត់ ក៏ដូចជាមតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត[87] ទាមទារឱ្យម្ចាស់បណ្តាំអានអំពីខ្លឹមសារ ឬ ថ្លែងការណ៍អំពីភាពត្រឹមត្រូវនៃលិខិតមតកសាសន៍ ទៅសាក្សី ក៏ដូចជាសារការី។ ល័ក្ខខ័ណ្ឌនេះគឺ ដើម្បីបញ្ជាក់អំពីឆន្ទៈ ក៏ដូចជាការការពារនូវភាពត្រឹមត្រូវនៃបណ្តាំ ដោយចាំបាច់តម្រូវឱ្យម្ចាស់បណ្តាំមានសម្បទាផ្នែកនិយាយ និង ស្តាប់បាន។ យ៉ាងណាមិញ ដើម្បីជាការសម្របសម្រួលទៅដល់បុគ្គលដែលពុំមានសម្បទាក្នុងការ និយាយ ឬ ស្តាប់បាន ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានចែងអំពីបញ្ញត្តិសន្តិកម្ម នៅក្នុងផ្នែកទី២ ស្តីពីទម្រង់នៃមតកសាសន៍ កំណត់នូវការធ្វើមតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន ជាអាទិ៍។

ក្នុងករណីដែលបុគ្គលមិនអាចនិយាយមានបំណងក្នុងការធ្វើមតកសាសន៍តាមទម្រង់ដែលទាមទារឱ្យម្ចាស់បណ្តាំធ្វើការថ្លែងសេចក្តីអំពីខ្លឹមសារនៃមតកសាសន៍ ឬ សេចក្តីថ្លែងការណ៍ថាលិខិតនោះជាលិខិតមតកសាសន៍ពិតប្រាកដ ម្ចាស់បណ្តាំអាចជំនួសការប្រាប់អំពីឆន្ទៈរបស់ខ្លួនទៅកាន់សារការី តាមរយៈការបកប្រែភាសាសញ្ញា ឬ សរសេរដោយផ្ទាល់ដៃនៅចំពោះមុខសាក្សី និងសារការី។[88] បន្ទាប់ពីបានសរសេរជាលាយលក្ខណ៍អក្សរនូវខ្លឹមសារនៃបណ្តាំរួចរាល់ សារការីមានតួនាទីក្នុងការអានឱ្យម្ចាស់បណ្តាំ និង សាក្សីស្តាប់នូវអត្ថន័យនៃបណ្តាំ ប៉ុន្តែសម្រាប់ករណីម្ចាស់បណ្តាំ ឬ សាក្សី ជាមនុស្សថ្លង់ស្តាប់មិនបាន នោះសារការីអាចជំនួសការអានឱ្យស្តាប់បាន ដោយសារការីអាចធ្វើការប្រាប់អំពីអត្ថន័យដែលបានសរសេរ តាមរយៈការបកប្រែរបស់អ្នកបកប្រែជាភាសាសញ្ញាទៅកាន់ម្ចាស់បណ្តាំ និង សាក្សី។

[86] មាត្រា ៩៧៣ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីប្រទេសជប៉ុន បកប្រែជាភាសាអង់គ្លេស៖

> “ [...] A doctor in attendance of the making of a will shall make an entry on the will to the effect that the testator was not in a condition lacking decision-making capacity at the time of making the will, sign it, and affix his/her seal; provided that in the case of a will by sealed and notarized document, he/she shall make an entry to that effect on the sealed document, sign it, and affix his/her seal.”

[87] មាត្រា ១១៧៧ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧។

[88] មាត្រា ១១៧៩ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

## ១.៣. ចំណុចសំខាន់នៃមតកសាសន៍

### ១.៣.១. សមត្ថភាពក្នុងការធ្វើមតកសាសន៍

សន្តតិកម្មត្រូវចាប់ផ្ដើមឡើងដោយមរណភាពរបស់មតកជន ឬ បុគ្គលដែលត្រូវបានប្រកាសអំពីការបាត់ខ្លួន[89] ដោយមតកសាសន៍នោះគឺជាបណ្ដាំចុងក្រោយរបស់មតកជនកាលនៅរស់។ សន្តតិកម្មដែលត្រូវបានទទួលស្គាល់ក្រោមក្រមរដ្ឋប្បវេណី គឺធ្វើឡើងផ្អែកតាមបញ្ញត្តិនៃច្បាប់ ឬ តាមឆន្ទៈរបស់ម្ចាស់បណ្ដាំ។ ក្រោមមាត្រា ១១៦៨ កថាខណ្ឌទី ១ បានកំណត់ថា បុគ្គលដែលមានសមត្ថភាពក្នុងការធ្វើមតកសាសន៍បាន គឺជានីតិជន ឬ អនីតិជនដែលបានអត្តាធីនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន[90] ឬ អំណាចមេបា។ តែយ៉ាងណាមិញ ច្បាប់ក៏បានចែងឱ្យ ជនដែលប្រកាសចាប់ផ្ដើមអាណាព្យាបាល ឬ ហិតូបត្ថម្ភ[91] មានសិទ្ធិក្នុងការបង្កើតមតកសាសន៍ក្រោម លក្ខខ័ណ្ឌដែលមានសមត្ថភាពក្នុងការយល់ដឹង ដែលបានបកស្រាយនៅចំណុច ១.១.៤ នៃផ្នែកខាងលើ។

ជាក់ស្ដែង អនីតិជនពុំមានសិទ្ធិក្នុងការធ្វើមតកសាសន៍តាមទម្រង់ណាឡើយ ដោយអនីតិជនគឺជាជនដែលត្រូវបានកម្រិតសម្ថភាពក្នុងការបង្កើតកិច្ចសន្យា ឬ សកម្មភាពឯកតោភាគី ។ ជាទូទៅ អ្នកដែលមានអំណាចមេបា ឬ អ្នកដែលជាអាណាព្យាបាលទូទៅសម្រាប់អនីតិជន មានសិទ្ធិអំណាចក្នុងការលុបចោល ឬ ផ្ដល់សច្ចានុមតិ លើរាល់សកម្មភាពផ្សេងៗនៃអនីតិជន។ ជាក់ស្ដែង នៅក្រោមក្រមរដ្ឋប្បវេណី គឺពុំទទួលស្គាល់ការបង្កើតមតកសាសន៍របស់អនីតិជនឡើយ លុះត្រាតែអនីតិជនបានរួចផុតពីអនីតិភាពដែលចែងអំពីល័ក្ខខ័ណ្ឌនៃអត្តានីភាពសម្រាប់អនីតិជន ទើបច្បាប់ទទួលស្គាល់ និងចាត់ទុកថារាល់សកម្មភាពផ្សេងៗ រួមផ្សំសកម្មភាពគតិយុត្តគឺជាសកម្មភាពឯករាជ្យ ជាអាទិ៍ ការទទួលស្គាល់នូវការធ្វើមតកសាសន៍របស់ជននោះផងដែរ[92]។

### ១.៣.២. លក្ខណៈសម្បត្តិជាសន្តតិជន

សន្តតិជន គឺជាបុគ្គលដែលទទួលសិទ្ធិទាំងស្រុង និង ករណីយកិច្ចទាំងអស់ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជន ចាប់ពីពេលផ្ដើមនៃសន្តតិកម្ម។[93] នោះមានន័យថា សន្តតិជន គឺត្រូវទទួលនូវឋានៈបន្តរបស់មតកជនតាមរយៈការបែងចែកមត៌ក ប៉ុន្តែដើម្បីជាការបង្ការមិនឱ្យខូចប្រយោជន៍ធ្ងន់ធ្ងរ ដោយសារសន្តតិកម្មទៅដល់សន្តតិជន តាមរយៈការទទួលបន្តនូវកាតព្វកិច្ច ទើបក្រោមក្រមរដ្ឋប្បវេណីបានចែងកំណត់ អំពីរបប

[89] មាត្រា ៤៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[90] មាត្រា ២១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[91] គន្ថីទី ២ ជំពូកទី ១ ផ្នែកទី៤ កថាភាគទី ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[92] មាត្រា ២១ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[93] មាត្រា ១១៤៧ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

បោះបង់នូវសន្តតិកម្ម ឬ ការយល់ព្រមដោយកម្រិត[94]។ យ៉ាងណាមិញ សន្តតិជន ឬ អច្ច័យលាភី គឺជាបុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវមានជីវិតរស់នៅ នាពេលផ្ដើមនៃសន្តតិកម្ម ក្រៅពីបុគ្គលដែលបញ្ញត្តិចាប់ពីមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) រហូតដល់មាត្រា ១១៥២ (ការផ្ដាច់មត៌កពីសន្តតិជនដោយមតកសាសន៍) ទើបអាចទទួលសន្តតិកម្មបាន។[95]

លក្ខខណ្ឌនៃការមានជីវិតរស់នៅ ក៏ត្រូវបានប្រើប្រាស់ទៅលើបញ្ញត្តិសម្រាប់ទារកក្នុងគភ៌ផងដែរ ដោយធ្វើការកំណត់លើថិរវេលានៃការចាប់កំណើតរបស់ទារក ដើម្បីសំគាល់ថាទារកនោះមានសិទ្ធិ និងសមត្ថភាពក្នុងការទទួលមត៌កដែរឬទេ។[96] លក្ខខណ្ឌនេះក៏ជាគោលការណ៍នៃការចាប់ផ្ដើម និងការបញ្ចប់សមត្ថភាពក្នុងការទទួលសិទ្ធិផងដែរ នៅក្នុងករណីដែល មតកជន និង សន្តតិជនទទួលមរណភាពព្រមគ្នា នោះសន្តតិជនពុំបានបំពេញលក្ខណៈសម្បត្តិជាប្រធានសិទ្ធិ និង កាតព្វកិច្ច ដូច្នេះជននោះពុំមានសិទ្ធិក្នុងការទទួលទ្រព្យសម្បត្តិឡើយ។

### ១.៣.៣. ការចុះហត្ថលេខា និងផ្ដិតស្នាមមេដៃ

ក្រោយពីការធ្វើមតកសាសន៍រួច ម្ចាស់បណ្ដាំ សារការី ឬសាក្សីគឺតម្រូវអោយមានការសរសេរកាលបរិច្ឆេទ និងចុះហត្ថលេខា។ ដោយលក្ខខណ្ឌនេះត្រូវបានឱ្យឃើញថា មានការលើកលែងចំពោះសារការី និងសាក្សី ដោយអនុញ្ញាតឱ្យធ្វើការជំនួសពីការ ចុះហត្ថលេខា ទៅជាការផ្ដិតស្នាមមេដៃបាន។[97] ប៉ុន្តែករណីនេះ គឺពុំអនុញ្ញាតចំពោះម្ចាស់បណ្ដាំឡើយ ដោយសារតែមានការចាំបាច់ត្រូវធ្វើការផ្ទៀងមើលហត្ថលេខាសាមីខ្លួនដើម្បីបញ្ជាក់អំពីភាពត្រឹមត្រូវក្នុងការធ្វើឯកសារ[98]។ យ៉ាងណាមិញ ក្នុងប្រទេសកម្ពុជាក៏បានឃើញថា មានទទួលស្គាល់ការប្រើប្រាស់ហត្ថលេខាឌីជីថល។ យោងតាមអនុក្រឹត្យលេខ ២៤៦ អនក្រ.បក បានប្រកាសអោយមានការប្រើប្រាស់ហត្ថលេខាឌីជីថល លើឯកសារអេឡិចត្រូនិច ដើម្បីជំនួសដល់ការចុះហត្ថលេខាលើលិខិតលាយលក្ខណ៍អក្សរ ដែលតម្រូវអោយមាននូវ ហត្ថលេខា ឬ ស្នាមមេដៃ។[99]

យ៉ាងណាមិញ ក្នុងការធ្វើមតកសាសន៍ដោយលិខិតឯកជនបានកំណត់យ៉ាងជាក់លាក់ថា ការតាក់តែងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដែលសរសេរដោយផ្ទាល់ដៃរបស់ម្ចាស់បណ្ដាំ ហើយមិនអាចធ្វើការ

[94] មាត្រា ១២៤៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[95] មាត្រា ១១៤៩ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[96] មាត្រា ២១ កថាខណ្ឌទី ២ និង មើលបន្ថែមក្នុង មាត្រា ៩ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[97] មាត្រា ១១៨០ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[98] មាត្រា ១៥៥ កថាខណ្ឌទី ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៧។

[99] មាត្រា ១០ នៃអនុក្រឹត្យលេខ ២៤៦ អណក្រ.បក

ជំនួសដោយការប្រើប្រាស់ម៉ាស៊ីន ជាអាទិ៍ អង្គុលីលេខបានឡើយ។ ការកំណត់ល័ក្ខខ័ណ្ឌនេះឡើង គឺដោយសារតែកម្រិតសុវត្ថិភាពនៃមតកសាសន៍តាមទម្រង់លិខិតឯកជន មានកម្រិតទាប ក្នុងការការពារពីការក្លែងបន្លំ ឬ កែប្រែនូវឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្ដាំ។ បន្ថែមពីនេះ ហត្ថលេខាឌីជីថល ក៏ត្រូវបានបដិសេធក្នុងការយកមកប្រើប្រាស់ទៅលើការចុះហត្ថលេខាលើមតកសាសន៍ផងដែរ ដែលអនុឡោមតាម ច្បាប់ពាណិជ្ជកម្មកម្ពុជាតាមប្រព័ន្ធអេឡិចត្រូនិច បានកំណត់នូវវិសាលភាពនៃការប្រើប្រាស់ហត្ថលេខាឌីជីថល តាមខ្លឹមសារដកស្រង់ដូចខាងក្រោម៖[100]

«វិសាលភាព

ច្បាប់នេះត្រូវអនុវត្តលើសកម្មភាព ឯកសារ និងប្រតិបត្តិការពាណិជ្ជកម្ម និងរដ្ឋប្បវេណីទាំងអស់ដែលធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិច លើកលែងតែសកម្មភាព ឯកសារ និងប្រតិបត្តិការទាក់ទងនឹង៖

[...] ការបង្កើតឬការចុះហត្ថលេខាលើមតកសាសន៍ លិខិតកែប្រែមតកសាសន៍ ឬបញ្ហាផ្សេងៗដែលទាក់ទិននឹងសន្តតិកម្ម។ [...]»

### ១.៣.៤. បុគ្គលដែលមិនអាចក្លាយជាសាក្សី

នៅក្នុងការធ្វើមតកសាសន៍ សាក្សីមានតួនាទីសំខាន់ក្នុងការចូលរួម។ យើងអាចឃើញថា ការធ្វើមតកសាសន៍តាមលិខិតយថាភូត ឬ ដោយលិខិតសម្ងាត់ ឬ មតកសាសន៍របស់ជនដែលកំពុងជួបគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិតសុទ្ធតែតម្រូវឱ្យមាននូវ វត្តមានរបស់សាក្សី ពុំនោះទេមតកសាសន៍នឹងមិនត្រូវបានទទួលស្គាល់ ក៏ដូចជាទទួលបានការប៉ះពាល់ដល់សុពលភាពនៃទម្រង់មតកសាសន៍។ ដោយផ្អែកទៅលើ សារៈសំខាន់របស់សាក្សីក្នុងការបំពេញការធ្វើមតកសាសន៍ ដោយទាមទារវត្តមានរបស់សាក្សី ជាដាច់ខាត។ តួនាទីសាក្សី គឺជាអ្នកដែលអាចបញ្ជាក់អំពីហេតុការណ៍ដែលកើតនាពេលធ្វើមតកសាសន៍ យោងតាមក្រមរដ្ឋប្បវេណី បានកំណត់នូវបញ្ញត្តិដែលចែងអំពី បុគ្គលដែលមិនអាចក្លាយជា សាក្សី ឬ អ្នកសង្កេតការណ៍ដូចខាងក្រោម។

#### ១.៣.៤.១. អនីតិជន ឬជនក្រោមអាណាព្យាបាល

អនីតិជន និង ជននៅក្រោមអាណាព្យាបាល គឺជាបុគ្គលដែលត្រូវបានកំណត់សមត្ថភាពក្នុងការធ្វើសកម្មភាព ហេតុដូចនេះ បុគ្គលនោះគឺពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការធ្វើជាសាក្សីឡើយ។ នៅក្នុងចំណុច ១.២.១ ខាងលើ អនីតិជនគឺ ជាបុគ្គលដែលពុំមានសិទ្ធិក្នុងការធ្វើសន្តតិកម្ម លុះត្រាតែជននោះបានរួចផុតពីអនីតិភាព ហេតុដូច្នោះ អនីតិជនក៏ពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ដើរតួជា សាក្សីដូចគ្នា។ មានន័យថា ទោះជាករណីអនីតិជនអាចមានសមត្ថភាពយល់ដឹងដោយមានកម្រិត ឬ អាចធ្វើការវិនិច្ឆ័យទៅលើ

[100] មាត្រា ៣ នៃច្បាប់ពាណិជ្ជកម្មកម្ពុជាតាមប្រព័ន្ធអេឡិចត្រូនិច។

អត្ថន័យនៃបណ្តាំក្តី ប៉ុន្តែ ប្រសិនជាអនីតិជនស្ថិតក្រោមអំណាចមេបា ឬអាណាព្យាបាលទូទៅ ឬគ្មានការយល់ព្រមពី អ្នកដែលមានសិទ្ធិអំណាចលើអនីតិជន ឬអាណាព្យាបាលទូទៅ នោះអ្នកដែលមានសិទ្ធិអំណាចលើអនីតិជន ឬអាណាព្យាបាលទូទៅ គឺមានសិទ្ធិក្នុងការលុបចោល ឬ ផ្តល់សច្ចានុមតិ លើរាល់សកម្មភាពផ្សេងៗនៃអនីតិជន[101]។ បន្ថែមពីនេះ លក្ខខណ្ឌសាក្សីក្នុងការធ្វើមតកសាសន៍ ក៏តម្រូវឱ្យមានការផ្ទៀងផ្ទាត់បញ្ជាក់អត្តសញ្ញាណ ជាអាទិ៍អត្តសញ្ញាណបណ្ណ ឬសេចក្តីចម្លងសំបុត្រកំណើត។

### ១.៣.៤.២. ជនដែលត្រូវបានសន្មតជាសន្តតិជន ឬ អច្ច័យលាភី ជាអាទិ៍

សន្តតិជនត្រូវសន្មតថាជា ជនដែលនឹងទទួលបាននូវទ្រព្យសម្បត្តិ ក្រោយសន្តតិកម្មចាប់ផ្តើម ដោយសន្តតិជនគឺត្រូវបានសំដៅចំពោះ សន្តតិជនទាំងបីថ្នាក់[102] រួមទាំងសហព័ទ្ធនៃមតកជន។ នៅក្នុងលក្ខខណ្ឌក្នុងការធ្វើមតកសាសន៍ វត្តមាននៃសាក្សីគឺសម្រាប់ធ្វើការផ្តល់សក្ខីកម្ម ដើម្បីការពារឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ។ ជាក់ស្តែង ជនដែលសន្មតជាសន្តតិជន គឺជាបុគ្គលដែលមានផលប្រយោជន៍ពាក់ព័ន្ធខ្លាំងនៅក្នុងបណ្តាំនោះបង្ហាញឱ្យឃើញថា ប្រសិនជាសន្តតិជនដើរតួជាសាក្សី ក្នុងការផ្តល់សក្ខីកម្មចំពោះអ្វីដែលបានលឺ ឬ ដឹងនោះការអះអាងអាចពុំមានភាពគួរអោយទុកចិត្តបាន។ សម្រាប់ករណីអច្ច័យលាភី ក៏លក្ខខណ្ឌនេះក៏បានអនុវត្តដោយហេតុតែអច្ច័យលាភីត្រូវទទួលបានប្រយោជន៍ពីអច្ច័យទាន។

សម្រាប់សហព័ទ្ធ ឬញាតិលោហិតនៃជនដែលសន្មតជាសន្តតិជន ក៏ពុំមានសិទ្ធិ និងខ្វះលក្ខណៈសម្បត្តិជាសាក្សី ទោះបីបុគ្គលនោះពុំមានពាក់ព័ន្ធនឹងមតកសាសន៍ក៏ដោយ។ បន្ថែមពីនេះ លក្ខខណ្ឌនេះគឺ ជាការការពារពីភាពលំអៀង ឬបាត់បង់ជំនឿទុកចិត្តលើការបំភ្លឺ ដោយសារតែទំនាក់ទំនងផលប្រយោជន៍រវាងបុគ្គលនោះ ដែលអាចបង្កបានជាការទទួលមត៌កច្រើនជាង ឬតិចជាងចំណែកមត៌កដែលបានចែងក្នុងបណ្តាំ។ ជាក់ស្តែង ក្នុងករណីបង្កើតមតកសាសន៍ដោយជនដែលកំពុងមានគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ប្រសិនជាមតកជនដាច់ដង្ហើមនៅក្នុងរង្វង់ជនដែលសន្មតថាជាសន្តតិជនច្រើននាក់ ហើយមានការអះអាងថា បណ្តាំត្រូវបានសរសេរតាមឆន្ទៈពិតប្រាកដក្តី ក៏ករណីនេះក៏ពុំមានការទទួលស្គាល់ដែរ ប៉ុន្តែសម្រាប់ករណីលើកលែង នៅពេលដែលគ្មានវត្តមានតតិយជន នោះសហសន្តតិជនអាចយកសម្តីមតកជនមកពិចារណា នៅពេលធ្វើការបែងចែកមត៌ក។

---

[101] មាត្រា ១៨ នៃក្រមរដ្ឋប្បវេណីនៃឆ្នាំ ២០០៧។

[102] សូមមើលក្នុងការបកស្រាយនៃចំណុច ២.២ នៃជំពូកទី១ ដែលបកស្រាយអំពីលំដាប់សន្តតិកម្ម។

### ១.៣.៤.៣. សហព័ទ្ធ ញាតិលោហិតខ្សែផ្ទាល់ ក្រឡាបញ្ជី ឬ និយោជិតរបស់សារការីពាក់ព័ន្ធ

តួអង្គនិង វត្តមានរបស់សារការីក្នុងការតាក់តែងមតកសាសន៍ ពិតមានសារៈសំខាន់យ៉ាងខ្លាំង។ នៅពេលដែលសារការីជាអ្នកពាក់ព័ន្ធក្នុងការធ្វើមតកសាសន៍ ចាំបាច់ត្រូវមានវត្តមានរបស់សាក្សី ក៏ដូចជាតតិយជនក្រៅពីសាក្សី ដើម្បីជាការធានាភាពសុក្រឹត្យ ប៉ុន្តែនៅក្នុងល័ក្ខខ័ណ្ឌនេះ គឺត្រូវបានកំណត់ដោយមិនអនុញ្ញាតឱ្យបុគ្គលនោះជា សហព័ទ្ធ ញាតិលោហិតខ្សែផ្ទាល់ ក្រឡាបញ្ជី ឬ និយោជិតរបស់សារការីពាក់ព័ន្ធចូលរួមបានឡើយ។ ទោះជាបុគ្គលទាំងនោះ ពុំមានទំនាក់ទំនង ឬ ទទួលបានផលប្រយោជន៍ពីសន្តតិកម្មក្តី តែដោយសារបុគ្គលអាចទទួលរងឥទ្ធិពលពីសារការី នោះជនដែលបានកំណត់ដូចខាងលើ ពុំអាចធ្វើការបំភ្លឺការពិតប្រសិនមានករណីកំហុសវិជ្ជាជីវៈរបស់សារការី ជាអាទិ៍ ការខកខានមិនបានពន្យល់អំពីអត្ថន័យ ការតាក់តែងមតកសាសន៍ផ្ទុយពីឆន្ទៈរបស់ម្ចាស់បណ្តាំ ការអនុញ្ញាតអោយមានការចូលរួមពីបុគ្គលដែលហាមឃាត់ដោយច្បាប់។ កំហុសវិជ្ជាជីវៈរបស់សារការី អាចប៉ះពាល់ដល់ផលប្រយោជន៍សន្តតិជន ឬ អច្ច័យលាភី សិទ្ធិនៃសន្តតិកម្ម នោះតម្រូវឱ្យមានការស្វែងរកការពិត ក៏ដូចជាការចាត់វិធានការទៅកាន់សារការី ជាអាទិ៍។

បន្ថែមពីនេះ យើងសង្កេតឃើញថា ពុំមានអត្ថបទច្បាប់ ឬ ការចែងអំពីសញ្ញាណនៃក្រឡាបញ្ជីសារការីឡើយ ក្រៅពីក្រមរដ្ឋប្បវេណី។ ក្រោមព្រះរាជក្រម លេខ ៩១០ នស ត្រូវបានឱ្យឃើញថា មានការប្រើប្រាស់ពាក្យក្រឡាបញ្ជីសារការី និងនៅក្រោមអនុក្រឹត្យស្តីពីការបង្កើតមន្ទីរសារការីជាទូទៅ បានកំណត់ថា “ក្នុងករណីចាំបាច់ អាចធ្វើការជ្រើសរើសសារការីដែលទទួលបានការតែងតាំងពីរាជរដ្ឋាភិបាល ឬបុគ្គលិកផ្សេងទៀតសម្រាប់ជួយបំពេញការងារ និងភារកិច្ចរបស់ខ្លួន។[103]” តែពុំមានការចែងអំពីសញ្ញាណទូទៅ ឬ ការកំណត់ច្បាស់លាស់នៃក្រឡាបញ្ជីសារការីឡើយ។

### ១.៣.៥. ការកំណត់ចំណែក និង វិធីបែងចែកមត៌ក

ជាទូទៅ ម្ចាស់បណ្តាំមានសិទ្ធិក្នុងការកំណត់នូវ ចំណែកមត៌កដែលសន្តតិជននឹងទទួលបាន ក្រោយពេលដែលសន្តតិកម្មចាប់ផ្តើម។ ការចាត់ចែងទ្រព្យសម្បត្តិតាមមតកសាសន៍នោះអាចធ្វើឡើងតាមពីរមធ្យោបាយ គឺ ការកំណត់ចំណែកមត៌ក និង ការកំណត់នូវវិធីបែងចែក។ នៅក្នុងសន្តតិកម្មតាមច្បាប់ ការកំណត់ចំណែកមត៌កត្រូវបានចែកជាភាគតាមលំដាប់នៃសន្តតិជន និងចំនួននៃសន្តតិជន ប៉ុន្តែករណីនេះ ច្បាប់ក៏ផ្តល់អានុភាពដល់ម្ចាស់បណ្តាំ ក្នុងការបង្ហាញឆន្ទៈ សម្រាប់ការកំណត់ផ្សេងពីចំណែកដែលបានចែងក្នុងច្បាប់ ឬ ធ្វើការផ្តាច់មត៌កពីសន្តតិជនដែលខ្លួនមានបំណងមិនឱ្យទទួលបាននូវសន្តតិកម្ម។

[103] អនុក្រឹត្យស្តីពីការបង្កើតមន្ទីរសារការីនីមួយៗ ដែលមានក្នុងឧបសម្ព័ន្ធ ៣។

ក្នុងការកំណត់ចំណែកតាមតកសាសន៍ មតកជនអាចធ្វើការកំណត់ចំណែកមត៌កដោយវិធីកំណត់នូវសមាមាត្រនៃទ្រព្យសម្បត្តិណាមួយ ទោះឆន្ទៈនោះផ្ទុយពីបញ្ញត្តិស្តីពីការសម្រួលចំណែកមត៌កក្តី។ នោះមានន័យថា ទោះជាការបែងចែកមត៌កឱ្យទៅសន្តតិជនណាម្នាក់ ឬច្រើននាក់ ទទួលបានផលប្រយោជន៍ពិសេស[104] ឬបង្កើតបានភាគនៃវិភាគទានក្តី[105] ក៏ការសម្រួលនៃចំណែកមត៌កមិនត្រូវបានយកមកអនុវត្តឡើយ។ តាមរយៈការកំណត់នេះ យើងអាចសង្កេតឃើញថា ក្នុងចំណោមសហសន្តតិជន មានបុគ្គលខ្លះត្រូវបានទទួលការបំពានភាគបម្រុងខ្លួន នៅក្នុងករណីមានការបំពាន សន្តតិជនដែលត្រូវបានទទួលការបំពាន អាចធ្វើការទាមទារឱ្យមានការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ដោយយោងតាមបញ្ញត្តិស្តីពីសិទ្ធិលើភាគបម្រុង ដែលនឹងត្រូវបកស្រាយនៅក្នុងចំណុច ១.៣.៨ ខាងក្រោមនៃចំនុចនេះ។ ឧទាហរណ៍ ទ្រព្យដែលត្រូវចាត់ទុកជាមត៌កមានចំនួនសរុប ៣០០,០០០ដុល្លារ ហើយសន្តតិជន **ក ខ** និង **គ** ទទួលបានមត៌កស្មើភាគគ្នា ប៉ុន្តែ សន្តតិជន **ក** បានទទួលផលប្រយោជន៍ពិសេសចំនួន ៦០,០០០ដុល្លារ រួចទៅហើយ។ មតកជនក៏បានកំណត់ចែកមត៌កឱ្យ សន្តតិជន ខ ចំនួន ១៧០,០០០ដុល្លារ និង សន្តតិជន ក ស្នងបន្ថែម ៣០,០០០ដុល្លារទៀត។ ក្នុងករណីនេះ មត៌កសរុបគឺត្រូវនឹង ៣៦០,០០០ដុល្លារ ហើយចំណែកមត៌កគឺ ៣៦០,០០០ដុល្លារ ចែកជា បីផ្នែក ស្មើនឹង ១២០,០០០ ដុល្លារ ដូច្នេះ ភាគនៃមត៌ករបស់ សន្តតិជន **ក** ត្រូវស្មើ ៩០,០០០ដុល្លារ (**ក** ទទួលបានផលប្រយោជន៍បន្ថែម ៦០,០០០ដុល្លារ រួចហើយ និងស្នងបន្ថែមចំនួន ៣០,០០០ដុល្លារ) ចំណែកឯសន្តតិជន **ខ** នឹងទទួលបាន ១៧០,០០០ដុល្លារ តាមការកំណត់ តែសន្តតិជន **គ** ទទួលបានតែទ្រព្យសល់ ក្រោយពីដកចំណែកសម្រាប់ **ក** និង **ខ** ស្មើ ១០០,០០០ដុល្លារ តែប៉ុណ្ណោះ។

ការកំណត់ចំណែកមត៌ក ពុំមានការកំណត់ច្បាស់ថាទ្រព្យណាមួយត្រូវប្រគល់អោយសន្តតិជនណាឡើយ ហេតុនេះ នៅពេលចាប់ផ្តើមសន្តតិកម្មបានរយៈពេល ១ខែ សហសន្តតិជនអាចធ្វើការចាប់ផ្តើមពិភាក្សាបែងចែកមត៌ក[106] ដែលអនុលោមតាមមាត្រា ១២៦៧។ ដើម្បីបង្ហាញឱ្យឃើញឆន្ទៈច្បាស់លាស់ក្នុងការចែកមត៌ក មតកជនគប្បីកំណត់អត្តសញ្ញាណសន្តតិជន និងទ្រព្យសម្បត្តិដែលបុគ្គលនោះនឹងត្រូវទទួលបាន ដោយការកំណត់នោះហៅថា ជាវិធីបែងចែកមត៌ក។ ម្យ៉ាងមិញទៀត ក្នុងល័ក្ខខ័ណ្ឌដែលពុំបានកំណត់វិធីបែងចែកច្បាស់លាស់ក្នុងមតកសាសន៍ សហសន្តតិជនត្រូវពិចារណាដល់ស្ថានភាពរបស់សន្តតិជននីមួយៗ ជាអាទិ៍ ប្រភេទ លក្ខណៈនៃវត្ថុ ឬ សិទ្ធិក្នុងមត៌ក ឬ អាយុ មុខរបរ ស្ថានភាពផ្លូវកាយ ផ្លូវចិត្ត និងជីវភាព។ ប្រសិនជាម្ចាស់បណ្តាំបានកំណត់ជាក់លាក់ថា ភាគដែលបានចែងគឺជាអច្ច័យទាន នោះការបែងចែកអោយដាច់រវាងការ

[104] មាត្រា ១១៦៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[105] មាត្រា ១១៦៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[106] មាត្រា ១២៦៦ ថ្មី នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

កំណត់វិធីបែងចែក និងអច្ច័យទានគឺត្រូវធ្វើឡើយដោយសារការី។ ករណីដែលម្ចាស់បណ្តាំកំណត់ថា អនុប្បទានទ្រព្យសម្បត្តិជាក់លាក់ជាអច្ច័យទាន នោះបញ្ញត្តិស្តីពីការសម្រួលមត៌កត្រូវបានអនុវត្ត ដោយការធ្វើអច្ច័យទាននោះចាត់ទុកថាជាផលប្រយោជន៍ពិសេស[107]។ ជាក់ស្តែង ការធ្វើអនុប្បទានទ្រព្យចំពោះសន្តតិជន គឺមានភាពលំបាកក្នុងការបែងចែកថា នោះជាការកំណត់នូវវិធីបែងចែកមត៌ក ឬ ជាអច្ច័យទាន ហេតុនេះការកំណត់អោយបានជាក់លាក់ គឺជាការចាំបាច់។ សម្រាប់ការកំណត់នូវវិធីបែងចែកដោយមតកសាសន៍ មតកជនត្រូវបានផ្តល់សិទ្ធិដើម្បីធ្វើការកំណត់វិធីចែកមត៌កដែលសន្តតិជនត្រូវស្នង រួមជាមួយការកំណត់ចំណែកមត៌កបាន។ នៅក្នុងបញ្ញត្តិនេះ មតកជនអាចប្រគល់អាណត្តិអោយទៅតតិយជនក្នុងការកំណត់វិធីនោះ នៅក្នុងល័ក្ខខ័ណ្ឌដែលជនសន្មតជាសន្តតិជនមិនទាន់គ្រប់អាយុជានីតិជននៅឡើយ ឬ អាចធ្វើការហាមឃាត់មិនឱ្យបែងចែកមត៌កក្នុងអំឡុងពេលដែលមិនលើសពី៥ឆ្នាំ គិតចាប់ពេលចាប់ផ្តើមសន្តតិកម្មផងដែរ[108]។

ជាទូទៅ ការបង្កើតមតកសាសន៍ គឺជាការសរសេរព្រាងទុកដែលកំណត់នូវការបែងចែកមត៌ក ឬ ការកំណត់វិធីបែងចែកមត៌កទៅតាមឆន្ទៈនៃមតកជន។ ដោយហេតុទ្រព្យដែលមតកជនទទួលបានផ្សេងទៀតក្រោយពេលដែលបង្កើតមតកសាសន៍ គឺពុំស្ថិតក្នុងវិសាលភាពនៃមតកសាសន៍ឡើយ ហេតុនេះក្រៅពីការកំណត់វិធីបែងចែកតាមរយៈការកំណត់ចំណែកមត៌កដោយគិតជាភាគនៃមត៌កទាំងស្រុង នៅក្នុងមាត្រា ១១៨៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី បានកំណត់ថា ក្នុងករណីដែលមតកជនធ្វើមតកសាសន៍ ចំពោះទ្រព្យសម្បត្តិតែមួយភាគនៅក្នុងចំណោមមត៌ក បើតម្លៃនៃទ្រព្យសម្បត្តិតិចជាងចំណែកមត៌កដែលសន្តតិជនត្រូវទទួល ត្រូវសន្មតថាបានកំណត់ត្រឹមតែវិធីបែងចែងមត៌កដែលត្រូវធ្លាក់លើសន្តតិជននោះ លើកលែងតែពុំមានការបង្ហាញឆន្ទៈផ្សេងពីនេះក្នុងមតកសាសន៍[109]។ បានសេចក្តីថា សន្តតិជនដែលទទួលបានទ្រព្យដែលមានតម្លៃតិចជាងចំណែកមត៌កតាមច្បាប់ អាចទទួលបានទ្រព្យដែលពុំស្ថិតក្នុងវិសាលភាពនៃមតកសាសន៍នោះ តាមរយៈការសម្រួលចំណែកមត៌ក លើកលែងតែមតកសាសន៍បានចែងថា សន្តតិជនទទួលបានតែទ្រព្យជាក់លាក់នោះ[110]។ ឧទាហរណ៍ តាមច្បាប់សហសន្តតិជនត្រូវទទួលបាន ១ភាគ៣ នៃអនុប្បទានតាមមតកសាសន៍ អោយសន្តតិជន **ក** ផ្ទះមួយខ្នងស្មើរនឹងតម្លៃ ២៥០,០០០ដុល្លារ សន្តតិជន **ខ** ដីមួយកន្លែងស្មើរនឹងតម្លៃ ២៥០,០០០ដុល្លារ និង សន្តតិជន **គ** ក្រុមហ៊ុនមួយស្មើរនឹងតម្លៃ ៤០០,០០០ដុល្លារ ដោយមត៌កមានតម្លៃស្មើរនឹង ៩០០,០០០ ដុល្លារ ហើយ មតកជនក៏បានបន្សល់ទុកប្រាក់ចំនួន ១០០,០០០ដុល្លារ ដែលពុំបានកំណត់អោយទៅសន្តតិជន

[107] មាត្រា ១១៦៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[108] មាត្រា ១១៨៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[109] មាត្រា ១១៨៥ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[110] មាត្រា ១១៨៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

ណាមួយឡើយ។ ដូចនេះ ក្នុងសន្តតិកម្មតាមច្បាប់ សន្តតិជននីមួយៗត្រូវទទួលបាន ៣០០,០០០ដុល្លារ តែជាក់ស្តែង សន្តតិជន **ក** និង **ខ** ទទួលបានទ្រព្យតម្លៃតិចជាងចំណែកតាមច្បាប់ចំនួន ១០០,០០០ដុល្លារ ឯសន្តតិជន គ ទទួលបានទ្រព្យច្រើនជាងចំណែកតាមច្បាប់ចំនួន ១០០,០០០ ដុល្លារ។ យោងតាមមាត្រា ១១៨២ កថាខណ្ឌទី ២ ទ្រព្យដែលជាប្រាក់របស់មតកជនបានបន្សល់ទុក ១០០,០០០ ដុល្លារ ៖ ២ ស្មើរ ៥០,០០០ដុល្លារ ហេតុនេះ សន្តតិជន **ក** និង **ខ** ទទួលមត៌កបន្ថែម ៥០,០០០ ដុល្លារ ពីមត៌កនៅសល់។ ប្រសិនជា មតកជនបានធ្វើការកំណត់ជាក់លាក់ថា សន្តតិជន **ខ** អាចទទួលត្រឹមតែផ្ទះមួយកន្លែងស្មើរនឹងតម្លៃ ២៥០,០០០ ដុល្លារ នោះប្រាក់ដែលបន្សល់ទុកត្រូវបានផ្ទេរទៅសន្តតិជន **ក** ទាំងអស់ ហើយសន្តតិជន **ខ** ពុំអាចស្នងមត៌កបន្ថែមឡើយ។

### ១.៣.៦. ការកំណត់អច្ច័យទាន

អច្ច័យទាន គឺជាប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឱ្យមនុស្សម្នាក់ ឬ ច្រើននាក់នូវទ្រព្យសម្បត្តិ ដោយមតកសាសន៍។[111] អច្ច័យទានមានពីរប្រភេទ គឺ អច្ច័យទានសកល និងអច្ច័យទានកំណត់។ ការធ្វើអច្ច័យទានមានកំណត់ គឺទ្រព្យសម្បត្តិត្រូវធ្លាក់ទៅលើអច្ច័យលាភី ព្រមជាមួយគ្នានឹងកំណើតនៃអានុភាពនៃមតកសាសន៍។ ចំណែកអច្ច័យទានសកល គឺការកំណត់ទ្រព្យតាមអត្រាភាគ ឬទ្រព្យសម្បត្តិជាមត៌កទាំងអស់ ដោយអច្ច័យលាភីសកល ទាំងអស់ចាំបាច់ពិភាក្សាគ្នាក្នុងការកំណត់នូវកម្មសិទ្ធិនៃទ្រព្យសម្បត្តិនីមួយៗ។

នៅក្នុងបញ្ញត្តិអច្ច័យទាន ពុំមានបានចែង ឬកម្រិតអំពីលក្ខណៈសម្បត្តិនៃអច្ច័យលាភីឡើយ ហេតុដូចនេះ សន្តតិជនក៏អាចក្លាយជាអច្ច័យលាភីបានដែរ។ ក្នុងករណីដែលអច្ច័យលាភីជាតតិយជនក្រៅពីសន្តតិជនបានទទួលអច្ច័យទានកំណត់ កម្មសិទ្ធិវត្ថុដែលជាកម្មវត្ថុក៏ត្រូវផ្ទេរទៅឱ្យអច្ច័យលាភី ស្របពេលដែលមតកសាសន៍បង្កើតអានុភាពដែរ។ សម្រាប់ករណីដែលអច្ច័យលាភីសកល អច្ច័យលាភីត្រូវបានចាត់ទុកថាបុគ្គលនោះមានសិទ្ធិ និងករណីយកិច្ចដូចសន្តតិជនដែរ ប៉ុន្តែក្នុងករណីដែលអច្ច័យទានសកលឱ្យមត៌កទាំងអស់ទៅកាន់តតិយជនក្រៅពីសន្តតិជន នោះសន្តតិជនចាត់ទុកថាពុំបានទទួលសន្តតិកម្មទេ លើកលែងតែសិទ្ធិលើភាគបម្រុងតែប៉ុណ្ណោះ[112]។

### ១.៣.៧. ការកំណត់អំពីសន្តតិជនជំនួស និងអច្ច័យលាភីជំនួស

ការចាប់ផ្តើមនៃសន្តតិកម្មជំនួសក្នុងសន្តតិកម្មតាមមតកសាសន៍ ត្រូវបានអនុវត្តពេលដែលសន្តតិជនទទួលមរណភាព នៅមុន ឬ ព្រមគ្នានឹងពេលចាប់ផ្តើមសន្តតិកម្ម ដូចទៅនឹងការអនុវត្តចំពោះសន្តតិកម្មតាមច្បាប់ដែរ។ តែប្រសិនជា ជនដែលបាន កំណត់ជាសន្តតិជនតាមការកំណត់នៃមតកជន ឬ តាមវិធីនៃការបែង

[111] មាត្រា ១១៩៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[112] មាត្រា ១២១២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

ចែកមត៌កដោយមតកសាសន៍ ទទួលមរណភាពមុនពេលសន្តតិកម្មចាប់ផ្តើម ឬ ត្រូវបានបាត់បង់សិទ្ធិសន្តតិកម្ម នោះជនដែលត្រូវបានកំណត់ជាសន្តតិជនជំនួសនឹងទទួលបានសិទ្ធិសន្តតិកម្ម។ ក្នុងករណីដែលគ្មានអ្នកទទួលសន្តតិកម្មជំនួសទេ នោះការកំណត់ចំពោះជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ មិនត្រូវបង្កើតអានុភាពឡើយ ហើយបញ្ញត្តិនេះក៏ត្រូវបានអនុវត្តដូចគ្នាចំពោះករណីដែលសន្តតិជនបោះបង់សន្តតិកម្មផងដែរ។ ប៉ុន្តែបើមតកជនមានឆន្ទៈផ្សេងក្នុងមតកសាសន៍ នោះបញ្ញត្តិអំពីសន្តតិជនជំនួស មិនមានអនុភាពឡើយ ដោយច្បាប់គោរពតាមឆន្ទៈរបស់ម្ចាស់បណ្តាំ។[113]

សម្រាប់ករណីដែលអច្ច័យលាភីទទួលមរណភាព មុន ឬ ព្រមគ្នានឹងពេលដែលម្ចាស់បណ្តាំទទួលមរណភាព នោះ អច្ច័យទានពុំមានអានុភាពនោះទេ ដោយបញ្ញត្តិនេះក៏ត្រូវបានអនុវត្ត ចំពោះករណីដែលអច្ច័យទានភ្ជាប់ជាមួយល័ក្ខខ័ណ្ឌបង្អង់ ឬ អច្ច័យលាភីទទួលមរណភាព មុនពេលដែលល័ក្ខខ័ណ្ឌត្រូវបានបំពេញ។ ដោយសារតែការធ្វើអច្ច័យទានគឺផ្តោតទៅលើទំនាក់ទំនងរវាង ម្ចាស់បណ្តាំ និងអច្ច័យលាភី នោះបច្ចាញាតិផ្ទាល់ របស់អច្ច័យលាភី មិនអាចទទួលអច្ច័យទានជំនួសបានឡើយ។ តែច្បាប់តែងគោរពនូវឆន្ទៈរបស់ម្ចាស់បណ្តាំ ដោយនឹងធ្វើការអនុលោមតាមឆន្ទៈរបស់ម្ចាស់បណ្តាំ ប្រសិនជាមានការបង្ហាញឆន្ទៈផ្សេងនៅក្នុងមតកសាសន៍។ ចំណែកករណីដែលជនដែលត្រូវបានសន្មតជាសន្តតិជន ជាអច្ច័យលាភី នោះអត្ថន័យនៃមតកសាសន៍ត្រូវសន្មតថាជាការកំណត់វិធីបែងចែកមត៌ក ឬ ការកំណត់នូវចំណែកមត៌ក[114]។ ប៉ុន្តែករណីជនដែលត្រូវបានសន្មតជាសន្តតិជនទទួលមរណភាព ការកំណត់សន្តតិជនជំនួសត្រូវអនុវត្តតាមល័ក្ខខ័ណ្ឌនៃសន្តតិជនជំនួស[115] ដូចខាងលើ។

### ១.៣.៨. សិទ្ធិលើភាគបម្រុង

សិទ្ធិលើភាគបម្រុង គឺជាការធានាមួយភាគនៃចំណែកមត៌កកំណត់ដោយច្បាប់ ចំពោះសន្តតិជនដែលកំណត់ដោយច្បាប់ ដោយភាគបម្រុងគឺមានតួនាទីក្នុងការផ្តល់ជា ការការពារដល់សន្តតិជនពីការរំលោភសិទ្ធិលើភាគបម្រុងរបស់ខ្លួន។ សិទ្ធិលើភាគបម្រុងពុំមានចែងក្នុងការកំណត់ចំណែក វិធីបែងចែក ឬ អច្ច័យទានក្នុងមតកសាសន៍ឡើយ ហេតុនេះ ដើម្បីធ្វើការជៀសវាងពីការប៉ះពាល់ដល់សិទ្ធិលើភាគបម្រុង ពេលដែលធ្វើការតាក់តែងមតកសាសន៍ មតកជនគប្បីពិចារណា ដោយមានការជួយពិភាក្សាពីសារការីទៅលើ៖

- តម្លៃសរុបនៃមត៌ក
- ចំនួននៃសន្តតិជន និង ចំណែកមត៌ក

[113] មាត្រា ១១៩៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[114] មាត្រា ១១៨២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[115] មាត្រា ១១៩៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

- ផលប្រយោជន៍ពិសេស
- ប្រទានកម្ម
- តម្លៃនៃអច្ច័យទាន និង បន្ទុក
- ចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលមតកជនមាន
- ការដែលសន្តតិជនបោះបង់សន្តតិកម្មមុនពេលចាប់ផ្តើមនៃសន្តតិកម្ម។

ក្រោយពីមានការជួយពិគ្រោះផ្តល់យោបល់ក្នុងការតាក់តែងមតកសាសន៍ សារការីមានកាតព្វកិច្ចក្នុងការសួរបញ្ជាក់ទៅកាន់មតកជន ក៏ដូចជាសាក្សីចូលរួមអំពីការយល់ដឹងនូវនីតិវិធីដែលបានរៀបរាប់។ ក្នុងករណីដែលមតកជន ឬសាក្សីមានចម្ងល់ នោះសារការីត្រូវមានភារៈកិច្ចក្នុងការបកស្រាយពន្យល់ជាភាសាសាមញ្ញ។

**ផ្នែកទី ២៖ តួនាទីសារការីក្នុងការថែរក្សា និងប្រតិបត្តិមតកសាសន៍**

សារការីដើរតួយ៉ាងសកម្ម និងជាតួអង្គសំខាន់ដែលមិនអាចខ្វះបាននៅក្នុងសន្តតិកម្មតាំងពីការតាក់តែង ការថែរក្សា និងការប្រតិបត្តិចាត់ចែង ពីព្រោះសារការីក៏ជាអ្នកវិជ្ជាជីវៈច្បាប់មួយក្នុងចំណោមអ្នកវិជ្ជាជីវៈច្បាប់ដទៃទៀត។ ហេតុដូចច្នេះ នៅក្នុងផ្នែកនេះនឹងធ្វើការបកស្រាយទៅលើ តួនាទីក្នុងការតម្កល់មតកសាសន៍របស់សារការី (**ចំណុច ២.១**) ការប្រតិបត្តិមតកសាសន៍ក្នុងសន្តតិកម្ម (**ចំណុច ២.២**) ការបែងចែកមត៌កដោយទម្រង់លិខិតយថាភូត (**ចំណុច ២.៣**) និង បញ្ហាប្រឈមរបស់វិជ្ជាជីវៈសារការីក្នុងសន្តតិកម្ម (**ចំណុច ២.៤**)។

**២.១. ការតម្កល់មតកសាសន៍របស់សារការី**

សារការីមិនត្រឹមតែមានតួនាទីក្នុងការតាក់តែងមតកសាសន៍ប៉ុណ្ណោះទេ សារការីក៏បានចូលរួមនៅក្នុងការតម្កល់មតកសាសន៍ដោយលិខិតយថាភូតដែលខ្លួនបានតាក់តែង និងដូចជាមតកសាសន៍ក្រោមទម្រង់ផ្សេងទៀតដែលបានស្នើសុំតម្កល់ដោយម្ចាស់បណ្តាំ ដើម្បីធានាបាននូវសុវត្ថិភាព និងប្រសិទ្ធិភាពនៃបណ្តាំមុនពេលចាប់ផ្តើមសន្តតិកម្ម។ ការតម្កល់លិខិតយថាភូត និងការចេញឯកសារចម្លងយថាភូតនេះ គឺជាកាតព្វកិច្ចរបស់សារការីដែលត្រូវបានកំណត់ក្នុងច្បាប់ នៅក្នុងបណ្តាប្រទេសនៃប្រព័ន្ធច្បាប់សារការីឡាតាំងផងដែរ។[116]

**២.១.១. គោលបំណង**

**២.១.១.១. ការបំពេញនូវឆន្ទៈរបស់ម្ចាស់បណ្តាំឲ្យទទួលបានប្រសិទ្ធិភាព**

ការតម្កល់មតកសាសន៍របស់សារការីមានគោលបំណងក្នុងការដើម្បីជួយធានាឲ្យបាននូវការគោរព និងបំពេញនូវឆន្ទៈរបស់ម្ចាស់បណ្តាំឲ្យទទួលបាននូវប្រសិទ្ធិភាព។ ពីព្រោះថា ម្ចាស់បណ្តាំមុនពេលស្លាប់មានឆន្ទៈក្នុងការធ្វើមតកសាសន៍ដែលទុកសម្រាប់ក្រោយពេលខ្លួនឯងទទួលអនិច្ចកម្ម នោះមត៌កនឹងធ្លាក់ទៅសន្តតិជន។

[116] សហភាពសារការីឡាតាំងអន្តរជាតិ, The Significance of the Notary and His Office in the Countries Associated in the Union International du Notariat Latin, International Lawyer, ខែតុលា ឆ្នាំ១៩៧១, Vol 5, លេខ៤, ទំព័រ ៧៥២

ប៉ុន្តែដោយហេតុថា ម្ចាស់បណ្តាំ ភ័យខ្លាចពេលដែលខ្លួនទទួលអនិច្ចកម្មទៅ សន្តតិជនដែលត្រូវនៅទទួលមត៌ក នោះអាចមានការខ្វែងគំនិតឈ្លោះប្រកែកដណ្តើមមត៌កគ្នា។ ដូចនេះ ទើបសារការីមានការតម្កល់មតកសាសន៍នេះឡើង ដើម្បីឲ្យជានាបានគោរពនូវការសម្រេចចិត្តរបស់ម្ចាស់បណ្តាំដែលបន្សល់ទុកនៅមុនពេលខ្លួនទទួលអនិច្ចកម្មទៅ។

### ២.១.១.២. ការធានាឲ្យបាននូវការទទួលស្គាល់ និងសុក្រឹត្យភាពនៃមតកសាសន៍

ការតម្កល់មតកសាសន៍របស់សារការីមានគោលបំណងក្នុងការដើម្បីជួយធានាឲ្យបាននូវការគោរព និងបំពេញនូវឆន្ទៈរបស់ម្ចាស់បណ្តាំឲ្យទទួលបាននូវប្រសិទ្ធិភាព។ ពីព្រោះថា ម្ចាស់បណ្តាំមុនពេលស្លាប់មានឆន្ទៈក្នុងការធ្វើមតកសាសន៍ដែលទុកសម្រាប់ក្រោយពេលខ្លួនឯងទទួលអនិច្ចកម្ម នោះមត៌កនឹងធ្លាក់ទៅសន្តតិជន។ ប៉ុន្តែដោយហេតុថា ម្ចាស់បណ្តាំ ភ័យខ្លាចពេលដែលខ្លួនទទួលអនិច្ចកម្មទៅ សន្តតិជនដែលត្រូវនៅទទួលមត៌ក នោះអាចមានការខ្វែងគំនិតឈ្លោះប្រកែកដណ្តើមមត៌កគ្នា។ ដូចនេះ ទើបសារការីមានការតម្កល់មតកសាសន៍នេះឡើង ដើម្បីឲ្យជានាបានគោរពនូវការសម្រេចចិត្តរបស់ម្ចាស់បណ្តាំដែលបន្សល់ទុកនៅមុនពេលខ្លួនទទួលអនិច្ចកម្មទៅ។

### ២.១.២. វិធីសាស្ត្រនៃការតម្កល់មតកសាសន៍

ទាក់ទងទៅនឹងការតម្រូវឲ្យតម្កល់មតកសាសន៍ គឺពុំបានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តជាវិជ្ជមានឡើយ។ ប៉ុន្តែបច្ចុប្បន្នយើងមានតែតួនាទីនៃការតម្កល់មតកសាសន៍ ដែលបានកំណត់នៅក្នុងអនុក្រឹត្យស្តីពីការបង្កើតមន្ទីរសារការីនីមួយៗ តែប៉ុណ្ណោះ ដែលបញ្ជាក់អំពីសមត្ថកិច្ចរបស់សារការីនៅក្នុងការតម្កល់នេះ។[117] យ៉ាងណាមិញ បញ្ញត្តិទាំងនោះ ពុំបានកំណត់ជាលក្ខខណ្ឌដាច់ខាតនៃការតម្កល់លិខិតយថាភូតរបស់សារការីឡើយ។ ចំពោះការចុះបញ្ជីអំពីការតម្កល់មតកសាសន៍ សារការីត្រូវធ្វើការផ្តល់ព័ត៌មានដូចជា៖ នាម និងគោត្តនាមរបស់ម្ចាស់បណ្តាំ, ថ្ងៃខែឆ្នាំ និងទីកន្លែងកំណើត, លំនៅឋានរបស់ម្ចាស់បណ្តាំ ប្រភេទ និងកាលបរិច្ឆេទនៃមតកសាសន៍ដែលស្នើសុំតម្កល់, ឈ្មោះ និងអាសយដ្ឋានសារការី អាជ្ញាធរសាធារណៈ ឬបុគ្គលដែលទទួលលិខិត ឬតម្កល់លិខិត។[118] នៅពេលចាប់ផ្តើមសន្តតិកម្ម បុគ្គលដែលមានផលប្រយោជន៍ អាចស្នើសុំព័ត៌មានទាំងនោះ ដោយភ្ជាប់មកជាមួយនូវសំបុត្រមរណភាព។[119] នៅក្នុងអន្តរកាលដែលពុំមានបញ្ញត្តិចែងជាក់លាក់ ការតម្កល់មតកសាសន៍ដោយលិខិតយថាភូតស្ថិតនៅក្នុងភាពមន្ទិល។ ប៉ុន្តែក្នុងគោលបំណងការពារ

---

[117] អនុក្រឹតស្តីពីការបង្កើតមន្ទីរសារការីនីមួយៗ ដែលមានក្នុង ឧបសម្ព័ន្ធទី ៣។

[118] មាត្រា ៧ កថាខណ្ឌទី១ នៃអនុសញ្ញាស្តីពីការបង្កើតក្របខ័ណ្ឌនៃការចុះបញ្ជីមតកសាសន៍។

[119] មាត្រា ៨ កថាខណ្ឌទី២ នៃអនុសញ្ញាស្តីពីការបង្កើតក្របខ័ណ្ឌនៃការចុះបញ្ជីមតកសាសន៍។

មតកសាសន៍ពីការក្លែងបន្លំ កែប្រែ លុបចោល ដែលក្រៅពីឆន្ទៈម្ចាស់បណ្តាំ មតកសាសន៍ដោយលិខិតយថាភូតដែលធ្វើឡើងដោយសារការី គប្បីត្រូវតម្កល់នៅមន្ទីរសារការី។ បន្ទាប់ពីបាន បង្កើតមតកសាសន៍ដោយលិខិតយថាភូត សារការីគួររៀបចំរក្សាទុកមតកសាសន៍ និងចេញវិញ្ញាបនបត្រស្តីពីការតម្កល់មតកសាសន៍ ជូនម្ចាស់បណ្តាំ ដើម្បីជាភស្តុតាងនៃការតម្កល់មតកសាសន៍។ ក្រៅពីនេះ សារការីក៏អាចទទួលតម្កល់មតកសាសន៍ដោយទម្រង់ផ្សេងទៀតដែលស្នើសុំដោយម្ចាស់បណ្តាំផងដែរ។

### ២.១.៣. ការចេញនូវឯកសារចម្លងយថាភូតនៃមតកសាសន៍ដោយលិខិតយថាភូត

តាមគោលការណ៍លិខិតយថាភូតមានតែច្បាប់ដើមមួយប៉ុណ្ណោះ។[120] ដូចច្នេះ ដើម្បីបានប្រើប្រាស់នូវលិខិតយថាភូតមួយបាន បុគ្គលដែលពាក់ព័ន្ធត្រូវដាក់ស្នើសុំមកមន្ទីរសារការីដើម្បីឲ្យខាងមន្ទីរសារការីបានផ្តល់ឯកសារចម្លងយថាភូត។ ហើយសេចក្តីចម្លងយថាភូត គឺជាឯកសារមួយដែលសារការីបានថតចម្លងចេញពីច្បាប់ដើមនៃលិខិតយថាភូតនោះ ដោយមានការធ្វើការបញ្ជាក់ និងត្រូវផ្តល់អំណាចទៅដល់ឯកសារនោះដូចទៅនឹងច្បាប់ដើមដែរ។ ហេតុនេះ សារការីជាអ្នកទទួលបញ្ជាក់ការចម្លងត្រឹមត្រូវតាមច្បាប់ដើមនូវរាល់លិខិតយថាភូត ហើយឯកសារចម្លងយថាភូតនេះមានតម្លៃស្មើនឹងច្បាប់ដើមដែរ។

មួយវិញទៀត បើក្រឡេកទៅមើលអត្ថបទច្បាប់នៃបណ្តាប្រទេសដែលមានឥទ្ធិពលលើវិស័យច្បាប់ពោលគឺក្រមរដ្ឋប្បវេណីកម្ពុជាចំពោះតែចំណុចដែលពុំមានកំណត់នេះ អាចសង្កេតបានថា ដោយយោងតាមច្បាប់ស្តីពីសារការីនៃប្រទេសជប៉ុន ឯកសារចម្លងយថាភូតគឺជាឯកសារចម្លងដែលចេញដោយសារការី ដែលមានផ្ទុកនូវព័ត៌មានមួយចំនួនរួមមាន ខ្លឹមសារទាំងស្រុងនៃលិខិតយថាភូត ឈ្មោះបុគ្គលដែលបានស្នើសុំការផ្តល់ និងកាលបរិច្ឆេទ សេចក្តីថ្លែងការណ៍ដែលសរសេរថាវាជាឯកសារចម្លងយថាភូត និងទីកន្លែងនៃការផ្តល់។[121]

## ២.២. ការប្រតិបត្តិមតកសាសន៍ក្នុងសន្តតិកម្ម

ការប្រតិបត្តិមតកសាសន៍ក៏ជាផ្នែកមួយ ក្នុងការជួយឲ្យដំណើរប្រព្រឹត្តនៃមតកសាសន៍បានល្អត្រឹមត្រូវដោយផ្អែកតាមឆន្ទៈម្ចាស់បណ្តាំ។ មួយវិញទៀត នៅក្នុងការប្រតិបត្តិមតកសាសន៍នេះ សារការីក៏អាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍បាន ហើយក៏ដើរតួយ៉ាងសំខាន់នោះដែរ ពីព្រោះអ្នកប្រតិបត្តិមតកសាសន៍គឺទាមទារឲ្យមានសមត្ថភាពផ្នែកច្បាប់ខ្ពស់។

[120] UINL, Fundamental Principles of the Latin Type Notarial System (គោលការណ៍គ្រឹះនៃប្រព័ន្ធសារការីឡាតាំង), ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ ២០០៥។

[121] មាត្រា ៤៨ កថាខណ្ឌទី១ នៃច្បាប់ស្តីពីសារការីប្រទេសជប៉ុនឆ្នាំ ១៩០៨។

### ២.២.១. អ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍ គឺជាជនដែលត្រូវបានកំណត់ដោយម្ចាស់ បណ្តាំ ឬមតកជនដោយតាមមតសាសន៍ ឬដោយតុលាការតាមពាក្យស្នើសុំ របស់ជនដែលមានផលប្រយោជន៍ពាក់ព័ន្ធ ដើម្បីធ្វើរាល់សកម្មភាពដែលចាំបាច់ក្នុងការប្រតិបត្តិមតកសាសន៍។ អ្នកប្រតិបត្តិមតកសាសន៍ មិនមានការកំណត់ជាក់លាក់ច្បាស់លាស់ថាត្រូវជានរណាឡើយ អាចជាសារការី ឬ អ្នកដែលជាតតិយជនក្រៅពីសន្តតិជន។ មួយវិញទៀត នៅក្នុងក្រមរដ្ឋប្បវេណី អ្នកប្រតិបត្តិមតកសាសន៍ក៏ពុំត្រូវបានតម្រូវជាចាំបាច់នោះដែរ។ ហេតុនេះ ម្ចាស់បណ្តាំ ឬ មតកជនអាចកំណត់ ឬ មិនកំណត់អ្នកប្រតិបត្តិមតកសាសន៍បាន។

#### ២.២.១.១. ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍

នៅពេលដែលម្ចាស់បណ្តាំមានបំណងចង់ឲ្យមត៌ករបស់ខ្លួនគ្រប់គ្រង និងបែងចែកដោយអ្នកប្រតិបត្តិមតកសាសន៍នោះម្ចាស់បណ្តាំអាចធ្វើការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍បានដោយកំណត់តាមរយៈមតកសាសន៍។ អ្នកប្រតិបត្តិមតកសាសន៍ត្រូវតែជានីតិជន និងពុំមែនជាជននៅក្រោមអាណាព្យាបាលទូទៅ ឬជននៅក្រោមហិតូបត្ថម្ភ និងជនធនក្ស័យនោះឡើយ។[122] ដោយហេតុថា អ្នកប្រតិបត្តិមតកសាសន៍ទទួលបន្ទុកទៅលើការចាត់ចែងកិច្ចការ ការគ្រប់គ្រង និងប្រតិបត្តិតាមខ្លឹមសារនៃមតកសាសន៍ ដូចនេះអ្នកប្រតិបត្តិមតកសាសន៍ត្រូវតែមានសមត្ថភាពគ្រប់គ្រាន់ដែលឆ្លើយតបទៅនឹងកិច្ចការងារដែលត្រូវប្រតិបត្តិនោះក៏ដូចជាមានការយល់ដឹងអំពីសិទ្ធិ និងសកម្មភាពរបស់ខ្លួនដែលត្រូវបំពេញ។ មួយវិញទៀត ក្នុងក្រមរដ្ឋប្បវេណីក៏មិនបានកម្រិតសមត្ថភាពរបស់សារការី ក្នុងការធ្វើជាអ្នកប្រតិបត្តិមតកសាសន៍ដែរ។

យ៉ាងណាមិញ កិច្ចការរបស់អ្នកប្រតិបត្តិមតកសាសន៍គឺអាចមានច្រើនរួមមាន ការរៀបចំនូវបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិ[123] ការតម្រូវឲ្យអ្នកប្រតិបត្តិមតកសាសន៍ដាក់ពាក្យស្នើសុំទៅតុលាការដើម្បីផ្តាច់មត៌កពីសន្តតិជន ការដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិអចលនវត្ថុទៅអច្ច័យលាភី និងការដាក់នូវលិខិតប្រកាសពន្ធជាអាទិ៍។ ដោយសារតែទំហំកិច្ចការងាររបស់អ្នកប្រតិបត្តិមតកសាសន៍មានភាពស្មុគស្មាញច្រើន ហេតុនេះម្ចាស់បណ្តាំអាចធ្វើការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍ច្រើននាក់ ដែលហៅថា សហអ្នកប្រតិបត្តិមតកសាសន៍[124] ដើម្បីឲ្យទទួលបាននូវការធានាចំពោះការប្រតិបត្តិមតកសាសន៍នោះអនុវត្ត និងប្រព្រឹត្តទៅបានយ៉ាងត្រឹមត្រូវច្បាស់លាស់។ ទាក់ទងនឹងការសម្រេចអំពីកិច្ចការប្រតិបត្តិនេះ ត្រូវធ្វើឡើងតាមសម្លេងភាគច្រើននៅក្នុងសហប្រតិបត្តិមតកសាសន៍នេះ។ ទោះបីជាយ៉ាងនេះក្តី ម្ចាស់បណ្តាំក៏អាចធ្វើការកំណត់នៅក្នុងមតកសាសន៍ដោយឲ្យអ្នក

[122] មាត្រា ១២១៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[123] មាត្រា ១២១៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[124] មាត្រា ១២២៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

ប្រតិបត្តិមតកសាសន៍ណាម្នាក់មានអានុភាពក្នុងការសម្រេចផងដែរ ឬក៏អាចជ្រើសតាំងសហប្រតិបត្តិមតកសាសន៍ដោយបែងចែកមុខងារនៃការប្រតិបត្តិ។

### ២.២.១.២. វិសាលភាពនៃការប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍ត្រូវបានកម្រិតនូវសិទ្ធិក្នុងការប្រតិបត្តិមតកសាសន៍ ព្រោះដើម្បីបញ្ចៀសនូវហានីភ័យណាមួយដែលកើតមានឡើងដែលនាំឲ្យប៉ះពាល់ដល់ផលប្រយោជន៍សន្តតិជន។ ដូចនេះ អ្នកប្រតិបត្តិមតកសាសន៍ត្រូវបានកម្រិតនូវសិទ្ធិត្រឹមទ្រព្យសម្បត្តិដែលបានកំណត់ឲ្យប្រតិបត្តិប៉ុណ្ណោះ។[125] មួយវិញទៀត ទាក់ទងទៅនឹងការប្រតិបត្តិមតកសាសន៍នេះ គឺពុំមែនជាសកម្មភាពដែលមិនយកកម្រៃនោះឡើយ[126] ហេតុនេះហើយ បានជានៅក្នុងការតាក់តែងមតកសាសន៍ សារការីចាំបាច់ត្រូវមានស្មារតីប្រុងប្រយ័ត្នខ្ពស់អំពីឆន្ទៈរបស់ម្ចាស់បណ្តាំមានឆន្ទៈក្នុងការកម្រិតសិទ្ធិរបស់អ្នកប្រតិបត្តិសាសន៍ នោះសារការីត្រូវសរសេរចូលនៅក្នុងមតកសាសន៍អំពីខ្លឹមសារនោះផងដែរ។

### ២.២.១.៣.កម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍ និងសោហ៊ុយនៃការប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍មានសកម្មភាពក៏ដូចជាកិច្ចការប្រហាក់ប្រហែលទៅនឹងអាណត្តិដែរ។ អ្នកប្រតិបត្តិមតកសាសន៍ ត្រូវបានបំពេញសិទ្ធិក៏ដូចជាកាតព្វកិច្ចទៅឲ្យម្ចាស់បណ្តាំដោយម្ចាស់បណ្តាំត្រូវផ្តល់នូវកម្រៃជាការតបស្នងវិញ។ មួយវិញទៀត ដោយសារតែអ្នកប្រតិបត្តិមតកសាសន៍ត្រូវបំពេញនូវសកម្មភាពជាច្រើនក្នុងគោលការណ៍បំណងដើម្បីប្រតិបត្តិមតកសាសន៍ឲ្យបានត្រឹមត្រូវ ហេតុនេះទើបក្រមរដ្ឋប្បវេណីក៏បានពិចារណាទៅលើកម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍នេះ។ ម្យ៉ាងទៀត ម្ចាស់បណ្តាំអាចធ្វើការកំណត់នូវកម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍នៅក្នុងមតកសាសន៍បាន។ គួរបញ្ជាក់ផងដែរថា នៅក្នុងការតាក់តែងមតកសាសន៍នេះ សារការីអាចផ្តល់ជាយោបល់ទៅដល់ម្ចាស់បណ្តាំនៅក្នុងការកំណត់នូវកម្រៃនេះ ពីព្រោះដើម្បីឲ្យមានភាពងាយស្រួលឲ្យក៏ដូចជាសមស្រប និងទទួលយកបានដោយអ្នកប្រតិបត្តិតមកសាសន៍ក្នុងការទទួលយកនូវមុខងារនេះមកប្រតិបត្តិ។ ប៉ុន្តែក៏អាចមានករណីមួយចំនួនអ្នកប្រតិបត្តិមកតកសាសន៍កាន់មុខងារដោយសុឆន្ទៈដោយផ្អែកលើមូលហេតុទំនាក់ទំនងរវាងម្ចាស់បណ្តាំ និងអ្នកប្រតិបត្តិ ដូច្នេះនៅក្នុងមតកសាសន៍នេះអាចមិនកំណត់អំពីកម្រៃអ្នកប្រតិបត្តិបាន។ យ៉ាងណាមិញ នៅក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍បានយល់ព្រមប្រតិបត្តិតែក្នុងមតកសាសន៍ពុំបានកំណត់កម្រៃពីការប្រតិបត្តិនោះ អ្នកប្រតិបត្តិមតកសាសន៍អាចធ្វើការដាក់ពាក្យស្នើសុំទៅកាន់តុលាការដើម្បីកំណត់អំពីកម្រៃនៃការងារដែលខ្លួនប្រតិបត្តិនេះ។ ថែមទាំងតុលាការ

[125] មាត្រា ១២២២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[126] មាត្រា ១២២៦ នៃក្រមរដ្ឋប្បវេណីនៃឆ្នាំ ២០០៧។

ត្រូវកំណត់ចំនួនទឹកប្រាក់កម្រៃនោះទៅតាមពាក្យសុំរបស់អ្នកប្រតិបត្តិមតកសាសន៍ ក្នុងករណីបើយល់ឃើញថាសមរម្យ នៅក្នុងការបង់កម្រៃនេះ ដោយមានការពិចារណាទៅលើស្ថានភាពនៃមត៌កទំនាក់ទំនងរវាងអ្នកប្រតិបត្តិមតកសាសន៍ និងម្ចាស់បណ្ដាំ ឬមតកជន និងស្ថានភាពផ្សេងៗទៀត រួមមានវិសាលភាពនៃការងារប្រតិបត្តិនេះ និងពេលវេលាដែលបានចំណាយទៅលើដើម្បីប្រតិបត្តិមតកសាសន៍នេះ។

**២.២.១.៤.សោហ៊ុយក្នុងការប្រតិបត្តិមតកសាសន៍**

សោហ៊ុយក្នុងការប្រតិបត្តិសាសន៍ សំដៅទៅលើរាល់ការចំណាយដែលពាក់ព័ន្ធនឹងការប្រតិបត្តិទាំងអស់។ សម្រាប់ការចំណាយនេះ អាចមានភាពខុសគ្នាទៅតាមស្ថានភាពជាក់ស្ដែងនីមួយៗដូចជាសេវាសាធារណៈក្នុងការចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយសន្តតិកម្ម កម្រៃមេធាវីក្នុងការតំណាងដោយអាណត្តិតាមផ្លូវតុលាការ ចំណាយទៅលើការរៀបចំបញ្ជីសារពើភ័ណ្ឌ និងការចំណាយទាក់ទងនឹងការគ្រប់គ្រងមត៌កសម្រាប់ការបែងចែកជាអាទិ៍។ ដោយថ្លៃសោហ៊ុយទាំងអស់នោះ ត្រូវបូកចូលជាបន្ទុកនៃមត៌ក។[127] អត្ថន័យនៃពាក្យជាបន្ទុកនៃមត៌កមានន័យថា គឺសន្តតិជនជាអ្នកត្រូវទទួលបន្ទុកទៅតាមសមាមាត្រនៃចំណែកមត៌ករបស់ខ្លួន។ ប៉ុន្តែក្នុងករណីខ្លះថ្លៃសោហ៊ុយនៃបន្ទុកមត៌កអាចធ្វើឲ្យប៉ះពាល់ទៅដល់សិទ្ធិលើភាគបម្រុងរបស់សន្តតិជនផងដែរ។ ដោយហេតុថាច្បាប់មានបំណងការពារសិទ្ធិលើភាគបម្រុងរបស់សន្តតិជននេះ ហេតុដូច្នេះហើយ បន្ទុកនៃមត៌កមិនត្រូវបំពានទៅលើសិទ្ធិភាគបម្រុងរបស់សន្តតិជនឡើយ។[128]

លើសពីនេះទៅទៀតដែរ នៅក្នុងមតកសាសន៍ម្ចាស់បណ្ដាំអាចធ្វើការកំណត់នូវកម្មវត្ថុ មត៌កដែលសម្រាប់ផ្ដល់ក្នុងការចំណាយជាសោហ៊ុយនៃការប្រតិបត្តិមតកសាសន៍នេះបាន។ ឧទាហរណ៍ មតកជនត្រូវរក្សាប្រាក់ទុកនៅក្នុងធនាគារចំនួន បីពាន់ប្រាំរយដុល្លារអាមេរិច ក្នុងការទុកធ្វើជាសោហ៊ុយក្នុងការប្រតិបត្តិមតកសាសន៍នេះ។

**២.២.២. ការប្រតិបត្តិមតកសាសន៍ដោយសារការី**

សារការីអាចត្រូវបានជ្រើសតាំងជាអ្នកប្រតិបត្តិមតកសាសន៍ដោយមតកជន ឬតុលាការដើម្បីបំពេញនូវកិច្ចការប្រតិបត្តិមតកសាសន៍។ បន្ថែមពីនេះ សង្កេតឃើញថាក៏ពុំមានបញ្ញត្តិណាមួយនៅក្នុងក្រមរដ្ឋប្បវេណី ឬនៅក្នុងលិខិតបទដ្ឋានគតិយុត្តណាផ្សេងទៀត ធ្វើការកម្រិតទៅលើមុខងារជាអ្នកប្រតិបត្តិមតកសាសន៍របស់សារការីនៅឡើយទេ។

[127] មាត្រា ១២២៨ វាក្យខ័ណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[128] មាត្រា ១២២៨ វាក្យខ័ណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

### ២.២.២.១. ការទទួលមុខងារជាអ្នកប្រតិបត្តិមតកសាសន៍

ក្នុងករណីដែលការកំណត់អ្នកប្រតិបត្តិមតកសាសន៍ ធ្វើឡើងតាមរយៈមតកសាសន៍ ហេតុនេះដើម្បីអាចទទួលមុខងារជាអ្នកប្រតិបត្តិមតកសាសន៍ និងបំពេញកិច្ចផ្សេងៗបានមតកសាសន៍ដែលបានកំណត់នោះត្រូវតែមានអានុភាពអាចយកទៅអនុវត្តជាមុនសិន។ ប្រសិនបើមតកសាសន៍ដែលកំណត់អ្នកប្រតិបត្តិ ត្រូវបានធ្វើឡើងតាមដោយលិខិតយថាភូត សន្តតិជន ឬបុគ្គលដែលមានផលប្រយោជន៍ពាក់ព័ន្ធ អាចដាក់ពាក្យសុំឯកសារចម្លងយថាភូតនៃមតកសាសន៍ មកមន្ទីរសារការី ដោយពុំចាំបាច់ដាក់ ពាក្យសុំពិនិត្យបញ្ជាក់មតកសាសន៍។ ប៉ុន្តែប្រសិនបើមតកសាសន៍ត្រូវបានធ្វើឡើងក្រោមទម្រង់ផ្សេង សន្តតិជនត្រូវដាក់ពាក្យសុំពិនិត្យបញ្ជាក់មតកសាសន៍ មុននឹងអាចធ្វើការដាស់តឿនឲ្យអ្នកប្រតិបត្តិមតកសាសន៍កាន់មុខងារ។[129]

បើមតកជនបានបង្ហាញឆន្ទៈ ជ្រើសតាំងសារការីជាអ្នកប្រតិបត្តិមតកសាសន៍សន្តតិជន ជាអាទិ៍ ត្រូវដាស់តឿនសារការីឲ្យបំពេញមុខងារជាអ្នកប្រតិបត្តិមតកសាសន៍ដោយកំណត់អំឡុងពេលសមរម្យ។ តាមការស្នើសុំ សារការីអាចទទួល ឬបដិសេធមិនបំពេញមុខងារជាអ្នកប្រតិបត្តិ។[130] ការស្នើសុំ និងការឆ្លើយតបចំពោះការទទួលមុខងារគប្បីធ្វើឡើងក្រោមទម្រង់ជាលិខិតជាលាយលក្ខណ៍អក្សរ ដើម្បីមានភាពងាយស្រួលក្នុងករណីដែលសន្តតិជន ឬអ្នកពាក់ព័ន្ធផលប្រយោជន៍ យកមកធ្វើជាមូលដ្ឋានក្នុងការដាក់ពាក្យសុំទៅតុលាការឲ្យជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍។

### ២.២.២.២. ការគ្រប់គ្រងមត៌ក និងការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ

ក្នុងករណីមានអ្នកប្រតិបត្តិមតកសាសន៍ សន្តតិជនត្រូវបាត់បង់សិទ្ធិគ្រប់គ្រង និងចាត់ចែងទាំងអស់លើកម្មវត្ថុនៃមត៌ក និងត្រូវបានហាមឃាត់មិនឲ្យបំពេញសកម្មភាពដែលរារាំងដល់ការប្រតិបត្តិមតកសាសន៍។ អ្នកប្រតិបត្តិមតកសាសន៍ ត្រូវប្រមូលទ្រព្យសម្បត្តិជាមត៌កមកគ្រប់គ្រង។ អ្នកប្រតិបត្តិមតកសាសន៍អាចទាមទារឲ្យសន្តតិជនដែលកំពុងកាន់កាប់មត៌កឲ្យប្រគល់មត៌កបានក្នុងករណីមានអ្នកប្រតិបត្តិមតកសាន៍។[131]

អ្នកប្រតិបត្តិមតកសាសន៍ ត្រូវរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិ។ បញ្ជីសារពើភ័ណ្ឌមានរៀបរាប់អំពីទ្រព្យសម្បត្តិដែលត្រូវធ្វើការបែងចែកឲ្យសន្តតិជន និងអច្ច័យលាភី ហើយជាមូលដ្ឋានដែលកំណត់អំពី

[129] មាត្រា ១២១៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[130] មាត្រា ១២១៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[131] មាត្រា ១២៦៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

ករណីយកិច្ចរាយការណ៍ ករណីយកិច្ចសងសំណងការខូចខាត និងករណីយកិច្ចប្រគល់។[132] សារការីត្រូវប្រគល់បញ្ជីសារពើភ័ណ្ឌជូនសន្តតិជនដោយគ្មានការយឺតយ៉ាវ។[133]

### ២.២.២.៣. ការដាក់ពាក្យសុំផ្តាច់មត៌កជាអាទិ៍ពីសន្តតិជន

ករណីយកិច្ចដំបូងដែលអ្នកប្រតិបត្តិមតកសាសន៍ត្រូវបំពេញ គឺការដាក់ពាក្យសុំផ្តាច់មត៌តជាអាទិ៍ពីសន្តតិជន ប្រសិនបើមានការកំណត់ក្នុងមតកសាសន៍។ ក្រមរដ្ឋប្បវេណីបានទាមទារឲ្យអ្នកប្រតិបត្តិដាក់ពាក្យសុំផ្តាច់មត៌កពីសន្តតិជន ដោយគ្មានការយឺតយ៉ាវនៅពេលមតកសាសន៍បង្កើតអានុភាព ក្នុងគោលបំណងដកហូតសិទ្ធិសន្តតិកម្ម និងសិទ្ធិគ្រប់គ្រងមត៌កពីសន្តតិជនដែលត្រូវបានផ្តាច់មត៌កតាមមតកសាសន៍។[134]

សារការីក្នុងនាមជាអ្នកប្រតិបត្តិមតកសាសន៍ ត្រូវទទួលខុសត្រូវចំពោះសន្តតិជន ចំពោះការខូចខាតដែលកើតឡើងពីការខកខានមិនបានផ្តាច់មត៌កពីសន្តតិជន[135] និងអាចត្រូវបានបញ្ឈប់ពីមុខងារដោយតុលាការតាមពាក្យសុំរបស់សន្តតិជន ក្នុងករណីមានការធ្វេសប្រហែស។ ការដាក់ពាក្យសុំផ្តាច់មត៌កពីសន្តតិជន ត្រូវធ្វើឡើងអនុលោមតាមច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។ សារការីត្រូវដាក់ពាក្យសុំទៅតុលាការនៃលំនៅឋានមតកជនពេលចាប់ផ្តើមសន្តតិកម្ម ដោយយោងលើមូលហេតុនៃការផ្តាច់មត៌កដូចបានកំណត់ក្នុងមតកសាសន៍ជាមូលដ្ឋាននៃការទាមទារ។

### ២.២.២.៤. ការបែងចែកមត៌កដោយអ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍មានសិទ្ធិ និងករណីយកិច្ចក្នុងការគ្រប់គ្រងមត៌ក និងធ្វើនូវរាល់សកម្មភាពផ្សេងទៀតដែលចាំបាច់ ដើម្បីប្រតិបត្តិមតកសាសន៍។[136] ដោយផ្អែកតាមបញ្ញត្តិនេះ អ្នកប្រតិបត្តិមតកសាសន៍អាចធ្វើការបែងចែកទៅតាមឆន្ទៈរបស់មតកជន និងសងកាតព្វកិច្ចជំនួសសន្តតិជន នៅក្នុងករណីដែលមានកំណត់ក្នុងមតកសាសន៍។ ប៉ុន្តែទាក់ទងនឹងវិសាលភាពនៃការប្រតិបត្តិរបស់អ្នកប្រតិបត្តិមតកសាសន៍ ត្រូវបានកម្រិតចំពោះទ្រព្យសម្បត្តិដែលខ្លួនត្រូវបានកំណត់ឲ្យធ្វើតែប៉ុណ្ណោះ។ មួយវិញទៀត សារការីត្រូវធ្វើបញ្ជីសារពើភ័ណ្ឌ និងប្រគល់ទ្រព្យសម្បត្តិដែលបានកំណត់ទៅឲ្យសន្តតិជន និងអច្ច័យលាភីកំណត់។ ក្នុងករណីដែលមតកសាសន៍បានជ្រើសតាំងតតិយជន ឲ្យធ្វើការកំណត់វិធីបែងចែកចំពោះសន្តតិជន ឬអច្ច័យលាភី អ្នកប្រតិបត្តិ

---

[132] មាត្រា ១២១៩ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី។

[133] មាត្រា ១២១៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[134] មាត្រា ១១៥២ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[135] មាត្រា ១២២៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[136] មាត្រា ១២២០ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

មតកសាសន៍ត្រូវដាស់តឿនជននោះឲ្យធ្វើការកំណត់ ហើយត្រូវប្រគល់ទ្រព្យសម្បត្តិដែលបានកំណត់នោះទៅសន្តតិជន ឬអច្ច័យលាភីតាមលទ្ធផលនៃការកំណត់ដោយតតិយជននោះ។[137]

បន្ទាប់ពីបានធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិ អ្នកប្រតិបត្តិមតកសាសន៍ត្រូវប្រគល់ទ្រព្យសម្បត្តិជាមត៌កទៅឲ្យសន្តតិជន និងអច្ច័យលាភីកំណត់ទៅតាមខ្លឹមសារនៃមតកសាសន៍។ ក្នុងករណីដែលកម្មសិទ្ធិអាចត្រូវបានផ្ទេរ តែតាមរយៈការចុះបញ្ជីជាដើម កម្មសិទ្ធិលើអចលនវត្ថុអ្នកប្រតិបត្តិមតកសាសន៍ត្រូវដាក់ពាក្យសុំរួមគ្នាជាមួយសន្តតិជនដែលត្រូវទទួលបានទ្រព្យសម្បត្តិ ទៅខាងរដ្ឋបាលសុរិយោដី ដោយអនុលោមតាម ប្រកាសអន្តរក្រសួងលេខ ៣០ ស្តីពីនីតិវិធីចុះបញ្ជីសិទ្ធិប្រត្យក្សពាក់ព័ន្ធនឹងក្រមរដ្ឋប្បវេណី។

## ២.៣. ការបែងចែកមត៌កដោយទម្រង់លិខិតយថាភូត

ក្នុងករណីដែលមកតសាសន៍ពុំបានកំណត់អំពីវិធីបែងចែកមត៌កទេ សន្តតិជនត្រូវធ្វើការពិភាក្សាបែងចែកតាមការព្រមព្រៀង។[138]ក្នុងករណីនេះអ្នកប្រតិបត្តិមតកសាសន៍មិនអាចសម្រេចធ្វើការបែងចែកមត៌កជំនួសសន្តតិជនឡើយ លើកលែងតែករណីដែលអ្នកប្រតិបត្តិមតកសាសន៍ត្រូវបានជ្រើសតាំងដោយមតកជន ឲ្យធ្វើការកំណត់វិធីបែងចែកមត៌ក អនុលោមតាមមាត្រា ១១៨៣នៃក្រមរដ្ឋប្បវេណី។ ការពិភាក្សាបែងចែកនេះ ត្រូវធ្វើឡើងតាមទម្រង់ដែលកំណត់ដោយក្រមរដ្ឋប្បវេណី និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលចាំបាច់សម្រាប់ការផ្ទេរសិទ្ធិទាំងនោះ។[139] ដោយហេតុថាការពិភាក្សាបែងចែក គឺជាការបំបាត់នូវស្ថានភាពអវិភាគនៃទ្រព្យ[140] ដោយឲ្យសន្តតិជនណាម្នាក់ ឬច្រើន ធ្វើលទ្ធកម្មលើអចលវត្ថុ ហេតុនេះទម្រង់នៃការពិភាក្សាបែងចែកមត៌កជាអចលនវត្ថុត្រូវធ្វើឡើង លិខិតយថាភូតតាមបញ្ញត្តិ មាត្រា៣៣៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។

### ២.៣.១. ទម្រង់នៃការពិភាក្សាបែងចែកមត៌កតាមការព្រមព្រៀង

កម្មវត្ថុនៃការផ្ទេរតាមរយៈសន្តតិកម្មគឺសិទ្ធិ និងកាតព្វកិច្ចដែលមានលើទ្រព្យសម្បត្តិរបស់មតកជន។ ទ្រព្យសម្បត្តិ មានន័យថាទូលាយ ដែលវាអាចសំដៅលើ សិទ្ធិប្រត្យក្ស ជាអាទិ៍ កម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ឬក៏អាចសំដៅលើ សិទ្ធិលើបំណុល ឬសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ដែលត្រូវបានទទួលស្គាល់ដោយច្បាប់ពិសេស ដូចជាសិទ្ធិបេតិកភណ្ឌនៃស្នាដៃអក្សរសាស្ត្រ។ល។ ហេតុនេះ ល័ក្ខខ័ណ្ឌទម្រង់ដើម្បីបង្កើតអានុភាព និងល័ក្ខខ័ណ្ឌតតាំងនៃការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀត តាមរយៈការពិភាក្សា ក៏មានលក្ខណៈខុសគ្នា អាស្រ័យ

[137] មាត្រា ១១៨៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[138] មាត្រា ១២៦៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[139] មាត្រា ១២៦៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[140] មាត្រា ១១៤៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

លើប្រភេទនៃសិទ្ធិទាំងនោះ។ នៅក្នុងចំណុចនេះ យើងនឹងសិក្សាលើទម្រង់នៃការពិភាក្សា ដើម្បីបង្កើតអានុភាព និងល័ក្ខខ័ណ្ឌតតាំងនៃការផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិជាមត៌ក។

**២.៣.១.១. កម្មសិទ្ធិអចលនវត្ថុ**

កម្មសិទ្ធិគឺជាសិទ្ធិប្រត្យក្សមួយដែលត្រូវផ្ទេរតាមរយៈសន្តតិកម្ម។ មាត្រា១២៦៦ ថ្មី នៃក្រមរដ្ឋប្បវេណី បានកំណត់នូវល័ក្ខខ័ណ្ឌទម្រង់ដែលចាំបាច់ត្រូវបំពេញ ដើម្បីបង្កើតអានុភាពនៃការពិភាក្សា។ ដោយហេតុថា កម្មសិទ្ធិលើអចលនវត្ថុ តម្រូវឲ្យធ្វើការផ្ទេរតាមរយៈលិខិតយថាភូត ហេតុនេះការពិភាក្សាបែងចែកមត៌កជាអចលនវត្ថុ ត្រូវមានការអន្តរាគមន៍ពីសារការី និងមន្ត្រីសាធារណៈដែលមានសមត្ថកិច្ច។

**២.៣.១.២. ការបែងចែកសិទ្ធិលើបំណុល**

ល័ក្ខខ័ណ្ឌបង្កើតអានុភាពនៃការផ្ទេរសិទ្ធិលើបំណុលត្រូវគោរពតាមត្រា ៥០២ នៃក្រមរដ្ឋប្បវេណី។ មាត្រានេះបានផ្តល់នូវល័ក្ខខ័ណ្ឌសាមញ្ញមួយ ដោយតម្រូវឲ្យមានការព្រមព្រៀងតែប៉ុណ្ណោះ ដើម្បីបង្កើតអានុភាពនៃអនុប្បទានសិទ្ធិលើបំណុល។ ប៉ុន្តែដើម្បីអាចឲ្យអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ យកទៅតតាំងជាមួយកូនបំណុល ឬតតិយជន បានលុះត្រាតែបានបំពេញល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះដែលអាចជា ការធ្វើកិច្ចសន្យាជាលិខិតដែលមានកាលបរិច្ឆេទស្ថាពរ ឬការជូនដំណឹងទៅកូនបំណុលដោយលិខិតដែលមានកាលបរិច្ឆេទស្ថាពរ។ ទោះបីជាយ៉ាងនេះក្តី បើសិនជាការពិភាក្សាបែងចែក ផ្ទុយពីចំណែកមត៌ករបស់សហសន្តតិជន នោះសហសន្តតិជន ត្រូវធ្វើការជូនដំណឹងទៅកាន់កូនបំណុល ដើម្បីអាចយកលទ្ធផលនៃការពិភាក្សាបែងចែកមត៌កតតាំងជាមួយកូនបំណុលបាន។[141]

**២.៣.១.៣. ការបែងចែកសិទ្ធិប្រត្យក្សផ្សេងទៀត**

ក្រៅពីកម្មសិទ្ធិលើអចលនវត្ថុ សិទ្ធិប្រត្យក្សផ្សេងទៀតជាអាទិ៍ កម្មសិទ្ធិលើចលនវត្ថុ សិទ្ធិជួលអចិន្ត្រៃយ៍ ត្រូវបង្កើតអានុភាពនៅពេលមានការព្រមព្រៀង។[142] ពុំមានការទាមទារទម្រង់អ្វីពិសេសឡើយចំពោះការផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិទាំងនេះ។ ប៉ុន្តែដើម្បីបង្កើតនូវល័ក្ខខ័ណ្ឌតតាំងនៃការផ្ទេរសិទ្ធិប្រត្យក្សទាំងនេះ ត្រូវគោរពតាមល័ក្ខខ័ណ្ឌដែលមានកំណត់ក្នុងមាត្រា ១៣៤ នៃក្រមរដ្ឋប្បវេណី។

**២.៣.២. វិធីសាស្ត្រក្នុងការបែងចែក**

ការបែងចែកមត៌ក គឺជាការបំបាត់នូវស្ថានភាពអវិភាគនៃទ្រព្យសម្បត្តិជាមត៌កដោយហេតុថាប្រសិនបើមតកជនមិនបានកំណត់ពីវិធីបែងចែកមត៌ក ហេតុនេះសហសន្តតិជន និងអច្ច័យលាភីសកល នឹងត្រូវបន្តស្ថានភាពអវិភាគនៃទ្រព្យសម្បត្តិនេះ ហើយស្ថានភាពមួយចំនួន មិនមានលក្ខណៈសមស្របក្នុងការរក្សាទុកស្ថាន

[141] មាត្រា ១២៧៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[142] មាត្រា ១៣៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

ភាព អវិភាគឡើយ ដូចជាដីធ្លី ទ្រព្យសម្បត្តិជាចលនវត្ថុ ឬសិទ្ធិលើបំណុល។ ក្នុងគោលបំណងនេះការពិភាក្សាបែងចែកត្រូវធ្វើឡើងតាមវិធីសាស្រ្តដូចខាងក្រោម។

**២.៣.២.១.សិទ្ធិអាទិភាពរបស់សហព័ទ្ធ**

សហព័ទ្ធជាសន្តតិជន ការពិភាក្សាបែងចែកទ្រព្យសម្បត្តិ ត្រូវពិចារណាអំពីសិទ្ធិអាទិភាពរបស់សហព័ទ្ធក្នុងការទទួលបានចំណែកអវិភាគជាមត៌ក។ ដោយហេតុថា ទ្រព្យសម្បត្តិជាមត៌កភាគច្រើន ស្ថិតនៅក្នុងស្ថានភាពអវិភាគជាមួយសហព័ទ្ធ ហេតុនេះគប្បីឲ្យសហព័ទ្ធធ្វើលទ្ធកម្មនូវចំណែកអវិភាគជាមួយនឹងមតកជន រហូតដល់គ្រប់ចំណែកមត៌ករបស់សហព័ទ្ធនោះ។[143] ក្នុងករណីនេះ សារការីត្រូវបើកលទ្ធភាពឲ្យមានការពិភាក្សាក្នុងចំណោមសហសន្តតិជន និងគោរពឆន្ទៈរបស់សហព័ទ្ធរហូតដល់គ្រប់ចំណែកមត៌ករបស់សហព័ទ្ធនោះ។

**២.៣.២.២.ការបង់ប្រាក់សម្រួល**

ក្នុងស្ថានភាពដែលការបែងចែកទ្រព្យសម្បត្តិ អាចបណ្តាលឲ្យមានការធ្លាក់ចុះនៃតម្លៃ សហសន្តតិជនអាចព្រមព្រៀងគ្នាឲ្យសហសន្តតិជនណាម្នាក់ធ្វើលទ្ធកម្មលើទ្រព្យសម្បត្តិនោះ រហូតដល់គ្រប់ចំណែកមត៌ករបស់ជននោះ ហើយបើតម្លៃនៃទ្រព្យសម្បត្តិនោះលើសពីចំណែកមត៌កដែលសហសន្តតិជននោះត្រូវទទួល (តាមច្បាប់ ឬមតកសាសន៍) សហសន្តតិជនដែលបានធ្វើលទ្ធកម្មនោះ ត្រូវបង់ប្រាក់សម្រួលដល់សហសន្តតិជនផ្សេងទៀត។

**២.៣.២.៣. ការពិចារណាស្ថានភាពជុំវិញ**

នៅក្នុងការពិភាក្សាបែងចែកមត៌កដោយសហសន្តតិជន សារការីក៏ត្រូវពិចារណាអំពីស្ថានភាពជុំវិញនៃទ្រព្យសម្បត្តិ និងសហសន្តតិជនផងដែរ។ មាត្រា ១២៦៧ កថាខណ្ឌទី១ បានតម្រូវឲ្យការពិភាក្សាបែងចែកត្រូវធ្វើឡើងដោយពិចារណាលើប្រភេទលក្ខណៈនៃវត្ថុ សិទ្ធិដែលមានក្នុងមត៌ក ឬអាយុ មុខរបរ ស្ថានភាពផ្លូវកាយ និងផ្លូវចិត្ត ស្ថានភាពជីវភាពរបស់សហសន្តតិជននីមួយៗ។

**២.៣.២.៤.ការផ្លាស់ប្តូរភាគបន្ទុកកាតព្វកិច្ច**

សហសន្តតិជន ត្រូវទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចតាមសមាមាត្រនៃចំណែកមត៌ក។[144] រាល់ការពិភាក្សាបែងចែកមត៌ក ដែលមានកម្មវត្ថុជាការផ្លាស់ប្តូរភាគបន្ទុកកាតព្វកិច្ចត្រូវបានហាមឃាត់ដោយច្បាប់ លើកលែងតែមានការយល់ព្រមពីម្ចាស់បំណុល ដោយហេតុថាលទ្ធផលនៃការផ្លាស់ប្តូរនឹងជះឥទ្ធិពលដល់លទ្ធភាពនៃការទទួលបានការសងរបស់ម្ចាស់បំណុល។ សារការីត្រូវបដិសេធមិនផ្តល់យថាភូតភាពចំពោះ

---

[143] មាត្រា ១២៦៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[144] មាត្រា ១១៤៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

ការពិភាក្សាបែងចែកមត៌ក ដែលមានខ្លឹមសារឲ្យសហសន្តតិជនណាម្នាក់ទទួលបន្ទុកកាតព្វកិច្ចទាំងស្រុង ឬផ្លាស់ប្តូរភាគ លុះត្រាតែម្ចាស់បំណុលបានយល់ព្រមចំពោះការផ្លាស់ប្តូរនោះ។

## ២.៤. បញ្ហាប្រឈមរបស់វិជ្ជាជីវៈសារការីក្នុងសន្តតិកម្ម

វិជ្ជាជីវៈសារការី ជាវិជ្ជាជីវៈមួយដែលកំពុងដំណើរការឆ្ពោះទៅរកការអភិវឌ្ឍ និងរីកចម្រើនក្នុងការបណ្តុះបណ្តាលនៅក្នុងផ្នែកនេះ ក្រោមកិច្ចខិតខំប្រឹងប្រែងដែលមានក្រសួងយុត្តិធម៌ជាអាណាព្យាបាលក្នុងនោះ ហើយដែលបង្កើតឲ្យមាននូវវិជ្ជាជីវៈសារការីសារជាថ្មីនេះឡើង ចាប់តាំងពីការបង្កើតរហូតដល់ការដាក់ឲ្យអនុវត្តក្រមរដ្ឋប្បវេណី និងការរៀបចំតាក់តែងនូវសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈសារការី ព្រមទាំងការបណ្តុះបណ្តាលនូវធនធានសារការីនេះដោយប្រសិទ្ធិភាព និងគុណភាពខ្ពស់ ដោយមានរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការជាសេនាធិការផងដែរ។ ថ្វីត្បិតតែ នៅក្នុងអន្តរកាលវិជ្ជាជីវៈសារការីកំពុងតែមានការអភិវឌ្ឍល្អក៏ពិតមែន ប៉ុន្តែការអនុវត្តមុខងាររបស់សារការីនៅតែមានបញ្ហាជួបប្រទះមួយចំនួនដដែរ។ នៅក្នុងចំណុចនេះ នឹងធ្វើការបកស្រាយអំពីបញ្ហាចំនួនពីររួមមាន កង្វះធនធានសារការី និងកង្វះខាតក្របខ័ណ្ឌគតិយុត្ត។

### ២.៤.១. កង្វះធនធានសារការី

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានបង្កើតឡើង ស្របពេលជាមួយប្រទេសកម្ពុជាកំពុងមានស្ថានភាពមួយដែលសារការីមានចំនួនតិចតួចបំផុត។ បន្ថែមពីនេះទៅទៀត ក៏បង្ហាញពីសញ្ញាណដែលគួរឲ្យព្រួយបារម្ភអំពីកង្វះខាតនូវលទ្ធភាពក្នុងការអនុវត្តក្រមរដ្ឋប្បវេណីឲ្យបានពេញលេញ និងប្រកបដោយប្រសិទ្ធិភាព។ ដូចច្នេះហើយ បានជានាំឲ្យមានការតែងតាំងនូវមន្ត្រីទទួលបន្ទុកផ្នែកកិច្ចការសារការីដូចដែលបានកំណត់នៅក្នុង មាត្រា ១០ នៃក្រមរដ្ឋប្បវេណី សម្រាប់រយៈពេលអន្តរកាលដែលមានច្បាប់លក្ខន្តិកៈសារការីនេះផងដែរ។ មានតែមន្ត្រីទទួលបន្ទុកផ្នែកកិច្ចការសារការីមួយចំនួនប៉ុណ្ណោះដែលបានបំពេញវិជ្ជាជីវៈសារការីនេះ។

### ២.៤.២. កង្វះខាតក្របខ័ណ្ឌគតិយុត្ត

នៅក្នុងវិជ្ជាជីវៈសារការី គឺកំពុងមានការជួបប្រទះនឹងបញ្ហាកង្វះខាតនូវផ្នែកលិខិតបទដ្ឋានគតិយុត្តក្នុងការលើកស្ទួយនូវវិជ្ជាជីវៈរបស់ខ្លួន។ ទោះបីជាមាន ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យស្តីពីការបង្កើតមន្ទីរសារការីក្តី ក៏ពុំគ្រប់គ្រាន់ក្នុងការគ្រប់គ្រងវិជ្ជាជីវៈសារការីទាំងមូលនោះឡើយ។ ដោយសារតែនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា គឺពុំបានកំណត់នូវមុខងារជាក់លាក់ច្បាស់លាស់អំពីវិជ្ជាជីវៈសារការីឡើយ ព្រោះក្រមរដ្ឋប្បវេណីជាច្បាប់សារធាតុមួយដែលបទបញ្ញត្តិទាំងនោះគឺចែងទាក់ទងទៅនឹងទំនាក់ទំនងបុគ្គលឯកជនក្នុងនោះរួមមាន ទ្រព្យសម្បត្តិ និងញាតិជាអាទិ៍។ ថ្វីត្បិតតែមានអនុក្រឹត្យស្តីពីការបង្កើតមន្ទីរសារការីក៏ដោយ ក៏ប៉ុន្តែនៅក្នុងអនុក្រឹត្យនេះគឺបានត្រឹមតែកំណត់អំពីមុខងារក៏ដូចជាតួនាទីដែលរដ្ឋបានប្រគល់ឲ្យសារការីប៉ុណ្ណោះ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ដោយមានការឆ្លងកាត់តាមរយៈការស្រាវជ្រាវយ៉ាងលម្អិត យើងអាចធ្វើការសន្និដ្ឋានទៅលើបានថា សន្តតិកម្មត្រូវបានលេចឡើងនៅក្រមរដ្ឋប្បវេណីសង្គមចាស់ដែលមានទម្រង់ទូលំទូលាយ ប៉ុន្តែក្នុងបញ្ញត្តិដែលមានចែងអំពីសន្តតិកម្មពុំបានបង្ហាញឲ្យឃើញអំពីវត្តមានរបស់សារការីឡើយ។ យ៉ាងណាមិញ សារការីត្រូវបានចែងជាលើកដំបូងក្រោមព្រះរាជក្រមន.ស ៩១០ ស្តីពីសារការីជាមន្ត្រីសាធារណៈ។ ក្រោយមានការវិវត្តនៃច្បាប់សន្តតិកម្មពីមួយសម័យកាលទៅមួយសម័យកាល ក៏ដូចជាការប្រែប្រួលនៃបរិបទសង្គម ក្នុងឆ្នាំ២០០៧ក្រោមការដឹកនាំរបស់ក្រសួងយុត្តិធម៌ប្រទេសកម្ពុជា និងប្រទេសជប៉ុន សារការីត្រូវបានរំលេចនូវវត្តមានក្នុងបញ្ញត្តិសន្តតិកម្ម ដោយទទួលបាននៅតួនាទីក្នុងការតាក់តែងមតកសាសន៍ ការប្រតិបត្តិ ក៏ដូចជាការចូលរួមពិភាក្សាជាមួយម្ចាស់បណ្តាំក្នុងការបែងចែកមត៌កផងដែរ។ នៅក្នុងសន្តតិកម្ម ការចាប់ផ្តើមគឺត្រូវបានកំណត់ក្រោយពេលដែលមតកជនទទួលមរណៈភាព នាពេលនោះបុគ្គលដែលនឹងទទួលបាននូវទ្រព្យសម្បត្តិ ក៏ដូចជាកាតព្វកិច្ចបន្តពីមតកជនគឺសន្មតថាជាសន្តតិជន។ យោងតាមសន្តតិកម្មដោយច្បាប់ លំដាប់សន្តតិជនត្រូវបានកំណត់ទៅតាមឋានៈ ប៉ុន្តែនៅក្នុងល័ក្ខខ័ណ្ឌដែលមតកជនមានបំណងក្នុងការកំណត់ ឬទៅតាមឆន្ទៈរបស់ខ្លួនក្នុងការបែងចែក នោះមតកជនអាចធ្វើការបង្កើតមតកសាសន៍បានតាមទម្រង់ទូទៅដែលកំណត់ដោយច្បាប់ដូចជា មតកសាសន៍ដោយលិខិតយថាភូត មតកសាសន៍ដោយលិខិតឯកជន មតកសាសន៍ដោយលិខិតសម្ងាត់ និងតាមទម្រង់បន្ថែមដូចជា មតកសាសន៍នៃជនក្រោមអាណាព្យាបាល មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់ជីវិត[145] មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង[146] និងការធ្វើមតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន។

សន្តតិកម្មដោយមតកសាសន៍ចាំបាច់តម្រូវទាមទារឱ្យមានការចូលរួមពីសារការីនៅក្នុងដំណើរការនៃការបង្កើតមតកសាសន៍នីមួយៗ រួមជាមួយនឹងការបំពេញកាតព្វកិច្ចផ្សេងៗតាមច្បាប់កំណត់។ ល័ក្ខខ័ណ្ឌនៃការបង្កើតមតកសាសន៍នោះ គឺត្រូវកំណត់អំពីសមត្ថភាពក្នុងការធ្វើមតកសាសន៍ លក្ខណៈសម្បត្តិរបស់សាក្សី ការកំណត់ចំណែក ឬ ការកំណត់វិធីបែងចែកមត៌ក ការកំណត់អំពីអច្ច័យទាន ការកំណត់អំពីសន្តតិជន និងអច្ច័យលាភីជំនួស ហើយ សារការីក៏មានតួនាទីជាអ្នកពិគ្រោះនិងផ្តល់យោបល់ដល់មតកជនមុនពេលមានការចាប់ផ្តើមតាក់តែងមតកសាសន៍ឡើង ដើម្បីបញ្ចៀសពីការរំលោភសិទ្ធិរបស់សន្តតិជន ជាអាទិ៍ សិទ្ធិលើភាគបម្រុង។ ក្រោយពេលដែលមតកសាសន៍ត្រូវបានបង្កើតទៅតាមបញ្ញត្តិច្បាប់កំណត់ សារការីមានកាតព្វកិច្ចក្នុងការថែរក្សា និងតម្កល់ទុកនូវបណ្តាំនោះ ជាកិច្ចធានាដល់សុវត្ថិភាពនៃឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ។ ការតម្កល់ទុក

[145] មាត្រា ១១៧៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[146] មាត្រា ១១៧៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

នោះគឺត្រូវរក្សានៅមន្ទីរសារការីនីមួយៗ ប៉ុន្តែពុំមានបញ្ញត្តិណាមួយបានកំណត់ជាល័ក្ខខ័ណ្ឌដាច់ខាតសម្រាប់ការតម្កល់របស់សារការីឡើយ។ ច្បាប់ក៏ពុំបានចែងបញ្ញត្តិណាមួយថា សារការីមានមុខងារជាអ្នកប្រតិបត្តិមតកសាសន៍ឡើយ តែមតកជនមានជម្រើសក្នុងការរើសយកធ្វើអ្នកប្រតិបត្តិបណ្តាំខ្លួនបាន ឬ អាចទុកអោយតុលាការជាកំណត់ចែង។ ក្នុងករណីសារការីត្រូវបានជ្រើសតាំងជាអ្នកប្រតិបត្តិ សារការីមានសិទ្ធិក្នុងការបដិសេធមុនបំពេញមុខងារ ដោយការស្នើសុំជាលាយលក្ខណ៍អក្សរ ដើម្បីសម្រួលដល់សន្តតិជនក្នុងការការដាក់ពាក្យស្នើរសុំទៅកាន់តុលាការ។ នៅពេលដែលមានការប្រតិបត្តិមតកសាសន៍ ប្រសិនជាមតកជនផ្តល់អាទិភាពក្នុងការបែងចែកមត៌កដល់អ្នកប្រតិបត្តិ នោះវិសាលភាពក្នុងការបែងចែកត្រូវកំណត់តាមឆន្ទៈរបស់ម្ចាស់បណ្តាំ។

ជារួមមកយើងអាចសន្និដ្ឋានបានថា សារការីមានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើមតកសាសន៍។ ការប្រតិបត្តិមតកសាសន៍ ត្រូវបានចូលរួមអន្តរាគមន៍ដោយវត្តមានរបស់សារការី ដែលត្រូវបានកំណត់ជាចំណែកដ៏សំខាន់ចាប់ពីការពិភាក្សាការបែងចែកទ្រព្យ ដំណើរក្នុងការតាក់តែង រហូតដល់ការបែងចែកមត៌ក។ ជាក់ស្តែងក្នុងការផ្តល់នូវនីតិសម្បទាដោយច្បាប់ចំពោះសារការីបានបង្ហាញអោយឃើញថា ជាការផ្តល់នូវទំនុកចិត្ត ក៏ដូចជាការលើកកម្ពស់នូវតម្លៃនៃលិខិតមត៌កសាសន៍ផងដែរ។ ចាប់ផ្តើមពីការចូលរួមពិភាក្សាពាក់ព័ន្ធនឹងការបែងចែកមត៌កទៅតាមឆន្ទៈរបស់ម្ចាស់បណ្តាំ ការតាក់តែងមតកសាសន៍ឡើង ការធានារក្សានូវឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ ការថែរក្សាទុកនូវមតកសសាន៍ ការធានាភាពសម្ងាត់នៃបណ្តាំ រហូតដល់ការប្រតិបត្តិនិងការបែងចែក គឺការដែលបង្ហាញឱ្យឃើញពីភាពចាំបាច់នៃវត្តមានរបស់សារការីនៅក្នុងសន្តតិកម្ម ដែលពុំអាចខ្វះបាន។ ដោយមានការផ្តល់ទំនុកចិត្តខ្ពស់ទៅលើលិខិតមតកសាសន៍ ដែលតាក់តែងឡើងស្របតាមនីតិវិធីច្បាប់ដោយសារការី ច្បាប់បានអនុញ្ញាតអោយមតកសាសន៍មានការអនុវត្តបានដោយមិនចាំបាច់មានការឆ្លងកាត់ការត្រួតពិនិត្យបញ្ជាក់ ឬ ឆ្លងកាត់នីតិវិធីតុលាការសម្រាប់ការបែងចែកឡើយ។ ហេតុនេះការចំណាយពេលវេលាការដោះស្រាយវិវាទ និងការចំណាយផ្សេងៗក៏ត្រូវបានកាត់បន្ថយរវាងចំណោមសហសន្តតិជនផងដែរ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានបញ្ចប់នូវការស្រាវជ្រាវ និងតាក់តែងនូវអត្ថបទសារណា ក្រោមប្រធានបទ «**តួនាទីសារការី ក្នុងសន្តតិកម្ម**» នេះហើយ យើងអាចធ្វើការសង្កេតបានថា សារការីមានតួនាទីយ៉ាងសំខាន់ក្នុងការតាក់តែងមតកសាសន៍ មិនតែប៉ុណ្ណោះ ទន្ទឹមនឹងការអភិវឌ្ឍផ្នែកច្បាប់នៅក្នុងប្រទេសកម្ពុជា វិស័យសារការីក៏ដូចជាការបង្កើតមតកសាសន៍ ត្រូវបានយល់ដឹងនិងទទួលស្គាល់យ៉ាងទូលំទូលាយផងដែរ។ យើងខ្ញុំបានសង្កេតឃើញថា មួយចំណែកធំនៃការបែងចែកមត៌ក ត្រូវបានធ្វើឡើងតាមរយៈមតកសាសន៍ ដែលចូលរួមអន្តរាគមន៍ដោយសារការី ក្រោមមូលហេតុនៃការផ្តល់នូវទំនុកចិត្ត និងការទទួលស្គាល់ដោយច្បាប់ពីលិខិតមតកសាសន៍នេះ។ ការតាក់តែងលិខិតមតកសាសន៍ត្រូវបាននឹងកំពុងមានការគាំទ្រ និងជ្រើសយកជានីតិវិធីក្នុងការកំណត់ចែកមត៌កតាមឆន្ទៈកំណត់នៃមតកជន។ ជាក់ស្តែងច្បាប់បានកំណត់អោយតម្លៃទៅលើលិខិតយថាភូតរបស់សារការីស្មើនឹងសាលក្រមរបស់តុលាការ នោះមានន័យថា ច្បាប់បានអនុញ្ញាតអោយមតកសាសន៍មានការអនុវត្តបានដោយមិនចាំបាច់មានការឆ្លងកាត់កាតត្រួតពិនិត្យបញ្ជាក់ឬឆ្លងកាត់នីតិវិធីតុលាការសម្រាប់ការបែងចែកឡើយ។

ផ្អែកតាមការឱ្យតម្លៃនិងផ្តល់ទំនុកចិត្តលើលិខិតមតកសាសន៍ យើងអាចនិយាយបានថា នៅក្នុងការបង្កើតមតកសាសន៍ សារការីត្រូវបំពេញតួនាទីដោយមានការយកចិត្តទុកដាក់ខ្ពស់ចំពោះរាល់ភារកិច្ច ដើម្បីជាការធានាថាមតកសាសន៍ត្រឹមត្រូវតាមល័ក្ខខ័ណ្ឌទម្រង់ ភាពច្បាស់លាស់នៃខ្លឹមសារ ភាពត្រឹមត្រូវនៃឆន្ទៈ ការធានាថែរក្សានិងសុវត្ថិភាពមតកសាសន៍ ក៏ដូចជាការបង្ការវិវាទរវាងចំណោមសហសន្តតិជនផងដែរ។ ទន្ទឹមនឹងគុណសម្បត្តិជាច្រើននៃលិខិតមតកសាសន៍ និងការអន្តរាគមន៍របស់សារការី យើងខ្ញុំបានកំណត់សម្គាល់ឃើញនូវបញ្ហាប្រឈមមួយចំនួន ដែលវិជ្ជាជីវៈសារការីជួបប្រទះក្នុងការអនុវត្តតួនាទី ជាអាទិ៍ កង្វះធនធាន និងកង្វះខាតលិខិតបទដ្ឋានគតិយុត្ត។ នៅក្នុងអំឡុងឱកាសនេះផងដែរ យើងខ្ញុំសូមលើកឡើងជាសំណូមពរជូនចំពោះស្ថាប័នពាក់ព័ន្ធ បង្កើតច្បាប់ស្តីពីលក្ខន្តិកៈសារការី ដើម្បីជាការសម្រួលដល់ការបំពេញការងារ ប្រកបដោយនីត្យានុកូលភាព ព្រមទាំងការបង្កើតអោយមានការចុះបញ្ជី និងការតម្កល់មតកសាសន៍អោយបានច្បាស់លាស់ជៀសវាងពីការមានបញ្ហាក្នុងការចុះបញ្ជីបណ្តាំ និងជម្រុញអោយមានការទទួលស្គាល់អោយកាន់តែមានភាពទូលំទូលាយនូវលិខិតដែលសារការីបង្កើតឡើងស្របតាមច្បាប់ ដើម្បីលើកកម្ពស់។

ជាចុងក្រោយ ក្នុងនាមជាទំពាំងស្នងឬស្សីដល់ជាតិ យើងខ្ញុំសង្ឃឹម ជឿទុកចិត្ត និងរំពឹងយ៉ាងមុតមាំថា រាជរដ្ឋាភិបាលកម្ពុជា និងមន្ត្រីគ្រប់ស្រទាប់ជាន់ថ្នាក់ រួមទាំងប្រជាពលរដ្ឋខ្មែរទាំងមូល នឹងបន្តពង្រីក និងពង្រឹងវិស័យច្បាប់ ទាំងក្នុងមែកធាងសាធារណៈ ទាំងក្នុងមែកធាងឯកជន ឱ្យបន្តដំណើរឆ្ពោះទៅមុខដោយភាពជោគជ័យ ភាពរុងរឿង ភាពទាន់សម័យ និងភាពដែលអាចអនុវត្តបានជាប្រយោជន៍រួមនៃជាតិទាំងមូលថែមទៀតផង៕

# ឯកសារយោង

# បញ្ជីឯកសារយោង

## ក. យុត្តិសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តអន្តរជាតិ

១. ច្បាប់ស្តីពីក្រមសីលធម៌សារការីប្រទេសម៉ុងតេណេហ្គ្រោនៃក្រុមប្រឹក្សាសហភាពអឺរ៉ុប, ប្រកាសឱ្យប្រើនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០១២។

២. ក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុន, នស/រកម/១២០៧/០៣០, ប្រកាសឱ្យប្រើនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ ១៨៩៦។

៣. ច្បាប់ស្តីអំពីសារការីនៃប្រទេសជប៉ុន, ប្រកាសឱ្យប្រើនៅថ្ងៃទី១៤ ខែមេសា ឆ្នាំ ១៩០៨។

៤. គោលការណ៍គ្រឹះនៃប្រព័ន្ធសារការីឡាតាំង (Fundamental Principles of the Latin Type Notarial System) អនុម័តដោយមហាសន្និបាតនៃសមាជិកសហភាពសារការីឡាតាំងអន្តរជាតិ (UINL) នាថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ ២០០៥។

## ខ. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាតិ

៥. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣។

៦. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/១២០៧/០៣០, ប្រកាសឱ្យប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧។

៧. ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, នស/រកម/០៥១១/០០៧, ប្រកាសឱ្យប្រើនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០១១។

៨. ព្រះរាជក្រម ៩១០ ន.ស ស្តីពីសារការីជាមន្ត្រីសាធារណៈ ប្រកាសឱ្យប្រើនៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ ១៩៥៤។

៩. ច្បាប់ភូមិបាល, ក្រឹតច្បាប់លេខ ១០០ ក្រ, ប្រកាសឱ្យប្រើនៅថ្ងៃទី១១ ខែសីហា ឆ្នាំ ១៩៩២។

១០. ច្បាប់ភូមិបាល, នស/រកម/០៨០១/១៤, ប្រកាសឱ្យប្រើនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ ២០០១។

១១. ច្បាប់ស្តីពីបរធនបាលកិច្ច, នស/រកម/០១១៩/០០២, ប្រកាសឱ្យប្រើនៅថ្ងៃទី០២ ខែមករា ឆ្នាំ ២០១៩។

## គ. សៀវភៅដែលបានបោះពុម្ពផ្សាយ

១២. ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ៦ គន្ថី៨-គន្ថី៩, ក្រសួងយុត្តិធម៌, បោះពុម្ព ឆ្នាំ ២០១០។

**ឃ. អត្ថបទស្រាវជ្រាវ**

១៣. អត្ថបទរបស់ Hammond W. A. ស្ដីអំពី តើការជាសះស្បាយមួយរយៈពេលកើតមានដែរឬទេ (Do lucid intervals exist?), The Journal of Nervous and Mental Disease (២០១៣) ។

១៤. The Significance of the Notary and His Office in the Countries Associated in the Union International du Notariat Latin, International Lawyer, ខែតុលា ឆ្នាំ១៩៧១, Vol 5, លេខ៤, ទំព័រ ៧៥២។

**ខ. គេហទំព័រផ្លូវការ**

១៥. និយមន័យ LUCID INTERVAL, ផ្សព្វផ្សាយដោយក្រុមប្រឹក្សាអ្នកច្បាប់តាមការបកប្រែឯកសារច្បាប់ដោយអ្នកមានវិជ្ជាជីវៈ, [បានចូលមើលថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១]
តំណ៖ https://www.legal-lingo.net/lucid-interval ។

១៦. ក្រមសីលធម៌ និងវិធានរៀបចំសម្រាប់សារការី, ផ្សព្វផ្សាយដោយសហភាពសារការីឡាតាំងអន្តរជាតិ, [បានចូលមើលថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១]
តំណ៖ https://www.uinl.org/en_GB/organizacion-de-la-funcion ។

១៧. របាយកាណ៍ករណីសិក្សា ស្ដីពីប្រវត្តិនៃការប៉ះទង្គិចក្បាល រួមមានការជាសះស្បើយមួយរយៈពេល (History of an abusive head trauma including a lucid interval and a retinal hemorrhage is most likely false.), ផ្សព្វផ្សាយដោយមជ្ឈមណ្ឌលជាតិសម្រាប់ព័ត៌មានបច្ចេកវិទ្យាជីវបច្ចេកវិទ្យារបស់សហរដ្ឋអាមេរិក, [បានចូលមើលថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១]
តំណ៖ https://pubmed.ncbi.nlm.nih.gov/23896724 ។

# ឧបសម្ព័ន្ធ

# បញ្ជីរាយនាមឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ១៖ ព្រះរាជក្រម លេខ ៩១០ ន.ស ស្ដីពីបទបញ្ញត្តិគ្រឹះពាក់ព័ន្ធនឹង
វិជ្ជាជីវៈសារការី

ឧបសម្ព័ន្ធ ២៖ ច្បាប់ស្ដីបរធនបាលកិច្ច នស/រកម/០១១៩/០០២

ឧបសម្ព័ន្ធ ៣៖ អនុក្រឹត្យ លេខ ២០៣ អនក្រ.បក ស្ដីពីការបង្កើតមន្ទីរសារ
ការីមេគន្លងនៃព្រះរាជាណាចក្រកម្ពុជា

ឧបសម្ព័ន្ធ ៤៖ ឯកសារចម្លងនៃមតកសាសន៍ដោយលិខិតឯកជន

ឧបសម្ព័ន្ធ ៥៖ ឯកសារចម្លងនៃមតកសាសន៍ដោយលិខិតយថាភូត

ឧបសម្ព័ន្ធ ៦៖ ឯកសារចម្លងនៃលិខិតបញ្ជាក់ពីការតម្កល់ទុកមតកសាសន៍

ឧបសម្ព័ន្ធ ៧៖ ប្រកាសអន្តរក្រសួង ស្ដីពី នីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិ
ប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី

# ឧបសម្ព័ន្ធ ១
# ព្រះរាជក្រម លេខ ៩១0 ន.ស ស្តីពីបទបញ្ញត្តិគ្រឹះ
# ពាក់ព័ន្ធនឹងវិជ្ជាជីវៈសារការី

ច្បាប់ចម្លង
បណ្ណសារដ្ឋានជាតិ



ព្រះរាជក្រមលេខ ៩១០ ន.ស.

បានទ្រង់យល់ រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រ ។

បានទ្រង់យល់ ពិធីសារប្រគល់សមត្ថកិច្ចតុលាការ ចុះថ្ងៃទី ២៩ សីហា គ.ស. ១៩៥៣ ។

បានទ្រង់យល់ អនុសញ្ញាតុលាការ ចុះថ្ងៃទី ៩ កញ្ញា គ.ស. ១៩៥៣

បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ ៥២១ ន.ស. ចុះថ្ងៃទី ២៦ សីហា គ.ស. ១៩៥២ ស្ដីពីតាំងគណៈរដ្ឋមន្ត្រី ។

បានទ្រង់យល់ យោបល់នៃក្រុមប្រឹក្សាជាតិ ។

គណៈរដ្ឋមន្ត្រី បានយល់ព្រមផង ។

ត្រាស់បង្គាប់ ដូចមានខាងក្រោម:

១— បទបញ្ញត្តទូទៅ

មាត្រា១ – សារៈការីជាមន្ត្រីសាធារណៈ ដែលតាំងឡើងតាមព្រះរាជក្រឹត្យនៃរដ្ឋាភិបាល ដោយមានវត្ថុបំណង:

១– ទទួល និងធ្វើតាមត្រូវការ នូវលិខិតឬកិច្ចសន្យាទាំងឡាយដែលគូសញ្ញាត្រូវធ្វើឲ្យមាន ឬចូលចិត្តឲ្យមានចរិតជាពេញលក្ខណៈតាមផ្លូវច្បាប់ ដែលតែងតែមានដល់លិខិតរបស់រាជការកាន់អំណាចសាធារណៈ ។

២– ធ្វើបញ្ជាក់កាលបរិច្ឆេទនៃលិខិតនេះ ទទួលរក្សាលិខិតនេះ ទុកនឹងចេញឲ្យសេចក្ដីដើម ឬសេចក្ដីចម្លងលិខិតនេះ ។

ករណីយកិច្ចជាដើមរបស់សារៈការី គឺត្រូវបំភ្លឺ, ឲ្យដំណឹងដល់ខ្លួនគូសញ្ញាអំពីលិខិត ដែលអ្នកនេះបានធ្វើ ឬមានបំណងនឹងធ្វើ ហើយដោយខ្លួនជាមន្ត្រីសាធារណៈ

ត្រូវពិនិត្យឲ្យដឹងថា សេចក្ដីកត់ចុះក្នុងលិខិតទាំងនោះត្រឹមត្រូវតាមការពិត ។ ក្នុងករណីណាក៏ដោយមន្ត្រីនេះមិនអាចបំភាស់ពីការខុសត្រូវ ដោយថាខ្លួនគ្រាន់តែចម្លងកត់តាមសេចក្ដី ឬកត់តាមលិខិតរបស់គូសញ្ញាដោយឥតល្អៀងដើម្បីឲ្យពេញតាមលក្ខណៈច្បាប់ទេ ។

មាត្រា ២.– ព្រះរាជក្រមនេះ មិនធ្វើឲ្យខូចសិទ្ធិគូសញ្ញាណាដែលសុខចិត្តឲ្យអ្នករាជការ បញ្ជាក់លិខិតតាមទម្រង់ការដែលមានបញ្ញត្តនៅមាត្រា ៩៤៤ និងមាត្រាតទៅទៀតនៃច្បាប់ក្រមរដ្ឋប្បវេណី ព្រមទាំងគ្មានធ្វើឲ្យខូចផលនៃការបញ្ជាក់លិខិតនេះនោះឡើយ ។

មាត្រា ៣– ប៉ុន្តែតទៅមុខទៀត មានតែសារៈការីទេ ដែលអាចបញ្ជាក់តាមទម្រង់ការមុខក្រសួងខ្លួន នូវលិខិតគ្រប់ប្រភេទបើកាលណាលិខិតនេះ មានចុះទឹកប្រាក់ចំនួនស្មើនឹងលើសពី ២០០.០០០ រៀល ។

ពី ៥០,០០០ ទៅ ២០០ ០០០ រៀល ចៅហ្វាយស្រុកដែលមានសមត្ថកិច្ចតាមនាទី គឺស្រុកដែលជាទីកន្លែងអសង្ហារិមៈ ឬជាទីលំនៅគូសញ្ញាណាមួយអាចធ្វើសេចក្ដីបញ្ជាក់បាន ។

ចុះពី ៥០.០០០ រៀលមក ការបញ្ជាក់ធ្វើបានតាមកិច្ចស័គ្រគូសញ្ញា គឺមេឃុំ ឬចៅហ្វាយស្រុកតាមបញ្ញត្តិវគ្គទី ១ និងទី ២ នៃមាត្រា ៩៤៥ ក្រមរដ្ឋប្បវេណីក៏បាន ឬសារៈការីក៏បាន ។

បទបញ្ញត្តខាងដើមនៃមាត្រា ៣ នេះ ត្រូវបង្កើតទៅជាវគ្គទី ៣-៤-និង ៥ នៃមាត្រា ៩៤៥ ក្រមរដ្ឋប្បវេណី មួយទៀតពាក្យជាលំដាប់ខាងក្រោយនេះ ត្រូវបន្ថែមតពីសេចក្ដីបញ្ចប់វគ្គទី ១ នៃមាត្រា ៩៤៥ :

"តែត្រូវទុកសិទ្ធិ ឬការផ្ដាច់មុខ ដែលមានសំដែងក្នុងមាត្រានេះដើម្បីជាប្រយោជន៍ឲ្យមន្ត្រីសាធារណៈឯទៀត" ។

ពាក្យដូចខាងក្រោយនេះ ត្រូវបន្ថែមនៅខាងមុខវគ្គទី២នៃមាត្រា ៩៤៥ :

"ប៉ុន្តែកុំបីឲ្យសៅហ្មងដល់សិទ្ធិនិងការផ្តាច់មុខ ដែលសារៈការីមានសមត្ថកិច្ចត្រូវមានផង (គតនៅសល់គ្មានកែប្រែ) ។

មាត្រា ៤.— តទៅមុខ ច្បាប់អាចដាក់កំហិតឲ្យចុះបញ្ជាក់ចំពោះមុខសារៈការី តាមការគតព្វកិច្ច នូវកិច្ចសន្យាណាដែលច្បាប់បានកយឈ្មោះតាមកំរិត ។ ចំណែកកិច្ចសន្យាស្តីពីបញ្ចាំដាក់អសង្ហារិមៈជាធានា ដែលមាត្រា ១៣៦៥ នៃក្រមរដ្ឋប្បវេណី បញ្ញត្តថា ឲ្យចុះសេចក្តីបញ្ជាក់តាមលក្ខណៈច្បាប់បាក់ង ត្រូវបញ្ជាក់នៅចំពោះមុខសារៈការីដែរ បើពុំនោះទេកិច្ចសន្យានេះគ្មានដំឡៃក្នុងផ្លូវច្បាប់ ។

មួយទៀត ការមិនត្រូវធ្វើឲ្យខូចសិទ្ធិដែលមានមកហើយជារៀបរយ និងសិទ្ធិដែលព្រមបើកឲ្យភ្នាក់ងារកុងស៊ុល ឬភ្នាក់ងារទូតដែលតាំងនៅអមព្រះរាជរដ្ឋាភិបាល ឲ្យប្រតិបត្តិការជាសារៈការី ក្នុងព្រំដែនច្បាប់រដ្ឋៈជាតិ ឬក្នុងព្រំដែនអនុសញ្ញាទូតដែលរដ្ឋាភិបាលនៃភ្នាក់ងារនេះបានធ្វើជាមួយនឹងព្រះរាជរដ្ឋាភិបាល ។

ព្រះរាជរដ្ឋាភិបាល អាចប្រគល់អំណាចឲ្យទូត ឬកុងស៊ុលប្រទេសខ្មែរនៅបរទេស ឲ្យកាន់ការជាសារៈការី តាមទម្រង់ការដែលមានបញ្ញត្តក្នុងច្បាប់ខ្មែរ ចំពោះកិច្ចសន្យាទាំងអស់ ដែលមានខ្មែរជាគូសញ្ញា ។ ប៉ុន្តែការសុំឲ្យភ្នាក់ងារបញ្ជាក់លិខិតនោះ មិនមែនត្រូវបង្ខំទៅលើជនខ្មែរទេ ជនខ្មែរនេះអាចមានសេរីភាព នឹងឲ្យរាជការកាន់អំណាចមានសមត្ថកិច្ចនៃប្រទេសដែលខ្លួននៅធ្វើលិខិតចេញច្បាប់ឲ្យខ្លួនបាន ។

មាត្រា ៥.— ដោយអនុវត្តន៍តាមបទបញ្ញត្តខាងលើ មាត្រា ៩៦១ នៃក្រមរដ្ឋប្បវេណីត្រូវទុកជាមោឃៈ ហើយត្រូវយកសេចក្តីដូចតទៅនេះជំនួសវិញ ៖

"មាត្រា ៩៦១.— ត្រូវទុកដូចជាលិខិតដែលត្រូវបញ្ជាក់ ក្រៅពីលិខិតដែលមានបញ្ញត្តនៅមាត្រា ៩៤៤ នឹងមាត្រាតទៅទៀត :

១ — អស់ទាំងលិខិត ដែលគុងស៊ុល ឬទូតខ្មែរធ្វើនៅបរទេសតាមទម្រង់លក្ខណៈច្បាប់សារៈការីខ្មែរ ក្នុងព្រំដែនសេចក្ដីសម្រេចខ្មែរដែលឲ្យអំណាចទៅភ្នាក់ងារនេះ ។

២.— អស់ទាំងលិខិត ដែលមន្ត្រីសាធារណៈបានធ្វើតាមទម្រង់ច្បាប់គឺសារៈការី និងក្រឡាបញ្ជី នៃសារៈការីដែលរាជការបានតាំង ឬដែលបានអនុញ្ញាតឲ្យកាន់កាប់មុខក្រសួងតែងលិខិតពេញច្បាប់ក្នុងអាណាខេត្តព្រះរាជអាណាចក្រ បន្តទៅទៀតជាបណ្ដោះអាសន្ន ទាំងមានសម្រេចក្នុងរឿងខ្លួនក្រោយ ដែលបានប្រគល់សមត្ថកិច្ច ។

៣ — អស់ទាំងលិខិត ដែលរាជការកាន់អំណាចបរទេសមានសមត្ថកិច្ចបានបញ្ជាក់តាមទម្រង់ច្បាប់បរទេស ។

៤.— អស់ទាំងលិខិត ដែលគុងស៊ុល ឬទូតបរទេសដែលបានតាំង មករាជរដ្ឋាភិបាលជាត្រឹមត្រូវ បានបញ្ជាក់នៅប្រទេសខ្មែរ កាលបើគុងស៊ុលឬទូតនោះ កាន់កាប់មុខក្រសួងជាសារៈការី ក្នុងព្រំដែនច្បាប់សាធារណៈអន្តរជាតិ ឬដែលមានអនុសញ្ញាទូត ឬគុងស៊ុលភ្ជាប់រដ្ឋាភិបាលនៃភ្នាក់ងារនេះ និងព្រះរាជរដ្ឋាភិបាល ។

លិខិតដែលមានសំដែងនៅវគ្គទី ៣ និងទី ៤ នៃមាត្រានេះត្រូវមានសាលក្រមសាលាតុលាការខ្មែរបញ្ជាក់ផង ទើបទទួលរូបមន្តបរិវត្តន៍ខ្មែរបាន ។

## ២.— លក្ខណៈ ត្រូវតាំងឲ្យកាន់មុខក្រសួង ជាសារៈការី

មាត្រា ៦.— ត្រូវបង្កើតនៅភ្នំពេញ មន្ទីរសារៈការីមួយ ដែលអ្នកកាន់កាប់ត្រូវមានសមត្ថកិច្ច ដើម្បីចាត់ការមុខក្រសួងពេញអាណាខេត្តព្រះរាជអាណាចក្រ ។ តាមសេចក្ដីស្នើសុំនៃរដ្ឋមន្ត្រីក្រសួងយុត្តិធម៌, គណៈរដ្ឋមន្ត្រីអាចបន្ថែមព្រះរាជក្រឹត្យតាមត្រូវការឲ្យមន្ទីរសារៈការីមានចំនួនឡើងដល់ទៅប្រាំនៅក្នុងព្រះរាជអាណាចក្រទាំងមូល ។ ព្រះរាជក្រឹត្យដែលបង្កើតមន្ទីរជាថ្មី ត្រូវចង្អុលព្រំដែនខាងសមត្ថកិច្ចនៃមន្ទីរនោះផង ។

ថតចម្លង
បណ្ណសារដ្ឋានជាតិ



មាត្រា ៧.- បេក្ខជនដែលសុំកាន់តំណែងជាសារៈការី ត្រូវមានសញ្ជាតិជាខ្មែរ មានសិទ្ធិជាពលរដ្ឋនិងនយោបាយ, មានអាយុ ៣០ ឆ្នាំយ៉ាងតិច និងមានសញ្ញាបត្រ ដែលមានសំដែងនៅវគ្គទី ២ និងទី ៣ នៃមាត្រានេះ ។

បេក្ខជនដែលមានបរិញ្ញាបត្រច្បាប់ ឬថ្នាក់បណ្ឌិតច្បាប់ ត្រូវបានហាត់ធ្វើការ ពីរឆ្នាំនៅក្នុងមន្ទីរសារៈការី ដែលតាំងនៅប្រទេសខ្មែរ ឬក្នុងប្រទេសណាមួយ ក្នុងសហភាពបារាំង ។

រយៈពេលហាត់ធ្វើការនេះ ត្រូវឡើងដល់ទៅប្រាំឆ្នាំ ចំពោះបេក្ខជនដែលមានសមត្ថភាពច្បាប់ ឬមានសញ្ញាបត្រស្មើនឹងនេះ ព្រមទាំងបេក្ខជនដែលមានសញ្ញាបត្រវិជ្ជាយុត្តិធម្មសាស្ត្រនិងសេដ្ឋសាស្ត្ររបស់ជាតិ ។

មាត្រា ៨.- ប៉ុន្តែជាអន្តរៈបញ្ញត្តិ

១ ១.- ហើយក្នុងកំឡុងពេលមិនលើសពីបីឆ្នាំ គិតពីថ្ងៃប្រកាសឲ្យប្រើនូវព្រះរាជក្រមនេះ ដោយឥតគិតអំពីលក្ខណៈហាត់ធ្វើការ រដ្ឋាភិបាលអាចតាំងឲ្យកាន់តំណែងជាសារៈការី ពល់តែបេក្ខជនណាដែលបំពេញលក្ខណៈ, អាយុ, សញ្ជាតិ, និងសីលធម៌ពេញបរិបូណ៌តាមមាត្រា ៧- ហើយបើបេក្ខជននេះមានបរិញ្ញាបត្រច្បាប់ផង ។

១ ២ – បេក្ខជនណា ដែលមានត្រឹមតែសញ្ញាបត្រសមត្ថភាពច្បាប់ ឬមានសញ្ញាបត្រស្មើនឹងនេះ អាចតាំងក្នុងតំណែងសារៈការី ក្នុងកំណត់ពេលប្រាំឆ្នាំ បើប្រសិនជាបេក្ខជននេះ បំពេញលក្ខណ. អាយុ, សញ្ជាតិ សីលធម៌ពេញបរិបូណ៌តាមធម្មតា លុះផុតរយៈពេលប្រាំឆ្នាំហើយ បេក្ខជននេះ ទុកជាបានបំពេញកាតព្វកិច្ចហាត់ធ្វើការហើយ ត្រូវតាំងបេក្ខជននេះអស់មួយជីវិត ។

១៣.– បេក្ខជនណាដែលគ្មានសញ្ញាបត្រ តែបានបញ្ជាក់ថាបានធ្វើរដ្ឋាជីវៈ ដប់ប្រាំឆ្នាំក្នុងក្របខណ្ឌជាន់ខ្ពស់ ក្នុងរដ្ឋាភិបាលព្រះរាជាណាចក្រ អាចតាំងជាសារការីក្នុងរយៈពេលប្រាំឆ្នាំ ហើយបើតាំងជាថ្មីវិញបាន បើប្រសិនជាបេក្ខជននោះ បានបំពេញ លក្ខណៈអាយុសញ្ញាតិ, និងសីលធម៌បរិបូណ៌ ។

បេក្ខជនអាចតាំងអស់ជីវិតបាន បើប្រសិនជាខ្លួនបានសញ្ញាបត្រសមត្ថភាពច្បាប់ ឬសញ្ញាបត្រស្មើនឹងនេះ ក្នុងរយៈពេលប្រាំឆ្នាំដែលបានតាំងខ្លួនជាបណ្ដោះអាសន្ន ។ ការតាំងអស់មួយជីវិត មិនអាចធ្វើបាន បើសាមីខ្លួនមិនទាន់ធ្វើជាមេមន្ទីរសារការី បានប្រាំឆ្នាំទេ ។

មាត្រា៩.– ព្រះរាជក្រឹត្យតាំងសារការី ដែលធ្វើតាមសេចក្ដីស្នើសុំនៃរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវកំរិតប្រាក់ធានា ដែលសាមីខ្លួនត្រូវបង់មុនទទួលសម្បថសច្ចា ។

ប្រាក់ធានានេះ ត្រូវកំរិតដូចខាងក្រោម ចំពោះអ្នកកាន់កាប់ទី ១ នៅមន្ទីរសារការី ដែលបង្កើតតាមវគ្គទី ១ មាត្រា ៦ នៃព្រះរាជក្រមនេះ ។

១.– ដាក់ប្រាក់ធានា ៥០០.០០០រៀល ក្នុងគណនីឃ្លាំងធនាគារ ឬគ្រឹះស្ថានបង់ការប្រាក់ ដែលរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុបានអនុញ្ញាត ។

២.– បញ្ជាក់ថាខ្លួនមានអសង្ហារឹម: នៅប្រទេសខ្មែរផុតចាកពីការធានាបញ្ចាំ និងការបញ្ចាំទាំងអស់ អាចបញ្ចាំជាដំឡៃគិតតាមក្បួន ប្រថាប់ត្រាបានយ៉ាងតិច ១.០០០.០០០រៀល ។ មុននឹងទទួលសម្បថសច្ចា សាមីខ្លួនត្រូវដាក់បញ្ចាំអសង្ហារឹមនេះ ជាប្រយោជន៍ឃ្លាំងជាដំឡៃ ១.០០០.០០០រៀល ។ កិច្ចសន្យាបញ្ចាំត្រូវធ្វើតាមបញ្ញត្តមាត្រា ១០ នៃព្រះរាជក្រមនេះ ។

## ៣.— កាតព្វកិច្ច សិទ្ធិសារៈការី

មាត្រា១០.— សារៈការី គ្មានសមត្ថកិច្ចនឹងទទួលលិខិត ដែលខ្លួន បងប្អូនខ្លួន, ញាតិពន្ធុត្រង់ ឬសាខាញាតិរហូតដល់ថ្នាក់មានក្មួយតិតទាំងថ្នាក់នេះផង ត្រូវធ្វើជាគូសញ្ញា ឬលិខិតដែលមានបញ្ញត្តិ ជាត្រូវឲ្យផលប្រយោជន៍ដល់ខ្លួន ឬបងប្អូននេះទេ ។

ជនដែលមានសំដែងនៅវគ្គខាងលើ ត្រូវចាងហ្វាងសាលាជំរះក្តីបើកអនុញ្ញាតឲ្យទៅពឹងរកសារៈការីឯទៀត ដែលគ្មានសមត្ថកិច្ចតាមមាត្រាទេ ។

បើមានសារៈការីតែមួយនៅប្រទេសខ្មែរ ឬក្នុងករណីដែលសារៈការីទាំងអស់ នៅក្នុងទំរង់បញ្ញត្តិវគ្គខាងលើនៃមាត្រានេះ ចាងហ្វាងផ្នែករដ្ឋប្បវេណីសាលាជំរះក្តីនៅភ្នំពេញ ត្រូវតាំងចៅហ្វាយស្រុកដែលយល់ឃើញថាគួរតាមសាលក្រមដែលធ្វើឡើងតាមពាក្យសុំ ដែលបញ្ជូនមកពីមន្ត្រីស្តីការនៃរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ អ្នកកាន់ការនេះ ប្រតិបត្តិការដូចជាសារៈការីតាមទម្រង់ការដូចគ្នា ហើយមានអំណាចនឹងបានប្រាក់ជំណាច់ដូចសារៈការីដែរ ។

មាត្រា១១.— ក្នុងលិខិតទាំងឡាយ ដែលគូសញ្ញាទាំងអស់ឬតែមួយមិនអាចចុះហត្ថលេខាបាននោះ ត្រូវយកសាក្សីពីរនាក់ពេញនីតិភាពនឹងពេញសិទ្ធិឲ្យចុះហត្ថលេខាបាន ។

មាត្រា១២.— ក្នុងលិខិតទាំងឡាយណា ដែលមានគូសញ្ញាមួយនាក់ឬច្រើននាក់ មានសញ្ជាតិជាជនបរទេស សារៈការីត្រូវមានអ្នកប្រែភាសាជាជំនួយ មានភាសាបរទេសប៉ុន្មាន ត្រូវមានអ្នកប្រែភាសប៉ុណ្ណោះ ។

មាត្រា១៣.— មុននឹងចូលកាន់មុខក្រសួង សារៈការីត្រូវទទួលសម្បថសច្ចានៅចំពោះមុខអស់ក្រុមជំនុំនៃសាលាវិនិច្ឆ័យ ។ រូបមន្ត ពាក្យសម្បថមានដូចតទៅនេះ

" ខ្ញុំសូមសច្ចាប្រណិធានថា រាល់តែឱកាស ខ្ញុំប្រព្រឹត្តជាមន្ត្រីសាធារណៈមួយល្អ និងគោរពច្បាប់ និងលាក់បំបិទបំបាំងនូវការសម្ងាត់ នៃរឿងដែលខ្ញុំទទួលជាផ្ទុក បើទុកជាខ្ញុំឈប់លែងធ្វើការទៅក៏ដោយ" ។

មាត្រា១៤.— សារៈការីត្រូវនៅក្រោមរបៀបគ្រប់គ្រងច្បាប់វិន័យនៃសមាជិកក្រុមមេធាវី ។ ក្នុងករណីដែលមានធុរៈ ឬមានជម្ងឺ, មន្ត្រីនេះត្រូវចាត់ឲ្យធ្វើការមុខក្រសួងក្នុងមន្ទីរខ្លួន ដោយខ្លួនទទួលខុសត្រូវ ។ ក្នុងករណីមរណៈភាព, លាឈប់, បញ្ឈប់ ឬបណ្ដេញពីមុខក្រសួង, រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវតាំងអ្នកកាន់កាប់បណ្ដោះអាសន្ន ឲ្យកាន់កាប់មន្ទីរសារៈការីនេះ អ្នកកាន់កាប់នេះ ត្រូវទទួលសម្បថសច្ចាដែលមានបញ្ញត្តនៅមាត្រា ១៣ មុននឹងចូលដំណែង ។ អ្នកកាន់កាប់នេះ ត្រូវបំពេញលក្ខណៈតាមបញ្ញត្តដើម្បីតាំងជាសារៈការី លើកលែងតែប្រាក់ធានាចេញ ។

មាត្រា ១៥.— សារៈការីត្រូវតែទទួលការ កាលណាបើមានគេមកសុំ លើកលែងតែករណីដែលមានសំដែងនៅមាត្រា ១០ ឬកាលណាបើគូសញ្ញាទាំងអស់ ឬមួយណាជាជនវិកលលក្ខណៈគ្មាននីតិសម្បទា, បើកាលណាលិខិតមិនត្រឹមត្រូវតាមគន្លងច្បាប់ បើកាលណាគូសញ្ញាមិនបានបង់ប្រាក់ថ្លៃប្រដាប់ត្រា និងថ្លៃឈ្នួល បើមន្ត្រីនេះ មិនស្គាល់គូសញ្ញា ហើយគូសញ្ញានេះមិនអាចបង្ហាញនូវអត្តសញ្ញាណប័ណ្ណខ្លួនដោយសំបុត្រស្នាម ឬដោយយកសាក្សីពីរនាក់បាន ឬជាអវិសាន បើកាលណាសារៈការី មិនអាចនឹងទទួលការបាន ដោយមានហេតុជៀសវាងមិនរួច ។

មាត្រា ១៦ — ប្រាក់បំណាច់ជាប្រយោជន៍សារៈការី ដែលបានមកអំពីប្រាក់ថ្លៃឈ្នួល ត្រូវនៅក្នុងរបៀបគ្រប់គ្រងទបញ្ញត្ត ដែលមានប្រើមកត្រឹមថ្ងៃទី ២៩ សីហា គ.ស. ១៩៥៣ លើកលែងតែមានព្រះរាជក្រឹត្យកែប្រែដែលធ្វើឡើងដោយការជំនុំនៃគណៈរដ្ឋមន្ត្រី ។

មាត្រា ១៧.— បើមានចេញព្រះរាជក្រឹត្យមួយទៀតក្រោយ ដើម្បីនឹងបញ្ញត្តិពីបែបបទ ដែលត្រូវត្រួតត្រាលើសារៈការី ។

មាត្រា ១៨.— រហូតដល់ពេលប្រកាសឲ្យប្រើអត្តបទជាតិ ដែលរដ្ឋាភិបាលកាចតាំងឡើងតាមព្រះរាជក្រឹត្យ មុខក្រសួងសារៈការី ត្រូវគ្រប់គ្រងតាមបទបញ្ញត្តិនៃដេក្រេ ចុះថ្ងៃទី ២៤ សីហា គ.ស. ១៩២១ និងអត្តបទបាក់ទងទាំងអស់ ដែលមិនផ្ទុយនឹងព្រះរាជក្រមនេះ ហើយដែលបានប្រកាសឲ្យប្រើជាក្រមត្រូវទៅកណ្ដាបិន ត្រឹមថ្ងៃទី ២៩ សីហា គ.ស. ១៩៥៣ ។

មានការប្រែប្រួលនៃសេវានៃសារៈការីជាដើម និងចម្រង់លិខិតការទុកដាក់ និងការចម្លងពីលិខិតដើម ការកាន់សៀវភៅនិងបញ្ជី ។

ប៉ុន្តែសារៈការី គ្មានអំណាចនឹងសុំឲ្យរដ្ឋាភិបាលតាំងអ្នកជំនួសទេ តាមព្រំដែននៃព្រះរាជក្រមនេះ រដ្ឋាភិបាលមានឥស្សរភាពនឹងតាំងជនណាដែលយល់ថាគួរ ។

ធ្វើនៅព្រះបរមរាជវាំងក្រុងភ្នំពេញ, នៅថ្ងៃ ៥ ១២ ឆ្នាំមមីសក ព.ស. ២៤៩៧ ត្រូវនឹងថ្ងៃទី ៤ វិច្ឆិកា គ.ស. ១៩៥៤ ។

ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង
ទ្រង់ឡាយព្រះហស្តលេខាហើយៈ
ន. សីហនុ

---

ព្រះរាជក្រមលេខ ៩២២-ន.ស.

បានទ្រង់យល់ រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រ ។

បានទ្រង់យល់ ព្រះរាជក្រមលេខ ១៧១-ន ស. ចុះថ្ងៃទី ១៥ មេសា គ.ស. ១៩៤៦ ស្ដីពីមុខក្រសួងនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីទាំងឡាយ ។

# ឧបសម្ព័ន្ធ ២

# ច្បាប់ស្តីពីបរធនបាលកិច្ច (សន្ធានុក្រម)

ក្រុមប្រឹក្សាអ្នកច្បាប់
អគ្គលេខាធិការដ្ឋាន
ចូល លេខ: ០០៤
ថ្ងៃ: សុក្រ ទី ៤ ខែមករា ២០១៩
ម៉ោង: ១៤:០០ នាទី

# ព្រះរាជក្រម

## យើង

នស/រកម/០១១៩/០០៤

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីបរធនបាលកិច្ច ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨ នាសម័យប្រជុំរដ្ឋសភា លើកទី១ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨ នាសម័យប្រជុំពេញអង្គលើកទី២ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ឧបសម្ព័ន្ធនៃច្បាប់ស្តីពីបរធនបាលកិច្ច

## សន្ទានុក្រម

បច្ចេកសព្ទសំខាន់ៗជាសារវន្ត ដែលត្រូវបានប្រើក្នុងច្បាប់ស្តីពីបរធនបាលកិច្ចមាននិយមន័យដូចតទៅ៖

១- **ក្រមរដ្ឋប្បវេណី** សំដៅដល់ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

២- **ក្រមព្រហ្មទណ្ឌ** សំដៅដល់ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

៣- **ក្រមនីតិវិធីព្រហ្មទណ្ឌ** សំដៅដល់ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

៤- **ទ្រព្យសម្បត្តិ** សំដៅដល់ចលនវត្ថុនិងអចលនវត្ថុដែលបានកំណត់ក្នុងមាត្រា១២០នៃក្រមរដ្ឋប្បវេណី។

៥- **ទ្រព្យសម្បត្តិបរធនបាលកិច្ច** សំដៅដល់ទ្រព្យសម្បត្តិឬមូលនិធិដែលបានផ្ទេរទៅក្នុងបរធនបាលកិច្ច និងផលដែលបានពីទ្រព្យសម្បត្តិឬមូលនិធិនោះ។

៦- **បរធន** សំដៅដល់ទ្រព្យសម្បត្តិឬមូលនិធិដែលបានផ្ទេរទៅឱ្យបរធនបាលគ្រប់គ្រងនិងចាត់ចែងសម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ តាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

៧- **បរធនបាល** សំដៅដល់បុគ្គលដែលទទួលសិទ្ធិគ្រប់គ្រងនិងចាត់ចែងបរធនពីបរធនបាលទាយកសម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ ដោយអនុលោមតាមលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

៨- **បរធនបាលកិច្ច** សំដៅដល់កិច្ចការគ្រប់គ្រងនិងចាត់ចែងបរធនដែលផ្តល់ដោយបរធនបាលទាយកសម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ ដោយអនុលោមតាមលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

៩- **បរធនបាលទាយក** សំដៅដល់បុគ្គលដែលបង្កើតនិងកំណត់លក្ខខណ្ឌនៃបរធនបាលកិច្ច និងផ្តល់ទ្រព្យសម្បត្តិឬមូលនិធិដំបូងទៅក្នុងបរធនបាលកិច្ច។

១០- **បុគ្គល** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលណាមួយដែលត្រូវបានបង្កើតឡើងដោយស្របច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ទោះជាបុគ្គលនោះស្វែងរកប្រាក់ចំណេញឬមិនស្វែងរកប្រាក់ចំណេញ។

១១- **ប្រទានកម្ម** សំដៅដល់កិច្ចសន្យាដែលភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ឱ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិដោយមិនយកថ្លៃ ហើយភាគីម្ខាងទៀតយល់ព្រមទទួល។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

១២- **មតកសាសន៍** សំដៅដល់លិខិតបណ្ដាំដែលបុគ្គលបានធ្វើឡើងតាមទម្រង់ដែលកំណត់ដោយច្បាប់ដើម្បីសម្ដែងឆន្ទៈចុងក្រោយអំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍ បន្ទាប់ពីមរណភាព។

១៣- **លិខិតបរធនបាលកិច្ច** សំដៅដល់៖

ក- លិខិតគតិយុត្តដែលកំណត់ជាអាទិ៍អំពីការបង្កើត ការគ្រប់គ្រង ការចាត់ចែង និងការបញ្ចប់បរធនបាលកិច្ច ដែលត្រូវបានធ្វើឡើងរវាងបរធនបាលទាយកឬអ្នកផ្ដល់វិភាគទានបរធនបាលកិច្ច និងបរធនបាល ដោយមានការបញ្ជាក់ពីសារការី ឬមេធាវី ឬឃុំសង្កាត់ ឬដោយបុគ្គលផ្សេងទៀតដែល មានចែងក្នុងបទប្បញ្ញត្តិជាធរមាន។

ខ- មតកសាសន៍ដែលធ្វើឡើងស្របតាមបទប្បញ្ញត្តិស្ដីពីសន្តតិកម្មនៃក្រមរដ្ឋប្បវេណី។

១៤- **សិទ្ធិប្រត្យក្ស** សំដៅទៅលើសិទ្ធិគ្រប់គ្រងលើវត្ថុដោយចំពោះ ដែលអាចអះអាងចំពោះបុគ្គលដទៃទៀតបាន។

១៥- **សេវារក្សាទុក** សំដៅដល់ការផ្ទេរទ្រព្យសម្បត្តិឬមូលនិធិដោយបុគ្គលណាមួយទៅឱ្យបរធនបាលដើម្បីរក្សាទុក ហើយប្រគល់ទៅឱ្យបុគ្គលផ្សេងទៀតឬប្រគល់ត្រឡប់ទៅឱ្យបុគ្គលនោះវិញ តាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងលិខិតបរធនបាលកិច្ច។

១៦- **អត្ថគាហកៈ** សំដៅដល់បុគ្គលដែលទទួលផលប្រយោជន៍ពីបរធនបាលកិច្ច។

១៧- **អ្នកផ្ដល់វិភាគទានបរធនបាលកិច្ច** សំដៅដល់បុគ្គលដែលផ្ដល់វិភាគទានទៅក្នុងបរធនបាលកិច្ច ឬបរធនបាលកិច្ចដែលមានស្រាប់ និងមានសិទ្ធិចូលរួមកំណត់លក្ខខណ្ឌនៃការបង់វិភាគទានដែលនឹងត្រូវគ្រប់គ្រង និងចាត់ចែងដោយបរធនបាល និងលក្ខខណ្ឌនៃការទទួលផលរបស់អត្ថគាហកៈ។

១៨- **អំណោយ** សំដៅដល់ការផ្ទេរទ្រព្យសម្បត្តិដោយស្ម័គ្រចិត្តពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតដោយគ្មានតម្លៃតបស្នងឬកាតព្វកិច្ចត្រឡប់។

ROYAUME DU CAMBODGE • LE MINISTÈRE DU PALAIS ROYAL

# ឧបសម្ព័ន្ធ ៣
# អនុក្រឹត្យស្តីពីការបង្កើតមន្ទីរសារការី

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៥០៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតមន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១ ..**

ត្រូវបានបង្កើតមន្ទីរសារការីមួយ ដែលមានឈ្មោះថា **មន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា** (MEKONG Notary Public of the Kingdom of Cambodia) សរសេរកាត់ជាភាសាខ្មែរ "ម.ស.ម." និងសរសេរកាត់ជាភាសាអង់គ្លេស "M.N.P."។

**មាត្រា២ ..**

ត្រូវបានតែងតាំងជាសារការីនូវបុគ្គលដែលមានរាយនាមដូចខាងក្រោម ៖

១-លោកស្រី **ចាំខ ស្រីពៅ** ដើម្បីបំពេញមុខងារជាប្រធាននៃមន្ទីរសារការីមេគង្គ

២-លោក **សៅ ឡឿន** ដើម្បីបំពេញមុខងារជាអនុប្រធាននៃមន្ទីរសារការីមេគង្គ

៣-លោក **ប៉ាន់ ទាសនា** ដើម្បីបំពេញមុខងារជាសមាជិកនៃមន្ទីរសារការីមេគង្គ

៤-លោក **ផង់ ទិចិត្រ** ដើម្បីបំពេញមុខងារជាសមាជិកនៃមន្ទីរសារការីមេគង្គ។

ក្នុងករណីចាំបាច់ មន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា អាចធ្វើការជ្រើសរើសសារការី ដែលទទួលបានការតែងតាំងពីរាជរដ្ឋាភិបាល ឬបុគ្គលិកផ្សេងទៀត សម្រាប់ជួយបំពេញតួនាទី និងភារកិច្ច របស់ខ្លួនបាន។

**មាត្រា៣ ..**

មន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា មានទីស្នាក់ការនៅផ្ទះលេខ ២២ ផ្លូវលេខ ២៨១ ភូមិទី១៤ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

ក្នុងករណីមានការផ្លាស់ប្តូរទីស្នាក់ការ មន្ទីរសារការីត្រូវជូនដំណឹងមកក្រសួងយុត្តិធម៌។

**មាត្រា៤ ..**

មន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា មានតួនាទី និងភារកិច្ចដូចតទៅ ៖

- ទទួលធ្វើកិច្ចសន្យា ឬលិខិតគតិយុត្តទាំងឡាយដែលរូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទត្រូវការ
- ផ្តល់ប្រឹក្សាយោបល់ចំពោះកិច្ចការពាណិជ្ជកម្ម វិនិយោគ កិច្ចការគ្រួសារ និងការគ្រប់គ្រងចាត់ចែង ទ្រព្យសម្បត្តិ
- ផ្តល់ការបញ្ជាក់សុពលភាពចំពោះការបង្កើត ឬកែប្រែលក្ខន្តិកៈក្រុមហ៊ុន និងនីតិបុគ្គលគ្រប់ប្រភេទ
- ផ្តល់យថាភូតភាពដល់លិខិតគតិយុត្ត ឬកិច្ចសន្យា ឬឯកសារបកប្រែទាំងឡាយ តាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- ស្នើសុំឱ្យស្ថាប័នអនុវត្តធ្វើការអនុវត្តដោយបង្ខំនូវលិខិតគតិយុត្ត ឬកិច្ចសន្យាដែលទទួលបាន យថាភូតភាពពីសារការី
- ទទួលបញ្ជាក់ការចម្លងត្រឹមត្រូវតាមច្បាប់ដើមនូវរាល់លិខិតគតិយុត្ត ឬកិច្ចសន្យានានាតាមច្បាប់ តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- បញ្ជាក់ជានាហត្ថលេខា និងកាលបរិច្ឆេទនៃលិខិតគតិយុត្ត ឬកិច្ចសន្យានានា
- ធ្វើសំណើចុះបញ្ជី ឬចុះលេខាធិការទៅស្ថាប័នមានសមត្ថកិច្ច
- ទទួលតម្កល់ និងរក្សាទុកច្បាប់ដើមនៃកិច្ចសន្យា លិខិតឯកតោភាគីផ្សេងៗ មតកសាសន៍ និង លិខិតស្នាមគ្រប់ប្រភេទ
- ចេញច្បាប់ចម្លងនៃលិខិតយថាភូត
- និងទទួលធ្វើកិច្ចការផ្សេងៗទៀត ដែលអនុញ្ញាតដោយច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៥ ..**

នៅពេលចាប់ផ្តើមប្រតិបត្តិការសកម្មភាពរបស់ខ្លួន មន្ទីរសោរការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវតម្កល់ប្រាក់ចំនួន ៦០០.០០០.០០០ (ប្រាំមួយរយលាន) រៀល នៅធនាគារជាតិនៃកម្ពុជា សម្រាប់ធានាការទទួលខុសត្រូវក្នុងការបំពេញមុខងាររបស់ខ្លួន។

ក្នុងករណីដែលច្បាប់តម្រូវឱ្យមានការរំលាយមន្ទីរសោរការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា ប្រាក់តម្កល់ខាងលើនេះត្រូវបង្វិលជូនស្ថាបនិក និងសហកាតាដែលមានសិទ្ធិក្នុងការទទួល បន្ទាប់ពីបានកាត់កងទូទាត់បំណុល និងកាតព្វកិច្ចទាំងអស់ ដោយរាប់បញ្ចូលទាំងប្រាក់សោហ៊ុយនានា ដែលចាំបាច់សម្រាប់ធានានិរន្តរភាពនៃការការពារផលប្រយោជន៍របស់អតិថិជនខ្លួន អនុលោមតាមបែបបទ និងនីតិវិធីជាធរមាន។

ទំនាក់ទំនងគតិយុត្តរវាងស្ថាបនិក និងសហកាតា ត្រូវកំណត់ដោយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងដែលត្រូវអនុម័តដោយ មន្ទីរសោរការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៦ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៧ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ មន្ទីរសោរការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា និងសាមីខ្លួនដូចចែងក្នុងមាត្រា២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ២០១៦

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៧
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ ៤

# ឯកសារចម្លងនៃមតកសាសន៍ដោយលិខិតយថាភូត

<u>មតកសាសន៍</u>
<u>របស់</u>

ពុទ្ធសករាជ ពីរពាន់ប្រាំរយហុកសិបបី
ឯកស័ក ឆ្នាំកុរ ខែបុស្ស ថ្ងៃពុធ ប្រាំមួយ រោច
ត្រូវនឹង គ្រិស្តសករាជពីរពាន់ម្ភៃ ខែមករា ថ្ងៃទី ដប់ប្រាំ
វេលាម៉ោង ដប់ប្រាំ និង ម្ភៃប្រាំបី នាទី រសៀល

**សារការី សៅ នឿន ជាសារការីនៃ មន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា មានអាសយដ្ឋាន នៅផ្ទះលេខ២២ ផ្លូវលេខ ២៨១ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានី-ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។**

**បានទទួលសំណើពីម្ចាស់បណ្ដាំ (អ្នកធ្វើមតកសាសន៍) ដើម្បីធ្វើមតកសាសន៍តាមទម្រង់លិខិតយថាភូត ដូចខាងក្រោម៖**

**ដោយមានវត្តមានសាក្សីពីរនាក់៖**

លោក/លោកស្រី..................ភេទ......សញ្ជាតិ.........................កើតនៅថ្ងៃទី..............................
កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិ............លេខ........................ចុះថ្ងៃទី.........................................
មានអាសយដ្ឋាន បច្ចុប្បន្ននៅ...................................................................................។

លោក/លោកស្រី..................ភេទ......សញ្ជាតិ.........................កើតនៅថ្ងៃទី..............................
កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិ............លេខ........................ចុះថ្ងៃទី.........................................
មានអាសយដ្ឋាន បច្ចុប្បន្ននៅ...................................................................................។

សាក្សីដែលតម្រូវឱ្យមានដោយអនុលោមតាមច្បាប់ត្រូវបានជ្រើសរើស និងកោះអញ្ជើញដោយម្ចាស់បណ្ដាំ។ តាមការកោះសួររបស់សារការី សាក្សីទាំងពីរនាក់ខាងលើ បានប្រកាសយ៉ាងច្បាស់ជាក់លាក់ និងដាច់ដោយឡែកពីគ្នាថាពួកគេមានសញ្ជាតិខ្មែរ និងជានីតិជន យល់ និងចេះសរសេរអក្សរខ្មែរ ចេះចុះហត្ថលេខា មានសមត្ថភាព ប្រើប្រាស់សិទ្ធិស្របច្បាប់របស់ពួកគេ ហើយប្រកាសថាមិនមែនជាសន្តតិជន អច្ច័យលាភី និងសហព័ទ្ធ ហើយនិងមិនមានទំនាក់ទំនងញាតិលោហិតខ្សែផ្ទាល់ដែលច្បាប់ហាមឃាត់ ជាមួយនឹងម្ចាស់បណ្ដាំ និងអច្ច័យលាភីទេ ។

**បានចូលមកនៅចំពោះមុខយើង៖**

**ម្ចាស់បណ្ដាំ** ឈ្មោះ...................... ភេទ........ ថ្ងៃខែឆ្នាំកំណើត...........................សញ្ជាតិ...............
មានសំបុត្របញ្ជាក់កំណើតលេខ.................. ចុះថ្ងៃទី......................................មានទីកន្លែងកំណើត
............................................... ជា..................ពីឈ្មោះ.......................... ភេទ..................
ថ្ងៃខែកំណើត៖ .................. សញ្ជាតិ..................មានសំបុត្រ..................លេខ..........ចុះថ្ងៃទី
.................. ចេញដោយ..................។

ដែលមានស្មារតី និងសម្បទាជាប្រក្រតី នៅពេលធ្វើមតកសាសន៍ចំពោះមុខសារការី និងសាក្សីពីរនាក់ ដែលមានខ្លឹមសារទាំងស្រុងរបស់មតកសាសន៍នេះ មានដូចខាងក្រោម៖

**១. ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃមតកសាសន៍**

ខ្ញុំបាទ/នាងខ្ញុំសូមប្រកាសថា ខ្ញុំបាទ/នាងខ្ញុំគឺជាម្ចាស់កម្មសិទ្ធិទ្រព្យអវិភាគ ចំនួន................... និងត្រូវបានគ្រប់គ្រងទ្រព្យមត៌ក ................... នៃចំណែកកម្មសិទ្ធិទ្រព្យអវិភាគ របស់អតីតប្តី/ប្រពន្ធរបស់ខ្ញុំបាទ/នាងខ្ញុំ ដែលមានលើ អចលនវត្ថុ(ដី និងផ្ទះ) ដូចខាងក្រោម ៖

១.១. វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ...................

- ក្បាលដីលេខ ៖...................
- ទំហំដី ៖ ...................
- ទីតាំងដីស្ថិតនៅ ៖ ...................
- ចុះថ្ងៃទី................... ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខេត្ត/ក្រុង...................។

១.២. វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ...................

- ក្បាលដីលេខ ៖ ...................
- ទំហំដី ៖ ...................
- ទីតាំងដីស្ថិតនៅ ៖ ................... ។
- ចុះថ្ងៃទី................... ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខេត្ត/ក្រុង...................។

ច្បាប់ចម្លងនៃវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ខាងលើ មានភ្ជាប់ជាឧបសម្ព័ន្ធនៃមតកសាសន៍នេះ។

**២.ការប្រកាសអំពីញាតិរបស់ម្ចាស់បណ្តាំ៖**

ខ្ញុំបាទ/នាងខ្ញុំសូមប្រកាសថា ខ្ញុំបាទ/នាងខ្ញុំមានកូនបង្កើត ចំនួន ................... ប៉ុណ្ណោះ ដែលមាន កូន ឈ្មោះ ...................។

សារការីបានពន្យល់ម្ចាស់បណ្តាំអំពីសិទ្ធិទទួលបានភាគបម្រុង និងទំហំនៃភាគបម្រុងស្របតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ដែលសន្តតិជនផ្សេងទៀតត្រូវទទួលបាន ហើយម្ចាស់បណ្តាំបានយល់ច្បាស់ពីអត្ថន័យនៃបញ្ញត្តិស្តីពីភាគបម្រុងនេះ ដែលកូនៗរបស់គាត់ដែលមានសិទ្ធិលើភាគបម្រុង។ ដូចនេះ ម្ចាស់បណ្តាំ សម្រេចធ្វើការបែងចែងទ្រព្យសម្បត្តិរបស់គាត់ទៅអច្ច័យលាភីដូចមានបញ្ជាក់ក្នុងចំណុចទី៣នៃមតកសាសន៍នេះ ។

**៣. ការកំណត់អច្ច័យលាភី និងការបែងចែកទ្រព្យសម្បត្តិឱ្យទៅអច្ច័យលាភី ៖**

ខ្ញុំបាទ/នាងខ្ញុំ សូមប្រកាសលុបចោលនូវមតកសាសន៍ ដែលមានពីមុនទាំងអស់ និងរាល់លិខិតកែប្រែមតកសាសន៍ ទាំងអស់របស់ខ្ញុំបាទ/នាងខ្ញុំ ហើយសូមប្រកាសថាមតកសាសន៍នេះ គឺជាមតកសាសន៍ចុងក្រោយរបស់ខ្ញុំបាទ/នាងខ្ញុំ។

ខ្ញុំបាទ/នាងខ្ញុំសូមធ្វើការបែងចែកទ្រព្យសម្បត្តិរបស់ខ្ញុំបាទ/នាងខ្ញុំ និងទ្រព្យដែលបានពីមត៌ករបស់អតីតប្តីប្រពន្ធ ខ្ញុំបាទ/នាងខ្ញុំដែលមានកំណត់ក្នុងចំណុចទី ១ នៃមតកសាសន៍នេះទៅឱ្យកូនៗបង្កើតរបស់ខ្ញុំបាទ/នាងខ្ញុំក្នុងនាមជាអច្ច័យលាភី ដូចខាងក្រោម៖

ក. **អច្ច័យលាភីទី១**

ឈ្មោះ.................. ភេទ.................. កើតថ្ងៃទី..................សញ្ជាតិ.................. មានសំបុត្រ បញ្ជាក់កំណើតលេខ..................ចុះថ្ងៃទី..................មានទីកន្លែងកំណើតនៅ.............................. ទទួលបាននូវសិទ្ធិកាន់កាប់ ឬសិទ្ធិកម្មសិទ្ធិលើដី និងផ្ទះ ក្នុង**ចំណែក**..................លើចំណែកទាំងអស់នៃ អចលទ្រព្យជាមត៌ក ដូចមានចែងក្នុង**ចំណុច ១.១. និងចំណុច១.២.** នៃមតកសាសន៍នេះស្តីពី **ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃមតកសាសន៍**។

ខ. **អច្ច័យលាភីទី២**

ឈ្មោះ.................. ភេទ.................. កើតថ្ងៃទី..................សញ្ជាតិ.................. មានសំបុត្រ បញ្ជាក់កំណើតលេខ..................ចុះថ្ងៃទី..................មានទីកន្លែងកំណើតនៅ.............................. ទទួលបាននូវសិទ្ធិកាន់កាប់ ឬសិទ្ធិកម្មសិទ្ធិលើដី និងផ្ទះ ក្នុង**ចំណែក**..................លើចំណែកទាំងអស់នៃ អចលទ្រព្យជាមត៌ក ដូចមានចែងក្នុង**ចំណុច ១.១. និងចំណុច១.២.** នៃមតកសាសន៍នេះស្តីពី **ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃមតកសាសន៍**។

គ. **អច្ច័យលាភីទី៣**

ឈ្មោះ.................. ភេទ.................. កើតថ្ងៃទី..................សញ្ជាតិ.................. មានសំបុត្រ បញ្ជាក់កំណើតលេខ..................ចុះថ្ងៃទី..................មានទីកន្លែងកំណើតនៅ.............................. ទទួលបាននូវសិទ្ធិកាន់កាប់ ឬសិទ្ធិកម្មសិទ្ធិលើដី និងផ្ទះ ក្នុង**ចំណែក**..................លើចំណែកទាំងអស់នៃ អចលទ្រព្យជាមត៌ក ដូចមានចែងក្នុង**ចំណុច ១.១. និងចំណុច១.២.** នៃមតកសាសន៍នេះស្តីពី **ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃមតកសាសន៍**។

ឃ. **អច្ច័យលាភីទី៤**

ឈ្មោះ.................. ភេទ.................. កើតថ្ងៃទី..................សញ្ជាតិ.................. មានសំបុត្រ បញ្ជាក់កំណើតលេខ..................ចុះថ្ងៃទី..................មានទីកន្លែងកំណើតនៅ.............................. ទទួលបាននូវសិទ្ធិកាន់កាប់ ឬសិទ្ធិកម្មសិទ្ធិលើដី និងផ្ទះ ក្នុង**ចំណែក**..................លើចំណែកទាំងអស់នៃ អចលទ្រព្យជាមត៌ក ដូចមានចែងក្នុង**ចំណុច ១.១. និងចំណុច១.២.** នៃមតកសាសន៍នេះស្តីពី **ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃមតកសាសន៍**។

៤. **អ្នកប្រតិបត្តិមតកសាសន៍**

ក. ក្នុងគោលដៅគ្រប់គ្រងមត៌ក និងធ្វើនូវរាល់សកម្មភាពផ្សេងៗដែលចាំបាច់ ដើម្បីប្រតិបត្តិមតកសាសន៍នេះ ខ្ញុំបាទ/នាងខ្ញុំជាម្ចាស់បណ្តាំសូមជ្រើសតាំងអច្ច័យលាភី ឈ្មោះ ...............................ជាអ្នកប្រតិបត្តិមតកសាសន៍នេះ ។

ខ. ក្នុងករណីដែលឈ្មោះ ............................... មានជម្ងឺធ្ងន់ធ្ងរ ឬទទួលមរណភាពមុនម្ចាស់បណ្តាំ ឬមិនអាចបំពេញកិច្ចជាអ្នកប្រតិបត្តិមតកសាសន៍នេះបានដោយមូលហេតុណាមួយនោះ តួនាទីជាអ្នកប្រតិបត្តិមតកសាសន៍ នឹងត្រូវប្រគល់ទៅឱ្យឈ្មោះ ............................... ។

គ. ក្នុងករណីដែលឈ្មោះ ............................... មានជម្ងឺធ្ងន់ធ្ងរ ឬទទួលមរណភាពមុនម្ចាស់បណ្តាំ ឬមិនអាចបំពេញកិច្ចជាអ្នកប្រតិបត្តិមតកសាសន៍នេះបានដោយមូលហេតុណាមួយនោះ តួនាទីជាអ្នកប្រតិបត្តិមតកសាសន៍ នឹងត្រូវប្រគល់ទៅឱ្យឈ្មោះ ............................... ។

**ឃ.** ក្នុងករណីដែលឈ្មោះ .............................. មានជម្ងឺធ្ងន់ធ្ងរ ឬទទួលមរណភាពមុនម្ចាស់បណ្តាំ ឬមិនអាចបំពេញកិច្ចជាអ្នកប្រតិបត្តិមតកសាសន៍នេះបានដោយមូលហេតុណាមួយនោះ តួនាទីជាអ្នកប្រតិបត្តិមតកសាសន៍ នឹងត្រូវប្រគល់ទៅឱ្យឈ្មោះ .............................. ។

មតកសាសន៍នេះ ត្រូវបានសរសេរទាំងស្រុងដោយសារការី តាមការថ្លែងប្រាប់របស់ម្ចាស់បណ្តាំនៅចំពោះមុខសាក្សីទាំងពីររូប។ សារការីបានសូត្រខ្លឹមសារនៃមតកសាសន៍នេះឱ្យម្ចាស់បណ្តាំ និងសាក្សីស្តាប់ នៅចំពោះមុខសាក្សី ហើយម្ចាស់បណ្តាំ និងសាក្សីអះអាងថាពួកគាត់យល់ច្បាស់លាស់ និងទទួលស្គាល់ថាខ្លឹមសារនៃមតកសាសន៍នេះ គឺពិតជាចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំប្រាកដមែន។

មតកសាសន៍នេះ ត្រូវបានតាក់តែងជាភាសាខ្មែរចំនួន ០១ (មួយ) ច្បាប់ដើម មានចំនួន ០៤ (បួន) ទំព័រ ដោយរាប់ទាំងទំព័រចុះហត្ថលេខា ដែលត្រូវតម្កល់ទុកនៅ **មន្ទីរសារការីមេគង្គ នៃព្រះរាជាណាចក្រកម្ពុជា** ហើយត្រូវបើកនៅចំពោះមុខសារការីស្របតាមនីតិវិធីនៃច្បាប់ជាធរមាន ។

បន្ទាប់ពីសារការី បានសូត្រខ្លឹមសារទាំងស្រុងនៃមតកសាសន៍នេះឱ្យម្ចាស់បណ្តាំ និងសាក្សីស្តាប់ ហើយម្ចាស់បណ្តាំ និងសាក្សី យល់ព្រមចុះហត្ថលេខា និងផ្តិតស្នាមមេដៃនៅកាលបរិច្ឆេទខាងលើ។

<table>
<tr><td colspan="2">ម្ចាស់បណ្តាំ<br>ហត្ថលេខា និងស្នាមមេដៃ</td><td colspan="2">សាក្សី<br>ហត្ថលេខា និងស្នាមមេដៃ</td><td colspan="2">សាក្សី<br>ហត្ថលេខា និងស្នាមមេដៃ</td></tr>
<tr><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td colspan="2">ឈ្មោះ</td><td colspan="2">ឈ្មោះ</td><td colspan="2">ឈ្មោះ</td></tr>
</table>

លេខ៖....................../មសម/២០

**មន្ទីរសារការី មេគង្គនៃព្រះរាជាណាចក្រកម្ពុជា**

បញ្ជាក់ថា ម្ចាស់បណ្តាំ និងសាក្សីទាំងពីរនាក់
បានចុះហត្ថលេខា និង/ផ្តិតស្នាមមេដៃនៅចំពោះមុខខ្ញុំ
ដើម្បីជាសក្ខីភាព ខ្ញុំសូមចុះហត្ថលេខា និងប្រថាប់ត្រាមន្ទីរសារការី

# ឧបសម្ព័ន្ធ ៥

# ឯកសារចម្លងនៃមតកសាសន៍ដោយលិខិតឯកជន

# គម្រូទលិខិតបណ្តាំមត៌ក

(លិខិតបណ្តាំតាមទម្រង់លិខិតឯកជន)

មត្រា១១៧៤

## ១. អត្តសញ្ញាណរបស់ម្ចាស់បណ្តាំ (មតកជន)

ឈ្មោះ....................................................................................................................   ..............

..........................................................................................................................................................

........................................................................................................................................................។

(ចំណុចនេះអាចបញ្ជាក់អំពីសមត្ថភាពរបស់បុគ្គលដែលអាចធ្វើមតកសាសន៍)

មាត្រា១១៦៨

## ២. ស្ថានភាពពេលកំពុងសរសេរមតកសាសន៍

